# ការសិក្សាប្រៀបធៀប

## រវាង

# រដ្ឋាភិបាលមូលដ្ឋាន នៃបណ្ដា
# ប្រទេសចំនួន១៥ ក្នុងតំបន់
# អាស៊ីប៉ាស៊ីហ្វិក

# ការសិក្សាប្រៀបធៀប

# រវាង

# រដ្ឋាភិបាលមូលដ្ឋាន នៃបណ្តា ប្រទេសចំនួន១៥ ក្នុងតំបន់ អាស៊ីប៉ាស៊ីហ្វិក

# អារម្ភកថា

ប្រទេសជាច្រើននៅក្នុងតំបន់ កំពុងធ្វើកំណែទម្រង់ដែលផ្ដោតលើការធ្វើវិមជ្ឈការនីយកម្ម និងការប្រគល់មុខងាររបស់រដ្ឋាភិបាលទៅឲ្យថ្នាក់មូលដ្ឋាន នៅក្នុងប្រទេសចំនួន ១៥ ក្នុងតំបន់ **អាស៊ីប៉ាស៊ីហ្វិក** រួមមានប្រទេសអូស្ត្រាលី បង់ក្លាដេស ចិន ហ្វីជី ឥណ្ឌា ឥណ្ឌូនេស៊ី ជប៉ុន គីហ្គីស្ថាន ម៉ាឡេស៊ី ញ៉ូហ្ស៊ីឡែន ប៉ាគីស្ថាន ហ្វីលីពីន ស្រីលង្កា សាធារណរដ្ឋកូរ៉េ និងថៃ ក្នុងបំណងជួយដល់អ្នកធ្វើគោលនយោបាយ អ្នកស្រាវជ្រាវ និងអ្នកពាក់ព័ន្ធនានា បានធ្វើការសិក្សាបន្ត ។

ជាទូទៅ ដើម្បីលើកតម្កើងមុខងាររដ្ឋាភិបាលមូលដ្ឋាននៅក្នុងប្រទេសណាមួយ ឬក្នុងតំបន់ទាំងមូល អ្នកអានត្រូវយោងទៅលើរបាយការណ៍ទាំងនេះ ។ ក្នុងករណីដោយឡែក ឬក្នុងករណីជារួម របាយការណ៍នេះបានឆ្លុះបង្ហាញពីតម្លៃតែមួយគត់ សម្រាប់ការគ្រប់គ្រងរដ្ឋាភិបាលមូលដ្ឋាន នៅក្នុងបណ្ដាប្រទេសចំនួន១៥ ដែលមានប្រជាពលរដ្ឋរស់នៅស្ទើរតែពាក់កណ្ដាល នៃប្រជាជនពិភពលោកទាំងមូល ។

គោលបំណងនៃការសិក្សាវិភាគនេះ គឺដើម្បីលើកឡើងនូវបញ្ហានានា ស្ដីពីស្វ័យគ្រប់គ្រងមូលដ្ឋានចេញពីរបាយការណ៍នៃប្រទេសនីមួយៗ ហើយការសិក្សា វិភាគលើផ្នែកជាច្រើនដោយផ្អែកលើរបាយការណ៍ប្រចាំប្រទេសនីមួយៗ ដូចដែលអ្នកនិពន្ធបានបង្ហាញស្រាប់។

ការស្រាវជ្រាវនេះក្នុងបំណងរក្សាឲ្យបាននូវសេចក្ដី

នៃរចនាបថ និងទស្សនវិស័យនីមួយៗ។ តាមអញ្ញត្រកម្មមួយចំនួន ទស្សនៈ ទ្រឹស្តី ឬមតិយោបល់មួយចំនួនផ្សេងទៀតដែលបានមកពីអត្ថបទអំណានសិក្សា មិនត្រូវបានបង្ហាញនោះទេ។

សៀវភៅស្តីពី **ការសិក្សាប្រៀបធៀប រចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន នៃបណ្តាប្រទេសចំនួន១៥ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក** ជាស្នាដៃថ្មីមួយដែលអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាយល់ឃើញថា មានសារសំខាន់ នឹងអាចក្លាយជាឯកសារជំនួយស្មារតីមួយ សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត ក្នុងការរៀបចំធ្វើកំណែទម្រង់រដ្ឋបាលមូលដ្ឋានដែលមានស្រាប់ នៅក្នុងប្រទេសនីមួយៗ។ ម្យ៉ាងវិញទៀត ឯកសារនេះជាជំនួយលើការសិក្សាបន្ថែម ដល់អ្នកដែលចង់ធ្វើការសិក្សា ពីរបាយការណ៍របស់ប្រទេសនីមួយៗ ។

ជាទីបញ្ចប់ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា យល់ឃើញថា តាមរយៈនៃការស្រាវជ្រាវឯកសារនេះ នៅមានចំណុចខ្វះខាតខ្លះៗទៀត ដែលតម្រូវធ្វើការកែលម្អពីសំណាក់អ្នកអាន និងជាពិសេសពីអ្នកជំនាញ ។ យើងខ្ញុំនឹងរង់ចាំទទួលនូវការរិះគន់ស្ថាបនា ពីមិត្តអ្នកអានទាំងអស់ ដើម្បីឲ្យការស្រាវជ្រាវនេះកាន់តែប្រសើរឡើង ។

**រាជធានីភ្នំពេញ, ខែមិថុនា ឆ្នាំ២០១១**

**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

# ការសិក្សាប្រៀបធៀប
# ទោង
# រដ្ឋបាលមូលដ្ឋាន នៃបណ្ដាប្រទេសចំនួន១៥ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក

**ដឹកនាំ និងកែសម្រួលដោយ ៖**

-ឯកឧត្ដម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា

-ឯកឧត្ដម **ប៊ុន ឌុឡា** អគ្គនាយកសេវាច្បាប់ និងសម្ព័ន្ធភាពដែនដី

-ឯកឧត្ដម **គួច ចចិត្រ** អគ្គនាយករងសេវាច្បាប់ និងសម្ព័ន្ធភាពដែនដី

**សិក្សា ស្រាវជ្រាវ និងចងក្រងដោយ ៖**

-លោក **សុខ ឌុស្សី** ប្រធាននាយកដ្ឋានភូមិភាគ និងសម្ព័ន្ធភាពដែនដី

-លោក **អ៊ុង ចិន្ដា** អនុប្រធាននាយកដ្ឋានភូមិភាគ និងសម្ព័ន្ធភាពដែនដី

-លោក **យូន យ៉ាន** អនុប្រធាននាយកដ្ឋានភូមិភាគ និងសម្ព័ន្ធភាពដែនដី

-លោក **តា ទ្រី** ប្រធានការិយាល័យនីតិកម្មមូលដ្ឋាន នៃនាយកដ្ឋានភូមិភាគ និងសម្ព័ន្ធភាពដែនដី

-លោក **សេង សត្យា** អនុប្រធានការិយាល័យនីតិកម្មមូលដ្ឋាន នៃនាយកដ្ឋានភូមិភាគ និងសម្ព័ន្ធភាពដែនដី

ខែមិថុនា ឆ្នាំ២០១១

# **សេចក្តីថ្លែងអំណរគុណ**

សៀវភៅស្តីពី **ការសិក្សាប្រៀបធៀប រចនាសម្ព័ន្ធរដ្ឋាភិបាលមូលដ្ឋាន នៃបណ្តាប្រទេសចំនួន១៥ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក** នេះ កើតចេញពីការស្រាវជ្រាវនៃប្រភពឯកសារភាសាបរទេសមួយចំនួន ដែលសរសេរជាភាសាអង់គ្លេស ។

ក្នុងនាមយើងខ្ញុំក្រុមការងារទាំងអស់គ្នា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការESCAP ដោយសហការជាមួយការិយាល័យ នៃសហភាពអន្តរជាតិ ស្តីអំពីអាជ្ញាធរមូលដ្ឋាននៅតំបន់អាស៊ីប៉ាស៊ីហ្វិក(IULA-ASPAC)និងមូលនិធិអាជ្ញាធរមូលដ្ឋាន នៃសាធារណរដ្ឋកូរ៉េ សម្រាប់កិច្ចការទំនាក់ទំនងអន្តរជាតិ (KLAFIR) និងវិទ្យាស្ថានឥណ្ឌា ស្តីអំពីស្វ័យគ្រប់គ្រងមូលដ្ឋាន (AIILSG) បានផ្តួចផ្តើមគំនិតធ្វើការសិក្សាស្តីអំពីប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន ឆ្នាំ១៩៩៧ ដែលជាប្រភពសំខាន់ក្នុងការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ ។

ជាទីបញ្ចប់ ក្រុមការងារយើខ្ញុំ សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី ដែលបានផ្តល់ឱកាសឲ្យក្រុមសិក្សាស្រាវជ្រាវ នឹងចងក្រង ព្រមទាំងសម្រួលការងាររហូតដល់បានបញ្ចប់ប្រកបដោយជោគជ័យ ។

**រាជធានីភ្នំពេញ, ខែមិថុនា ឆ្នាំ២០១១**

ក្រុមការងារ

# មាតិកា

ទំព័រ

សេចក្តីផ្តើម......................................................................................១

I-ប្រវត្តិវិមជ្ឈការមូលដ្ឋាន.....................................................៤

-ប្រអប់ទី១ ៖ វិមជ្ឈការមូលដ្ឋានក្រោយសម័យឯករាជ្យ .....៦

II-បញ្ហាស្វ័យគ្រប់គ្រងមូលដ្ឋាន...................................១២

ក-ការរៀបចំរចនាសម្ព័ន្ធ និងស្ថាប័ន.......................១៣

ខ-ហិរញ្ញវត្ថុ....................................................................១២

-ប្រអប់ទី២៖ប្រែកពចំណុលសំខាន់ៗរបស់វិមជ្ឈការមូលដ្ឋាន

...................................................................................... ១៧

គ-អំពីរដ្ឋបាល.................................................................២៣

ឃ-ការងារនីតិកម្ម..........................................................២៨

-ប្រអប់ទី៣ ៖ ក្របខ័ណ្ឌគតិយុត្តសម្រាប់វិមជ្ឈការមូលដ្ឋាន

.......................................................................................៣០

III-ទំនាក់ទំនងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន...............៣៤

-ប្រអប់ទី៤ ៖ រចនាសម្ព័ន្ធវិមជ្ឈការ...................................៣៧

IV-អភិបាលកិច្ចមូលដ្ឋាន.......................................................៤៦

ក-ស្វ័យភាពមូលដ្ឋាន.........................................................៤៧

ខ-ឯកជនភាវូបនីយកម្ម-សាធីវកម្មនីយកម្ម........៥៣

គ-ការបោះឆ្នោតមូលដ្ឋាន..............................៥៨
V-ការចូលរួមរបស់សង្គមស៊ីវិល និងសហគមន៍.............៦២
ក-តម្រូវការឱ្យមានការចូលរួម..........................៦៣
ខ-ក្រុមសង្គមស៊ីវិល............................................៦៥
ប្រអប់ទី៥ ៖ បច្ចេកទេសសម្រាប់ឱ្យមានការចូលរួម.........៦៦
ក-ការបំពាក់សម្ភារសម្រាប់ឱ្យមានការចូលរួម......៦៨
ខ-ការចូលរួមរបស់ក្រុមដែលបាត់បង់ផលប្រយោជន៍
................................................................................៦៩
VI-សមត្ថភាពរបស់មូលដ្ឋាន..................................៧២
ក-ធនធានមនុស្ស..............................................៧៣
ខ-ការតែងតាំង..................................................៧៣
គ-ការបណ្តុះបណ្តាល និងការបំពាក់សម្ភារ.........៧៦
ប្រអប់ទី៦៖ការផ្តោតលើកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាន.៧៧
ឃ-ការបណ្តុះបណ្តាលឡើងវិញ.......................៨០
ង-ប្រភពចំណូល...............................................៨២
ច-សមត្ថភាពសហគមន៍.................................៨៦
VII-របៀបវារៈដើម្បីសកម្មភាព...............................៨៨
ក-ការងារអនុវត្តនិងការត្រួតពិនិត្យ......................៨៩
ខ-ស្វ័យភាពមូលដ្ឋាន..........................................៩០

គ-ការងារនីតិកម្ម........................................៩០

ឃ-ទំនាក់ទំនងពីថ្នាក់កណ្តាល-ថ្នាក់មូលដ្ឋាន......៩១

ង-រដ្ឋបាល...................................................៩២

ច-ហិរញ្ញវត្ថុរដ្ឋាភិបាលមូលដ្ឋាន.........................៩៤

ឆ-ធនធានមនុស្ស.........................................៩៤

ជ-ការចូលរួមពីសាធារណៈ..............................៩៦

**-ឯកសារពិគ្រោះ**..........................................................៩៨

**-ឧបសម្ព័ន្ធ**...................................................................៩៩

**-រដ្ឋធម្មនុញ្ញពិភពលោកស្តីពីរដ្ឋាភិបាលស្វ័យគ្រប់គ្រងមូលដ្ឋាន**..១២៦

## សេចក្តីផ្តើម

ក្នុងរយៈពេល៣០ឆ្នាំកន្លងមកនេះ ប្រជាជនរស់នៅក្នុងទីក្រុង នៃតំបន់អាស៊ីប៉ាស៊ីហ្វិក បានកើនដល់៥៦០លាននាក់ គឺកើនឡើង២៦០% ហើយក្នុងរយៈពេល៣០ឆ្នាំបន្ទាប់ គេរំពឹងថាប្រជាជននឹងកើនឡើងប្រហែល១,៤៥០លាននាក់ គឺកើនឡើង២៥០%។

ដំណើរការនគរូបនីយកម្មដែលមិនធ្លាប់មានពីមុនមក នឹងជួបនូវការលំបាកកាន់តែច្រើនឡើង ក្នុងការដោះស្រាយសម្ពាធពីសង្គមទំនើបសព្វថ្ងៃទៅលើធនធានធម្មជាតិ និងធនធានមនុស្សដែលមានកម្រិតស្រាប់។

នៅពាក់កណ្ដាលទសវត្សឆ្នាំ១៩៩០ តំបន់អាស៊ីប៉ាស៊ីហ្វិកបានជួបប្រទះនូវកំណើនសេដ្ឋកិច្ចឆាប់រហ័ស ព្រមទាំងការធ្វើឧស្សាហូបនីយកម្ម និងនគរូបនីយកម្មបានយ៉ាងឆាប់រហ័ស ។ វាប្រាកដណាស់ថាឥទ្ធិពលចម្បងដែលប៉ះពាល់ដល់តំបន់នៅពេលអនាគត គឺជាការផ្លាស់ប្ដូរ និងការកើនឡើងនៅតំបន់ទីក្រុង ។ ទីក្រុងមេហ្គា និងទីក្រុងធំៗ ដែលមានប្រជាជនលើសពីមួយលាននាក់ បានកើនមានឡើងកាន់តែច្រើន ។

ទីក្រុងទាំងឡាយក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកគឺជាមជ្ឈមណ្ឌលតំណាងឱ្យក្ដីសង្ឃឹមផង និងក្ដីអស់សង្ឃឹមផង ពោលគឺដោយសារតែមានក្បាលម៉ាស៊ីនអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមដែលធ្វើឱ្យទីក្រុងទាំងឡាយ ក្លាយជាតំបន់ដែលចម្រុះដោយភាពក្រីក្រ និងការធ្លាក់ចុះនៃបរិស្ថាន ។

ប្រសិនបើពិភពលោក នៅតែបន្តនិន្នាការដូចបច្ចុប្បន្ន នា

សតវត្សទី២១នឹងក្លាយជាសតវត្សអាស៊ី ដោយសារទ្វីបអាស៊ីក្លាយជាចុងអាគុយ ឬជាឆ្អឹងខ្នងសេដ្ឋកិច្ចធំសំខាន់នៅក្នុងលោក។ ដល់ឆ្នាំ២០២៥ ប្រជាជនទ្វីបអាស៊ីភាគច្រើនបំផុត នឹងក្លាយជាអ្នករស់នៅទីក្រុង ។ ដោយសារសកម្មភាពសេដ្ឋកិច្ច ដែលមានតម្លៃបន្ថែមច្រើន និងមានប្រជាជនច្រើនរស់នៅតំបន់ប្រជុំជន ដូច្នេះតើនៅពេលនោះទីក្រុងនានានឹងប្រព្រឹត្តទៅបានល្អយ៉ាងណា ? ដោយហេតុថា ប្រព័ន្ធនេះ ជាកត្តាកំណត់អំពីអនាគតរបស់ទ្វីបអាស៊ី ។

ខណៈដែលសេដ្ឋកិច្ច និងសង្គមអាស៊ីនិងប៉ាស៊ីហ្វិកកំពុងឆ្លងកាត់ ការវិវត្តប្រែប្រួល យ៉ាងឆាប់រហ័ស ប៉ុន្តែរចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋាភិបាលនៅបណ្ដាប្រទេសភាគច្រើនក្នុងតំបន់ មានការប្រែប្រួលយឺត និងឆ្លើយតបបានតិចតួចចំពោះបញ្ហាប្រឈមថ្មីៗ។

ដើម្បីដោះស្រាយបាននូវបញ្ហាប្រឈមនានា ក្នុងសតវត្សទី២១នេះ គេគួរតែប្រើគំរូអនុវត្តបែបថ្មី ដោយផ្អែកលើភាពជាដៃគូរវាង រដ្ឋាភិបាលមូលដ្ឋាន និងសង្គមស៊ីវិល រួមទាំងវិស័យឯកជនកត្តានេះទាមទារឱ្យមានការវាយតម្លៃជាមូលដ្ឋានឡើងវិញ ចំពោះទម្រង់ និងលក្ខណៈអភិបាលកិច្ចមូលដ្ឋាននៅទ្វីបអាស៊ីប៉ាស៊ីហ្វិក។

ការរស់នៅក្នុងទីក្រុងនៅអាស៊ី(ESCAP ឆ្នាំ១៩៩៦) និងធម្មនុញ្ញពិភពលោក ស្ដីពីស្វយ័តគ្រប់គ្រងមូលដ្ឋាន បានលើកឡើងនូវគោលការណ៍នានា ស្ដីពីការបែងចែកភារកិច្ច និងភាពនៅជិតនឹងប្រជាពលរដ្ឋ ក្នុងការធ្វើកំណែទម្រង់រចនាសម្ព័ន្ធអភិបាលកិច្ចដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនានា ក្នុងសតវត្សទី២១ ។ម្យ៉ាងវិញទៀតការសម្រេចចិត្ត គួរតែត្រូវធ្វើឡើងនៅថ្នាក់រដ្ឋបាល ដែល

នៅជិតនឹងប្រជាពលរដ្ឋបំផុតហើយមានតែភារកិច្ចណាដែលថ្នាក់មូលដ្ឋានមិនអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព ដោយខ្លួនឯងទេ ទើបប្រគល់ភារកិច្ចនោះទៅឱ្យរដ្ឋបាលថ្នាក់លើអនុវត្ត។

កំណែទម្រង់ស្ថាប័ន និងអភិបាលកិច្ច ត្រូវធ្វើទន្ទឹមគ្នានឹងការធ្វើកំណែទម្រង់មុខងារសាធារណៈ តាមរយៈការអភិវឌ្ឍទូលំទូលាយ និងការរៀបចំគ្រប់គ្រងធនធានមនុស្សដ៏ឈ្លាសវៃ។ របាយការណ៍របស់ប្រទេសម៉ាឡេស៊ី ដកស្រង់សម្ដីរបស់លោកបណ្ឌិត Mahathir Mohammad នាយករដ្ឋមន្ត្រីម៉ាឡេស៊ីថា៖ បើនិយាយពីការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សនៅក្នុងសេដ្ឋកិច្ចពិភពលោក សេវាសាធារណៈត្រូវបានរៀបចំ ដើម្បីអាចដោះស្រាយបញ្ហាប្រឈមថ្មីៗនៅក្នុងសតវត្សទី២១នេះ ។ ដូច្នេះការខិតខំប្រឹងប្រែង ត្រូវធ្វើឡើងដើម្បីពិនិត្យមើលការផ្ដល់សេវាសាធារណៈជាប្រចាំឱ្យស្របតាមសេចក្ដីត្រូវការ និងសម័យកាលបច្ចុប្បន្ន ។ យើងចាំបាច់ត្រូវពិចារណាអំពីរបៀប និងមធ្យោបាយបែបថ្មី ដើម្បីលើកកម្ពស់សមត្ថភាពក្នុងការផ្ដល់សេវាសាធារណៈរបស់យើង ( Mahathir 1995) ។

នេះគឺជាប្រធានបទ ដែលបានកំណត់អំពីការសិក្សាវិភាគប្រៀបធៀប។ ប្រសិនបើយើងត្រូវចេញពីគំរូចាស់ ឆ្ពោះទៅប្រើគំរូថ្មី តើមានបញ្ហាអ្វីខ្លះ ? ដែលត្រូវលើកយកមកពិចារណា តើមានបញ្ហាអ្វីខ្លះ ? ដែលត្រូវជំនះឱ្យបាន តើមានការអនុវត្តល្អៗអ្វីខ្លះ ? ដែលគួរបន្តអនុវត្ត ។ ប្រវត្តិសង្ខេបពាក់ព័ន្ធនឹងប្រទេសនានា ត្រូវបានបង្ហាញមុននឹងឈានមកដល់ការពិភាក្សាតាមជំពូក។

បន្ទាប់ពីពិចារណាអំពីបញ្ហានានារួច យើងនឹងពិភាក្សាអំពីរបៀបវារៈមុខការដែលពិចារណាពីចំណុចដែលបានពិភាក្សានេះ។

**I-ប្រវត្តិរដ្ឋាភិបាលមូលដ្ឋាន**

គ្រប់ប្រទេសទាំងអស់ សុទ្ធតែមានប្រវត្តិដើមយូរអង្វែងពាក់ព័ន្ធអភិបាលកិច្ចមូលដ្ឋាន ទោះបីមិនមានទម្រង់ជាស្ថាប័នរដ្ឋាភិបាលមូលដ្ឋានពិតប្រាកដក៏ដោយ ។ នៅសាធារណរដ្ឋកូរ៉េប្រវត្តិដ៏យូរលង់ មានមូលដ្ឋានគ្រឹះរបស់ខ្លួនជាស្ថាប័នក្រៅផ្លូវការដោយស្ម័គ្រចិត្តក្នុងបំណងបង្កើនការជួយគ្នាទៅវិញទៅមក ក្នុងចំណោមប្រជាជន និងការបង្កើនសីលធម៌សម្រាប់សហគមន៍ និងប្រព័ន្ធជួយគ្នាទៅវិញទៅមក ។ ទោះបីអ្នកអះអាងថា ប្រទេសគីហ្ស៊ីស្ថាន មិនមានប្រវត្តិវែងឆ្ងាយក៏ដោយ ក៏ប្រទេសនេះមានទម្រង់មូលដ្ឋាន ស្តីពីស្វ័យគ្រប់គ្រងមូលដ្ឋាន អស់រយៈពេលយ៉ាងយូរណាស់មកហើយ ។ គំនិតផ្តួចផ្តើមបច្ចុប្បន្នសម្រាប់ឱ្យមានប្រជាធិបតេយ្យមូលដ្ឋាន អាចចាត់ទុកជាចំណុចរបត់មួយ ចំពោះបុព្វបទប្រវត្តិសាស្ត្រទាំងអស់នេះ។ អស់ពេលជាច្រើនសតវត្ស រដ្ឋាភិ-បាលមូលដ្ឋាននៅប្រទេសស្រីលង្កា រួមមានមុខងារតុលាការ ដូចជាដោះស្រាយបទល្មើសតូចតាចនិងផ្សះផ្សាវិវាទ ។ សព្វថ្ងៃនេះជាទូទៅ មុខងារតុលាការ ត្រូវបានផ្ទេរទៅឱ្យរដ្ឋាភិបាលថ្នាក់លើ។

ការជួយគ្នាទៅវិញទៅមក មូលដ្ឋានគ្រឹះសីលធម៌ យុត្តិធម៌ និងការផ្សះផ្សា គឺជារូបភាពនៃអភិបាលកិច្ចសហគមន៍។ ការកាន់កាប់ដោយអំណាចអាណានិគមនៅអាស៊ីប៉ាស៊ីហ្វិក បានបន្សល់ទុកនូវមរតករបៀបគ្រប់គ្រងរដ្ឋ តាមបែបមជ្ឈការ ដែលមានលក្ខណៈ

ងាយស្រួលបញ្ហាអនុវត្តច្បាប់ និងបទបញ្ជា ងាយស្រួលក្នុងការប្រមូលចំណូល ជាជាងការអនុវត្តអភិបាលកិច្ច និងការចូលរួមនៅថ្នាក់មូលដ្ឋាន ។ ទន្ទឹមនឹងនេះ គំរូរដ្ឋបាលអាណានិគម ត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងសហគមន៍មូលដ្ឋាន ដែលភាគច្រើនបំផុតមិនពាក់ព័ន្ធ ប្រព័ន្ធអភិបាលកិច្ចជាប្រវត្តិសាស្ត្ររបស់ពួកគេទេ ។ ដូចជារបាយការណ៍របស់ប្រទេសបង់ក្លាដេស បង្ហាញឱ្យឃើញថា គោលដៅចម្បងរបស់ពួកអង់គ្លេសនៅឥណ្ឌាមានពីរផ្លូវ ៖

១-ការពង្រីកការប្រមូលចំណូលពីដីធ្លីឱ្យបានជាអតិបរិមា

២-ការពង្រឹងការអនុវត្តច្បាប់ និងបទបញ្ជា។

តាមធម្មតា អង់គ្លេសជាអំណាចចក្រភពមានការយល់ដឹង និងចាប់អារម្មណ៍តិចតួចអំពីស្ថាប័នស្វ័យគ្រប់គ្រងមូលដ្ឋាន ដែលមាននៅក្នុងស្រុក។ ទម្រង់មជ្ឈការខ្ពស់នៅក្នុងរដ្ឋាភិបាលមូលដ្ឋាន បានកើតមាននៅប្រទេសហ្វីលីពីនអស់ពេលចំនួន៣សតវត្ស ដែលគេហៅថា "រដ្ឋបាលអាណាព្យាបាល និងអាណានិគម" របស់របបអាណានិគមអេស្ប៉ាញ។ សតវត្សនេះ នៅប្រទេសហ្វីលីពីន វាបិតនៅក្រោមរដ្ឋាភិបាលមូលដ្ឋានបែបអាមេរិក ត្រូវបានធ្វើហ្វីលីពីនូបនីយកម្ម ។ សូម្បីប្រព័ន្ធមូលដ្ឋានសព្វថ្ងៃ មិនមែនជាប្រព័ន្ធអាណានិគមក៏ដោយ ក៏ប្រព័ន្ធនេះនៅមានឥទ្ធិពលពីអំណាចអាណានិគមនៅក្នុងតំបន់ ហើយដូចជាករណីប្រទេសហ្វីជី អាជ្ញាធរត្រូវគោរពទៅតាមរបបអំណាចអាណានិគម។រដ្ឋាភិបាលមូលដ្ឋាននៅប្រទេសថៃជាឧទាហរណ៍គឺផ្អែកលើគំរូពីប្រទេសអាល្លឺម៉ង់ ចក្រភពអង់គ្លេស និង Northern Ireland បារាំង ហើយក្រោយមកទៀតយកគំរូតាម

សហរដ្ឋអាមេរិក ។

ការធ្វើមជ្ឈការនីយកម្មអាណាធរវជ្ជបាលនេះ គឺមិនបានធ្វើឱ្យខូចប្រយោជន៍ទេ។ ក្រោយពីបានទទួលឯករាជ្យ ប្រទេសភាគច្រើន បានខិតខំបោះជំហានទៅមុខកសាងជាតិ និងធ្វើឧស្សាហូបនីយកម្មយ៉ាងឆាប់រហ័ស តាមរយៈការធ្វើមជ្ឈការនីយកម្ម។ បើគ្មានករណីលើកលែងទេ ប្រទេសទាំង១៥ ដែលបានបង្ហាញនៅក្នុងអត្ថបទនេះ បានផ្ដួចផ្ដើមធ្វើកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាន។

បញ្ហាដែលនាំឱ្យមានការធ្វើកំណែទម្រង់នេះ គឺដើម្បីភាពស័ក្ដិសិទ្ធិនៅក្នុងវិស័យសាធារណៈ ការធ្វើប្រជាធិបតេយ្យនីយកម្ម និងការផ្លាស់ប្ដូររបបនយោបាយសេដ្ឋកិច្ច ឱ្យទៅជារបបសេដ្ឋកិច្ចចម្រុះ (ករណីចិន) និងសេដ្ឋកិច្ចទីផ្សារ (ករណី គីហ្ស៊ីស្ថាន)។ មូលបទនេះ គឺជាពូជសម្រាប់សាបព្រោះគំរូអនុវត្តថ្មី នៃស្វយ័តភិបាលមូលដ្ឋានឱ្យរីកដុះដាលឡើង ។ តាមរបៀបជាច្រើននិន្នាការទាំងនេះ មិនមែនជានិន្នាការថ្មីទេ ប៉ុន្តែវាតំណាងឱ្យឫសគល់នៃអភិបាលកិច្ចមូលដ្ឋានដែលភាគច្រើនបំផុតមានប្រវត្តិរាប់សតវត្សមកហើយ។

លក្ខណៈសម្គាល់មួយ ក្នុងចំណោមលក្ខណៈជាច្រើននៃរដ្ឋាភិបាលមូលដ្ឋាននៅសតវត្សនេះ គឺជាការធ្វើជាតូបនីយកម្មរដ្ឋាភិបាលមូលដ្ឋាន ក្រោយពីទទួលបានឯករាជ្យ។ រដ្ឋាភិបាលមូលដ្ឋាន ត្រូវបានរៀបចំឡើងវិញ តាមអត្តសញ្ញាណជាតិនីមួយៗ។

**ប្រអប់ទី១៖ រដ្ឋាភិបាលមូលដ្ឋានក្រោយសម័យឯករាជ្យ**

ប្រទេសអូស្ត្រាលី ៖ រដ្ឋធម្មនុញ្ញចែងច្បាស់ថា ប្រទេសអូស្ត្រាលី ត្រូវបន្តប្រកាន់យកប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានមួយដែល

អង្គភាពរដ្ឋាភិបាលមូលដ្ឋាន មានការបោះឆ្នោតយ៉ាងទៀងទាត់ ឬមានការតែងតាំងយ៉ាងទៀងទាត់ និងមានការទទួលខុសត្រូវក្នុងការធ្វើសកម្មភាពតាមផ្នែកគ្រប់គ្រងរបស់ខ្លួន ឱ្យបានកាន់តែល្អប្រសើរឡើង ។ របៀបធ្វើការ នៅក្នុងអង្គភាពរដ្ឋាភិបាលមូលដ្ឋាន មានចរិកលក្ខណៈ និងវិសាលភាពនៃអំណាចអាជ្ញាធរ តួនាទី និងមុខងារទាំងឡាយរបស់អង្គភាពមូលដ្ឋាន ត្រូវកំណត់ដោយ ឬអនុលោមទៅតាមច្បាប់របស់អង្គនីតិប្បញ្ញត្តិ ។

ប្រទេសបង់ក្លាដេស ៖ តាំងពីបានទទួលឯករាជ្យ នៅឆ្នាំ១៩៧១មក ប្រទេសនេះមានគោលបំណងយ៉ាងមុតមាំ ក្នុងការកែសម្រួលប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាននេះ។ការផ្លាស់ប្តូរជាច្រើនកើតមានពីពេលមួយទៅពេលមួយ ស្របតាមអាណត្តិនៃបញ្ជីឈ្មោះរដ្ឋាភិបាលមូលដ្ឋានបន្តបន្ទាប់ ក៏ប៉ុន្តែគេសង្កេតឃើញស្ទើរតែគ្មានការពង្រឹងស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន ឱ្យរឹងមាំទាល់តែសោះ ។ រចនាសម្ព័ន្ធប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន ហាក់ដូចជានៅតែដដែលស្ទើរតែគ្មានការប្រែប្រួលសោះ។ រដ្ឋាភិបាលបច្ចុប្បន្ន បានបង្កើតគណៈកម្មការទទួលបន្ទុកការងាររដ្ឋាភិបាលមូលដ្ឋាននៅឆ្នាំ១៩៩៦ ដែលក្រោយមកបានស្នើសុំឱ្យមានការបង្កើតរចនាសម្ព័ន្ធ រដ្ឋាភិបាលមូលដ្ឋានមួយ ដែលមានបួនថ្នាក់។

ប្រទេសចិន ៖ មហាសន្និបាតលើកទី១៣ របស់បក្សកុំម្មុយនីស្តចិនបានសម្រេចនៅខែតុលា ឆ្នាំ១៩៨៧ តាំងចិត្តធ្វើកំណែទម្រង់ប្រព័ន្ធនយោបាយ ដោយភ្ជាប់មកជាមួយនឹងកំណែទម្រង់សេដ្ឋកិច្ច ។ ៥ឆ្នាំក្រោយមក ប្រទេសចិនបានសម្រេចចិត្តអនុវត្ត

កំណែទម្រង់នយោបាយ និងកសាងនយោបាយប្រជាធិបតេយ្យសង្គមនិយម ស្របតាមរូបភាពរបស់ខ្លួន ។

ប្រទេសហ្វីជី ៖ ក្រោយពីទទួលបានឯករាជ្យ បទប្បញ្ញត្តិសម្រាប់គ្រប់គ្រងឃុំ សង្កាត់ត្រូវបានពង្រឹង ហើយរដ្ឋបាលត្រូវបានបំលែងទៅជា ក្រុមប្រឹក្សាដែលមានការបោះឆ្នោត ។

ប្រទេសឥណ្ឌា ៖ គណៈកម្មាធិការទំនាក់ទំនងជនបទ និងទីក្រុង ដែលបង្កើតឡើងដោយរដ្ឋាភិបាលឥណ្ឌានៅឆ្នាំ១៩៦៣ បានគូសបញ្ជាក់ថា រដ្ឋាភិបាលមូលដ្ឋាន មិនអាចនៅតែជាឧបករណ៍អប់រំនយោបាយ និងមនសិការពលរដ្ឋទេ ប៉ុន្តែត្រូវតែក្លាយជាស្ថាប័នសម្រាប់លើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់សហគមន៍មូលដ្ឋាន ព្រមទាំងជាផ្នែករួមមួយនៃរដ្ឋាភិបាលមូលដ្ឋាន ។ ក្នុងរយៈពេល៣០ឆ្នាំក្រោយមក ច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៧៤ ឆ្នាំ១៩៩២បានចូលជាធរមាន ដោយផ្តល់អំណាចកាន់តែច្រើនដល់ថ្នាក់មូលដ្ឋាន។

ប្រទេសឥណ្ឌូនេស៊ី ៖ រដ្ឋាភិបាលមូលដ្ឋាន ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៤៥។

ប្រទេសជប៉ុន ៖ នៅក្នុងរបាយការណ៍នេះ ប្រទេសជប៉ុនមានលក្ខណៈខុសគ្នាពីប្រទេសដទៃទៀតជាច្រើន ។ រដ្ឋាភិបាលមូលដ្ឋាន មានការទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ដែលធានានូវស្វ័យភាពមូលដ្ឋាន ហើយកំពុងឋិតក្នុងរលកកំណែទម្រង់លើកទី៣ ដែលពាក់ព័ន្ធនឹងការផ្ទេរអំណាច ពីថ្នាក់តំបន់ចុះទៅថ្នាក់ក្រោម។ ការធ្វើប្រជាធិបតេយ្យនីយកម្ម បានក្លាយជាបញ្ហាអាទិភាព

ចាប់ពីចប់សង្គ្រាម ។ រដ្ឋធម្មនុញ្ញថ្មី ដែលត្រូវបានប្រកាសឱ្យប្រើជាផ្លូវការ នៅខែវិច្ឆិកា ឆ្នាំ១៩៤៦ បានចាត់ទុកស្វ័យភិបាលមូលដ្ឋានថាជាប្រព័ន្ធមួយ ដែលជាទំព័រមួយថ្មី ពិសេសសម្រាប់អ្នកមូលដ្ឋាន ។ ច្បាប់ស្វ័យភាពមូលដ្ឋានដែលបន្តជំរុញសន្ទុះកំណែទម្រង់ទាំងអស់នេះ ត្រូវបានអនុម័ត និងចូលជាធរមានស្របគ្នានឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ។ ហេតុដូច្នេះ ការបង្កើតប្រព័ន្ធស្វ័យភិបាលមូលដ្ឋានសព្វថ្ងៃនេះ គឺជាទម្រង់ចុងក្រោយមួយ។

ប្រទេសតីហ្ស៊ីស្ថាន ៖ ក្រោយពីការបំបែកខ្លួនចេញពីសហភាពសូវៀតមក រដ្ឋាភិបាលបានសម្រេចចិត្តថា សាធារណរដ្ឋនេះនឹងប្រកាន់យករបបប្រជាធិបតេយ្យ ។ ក្នុងពេលដំណើរការដំបូងប្រទេសនេះ បានផ្ដោតការចាប់អារម្មណ៍ទៅលើការកសាងស្ថាប័នជាតិ ហើយរដ្ឋាភិបាលសព្វថ្ងៃនេះ កំពុងតែយកចិត្តទុកដាក់ចំពោះការស្វ័យគ្រប់គ្រងមូលដ្ឋាន។ ប្រធានាធិបតីបានធ្វើការបញ្ជាក់អះអាងយ៉ាងច្បាស់ថា ស្វ័យគ្រប់គ្រងមូលដ្ឋាន គឺជាចំណុចស្នូល នៃលទ្ធិប្រជាធិបតេយ្យ ពោលគឺ គេចាំបាច់ត្រូវធានា និងរក្សាតម្លៃមនុស្សជាតិ។ ដើម្បីរក្សាតម្លៃនេះបាន យើងចាំបាច់ត្រូវធ្វើការក្នុងនាមជាប្រទេសមួយ ហើយមានផ្លូវតែមួយគត់ ដើម្បីឈានឱ្យដល់គោលដៅ គឺតាមរយៈស្ថាប័នស្វ័យភិបាលមូលដ្ឋាននេះឯង ។

ប្រទេសម៉ាឡេស៊ី ៖ ទោះបីទទួលមរតកខ្លាំងក្លាពីប្រទេសអង់គ្លេសក៏ដោយ ក៏ប៉ុន្តែជាច្រើនឆ្នាំក្រោយមកអាជ្ញាធររដ្ឋាភិបាលមូលដ្ឋានបានក្លាយជាប្រព័ន្ធមួយ ដែលមានអត្តសញ្ញាណ លក្ខណៈ និងច្បាប់ផ្ទាល់របស់ខ្លួន ដែលឆ្លុះបញ្ចាំងពីបរិស្ថានសង្គម សេដ្ឋ

កិច្ច និងនយោបាយ ។ រដ្ឋាភិបាលមូលដ្ឋាន បានពើបប្រទះនូវផ្ទាំងដ៏សែនចលាចល ក្រោយពីបានទទួលឯករាជ្យ ម៉ាឡេស៊ីត្រូវបានដាក់ក្នុងបញ្ជីជារដ្ឋចលាចល ហើយនៅផ្ទាំបន្តបន្ទាប់ នៃការកើតមានការប្រឈមមុខជាមួយប្រទេសឥណ្ឌូនេស៊ី ហើយម៉ាឡេស៊ីក៏បានធ្វើការពន្យាពេលនៃការបោះឆ្នោត ។

ប្រទេសញូហ្ស៊ីឡេន ៖ សេចក្តីថ្លែងអំពីគោលនយោបាយរបស់រដ្ឋាភិបាល មានគោលការណ៍ចម្បង និងកំណត់ច្បាស់ថា រដ្ឋាភិបាលមូលដ្ឋានត្រូវបានជ្រើសតាំងឡើង ដើម្បីឱ្យទទួលខុសត្រូវ ឬរ៉ាប់រងមុខងារណា ដែលការពារផលប្រយោជន៍រួម ជាជាងប្រយោជន៍ នៃការរៀបចំស្ថាប័នផ្សេងទៀត ។ គោលការណ៍បែងចែកអំណាចទទួលខុសត្រូវ (Subsidiary Principles) ត្រូវតែយកមកអនុវត្ត រួមទាំងការបែងចែកមុខងារដោយផ្អែកលើក្រុមផលប្រយោជន៍ សមស្រប ភាពស័ក្តិសិទ្ធិនៃប្រតិបត្តិការ ដែលត្រូវសម្រេចឱ្យបាននូវកម្មវត្ថុច្បាស់លាស់ដោយគ្មានទំនាស់ បែងចែកការងារតាមគោលដៅជាក់ស្តែងឱ្យបានច្បាស់លាស់ មានតម្លាភាព និងមានយន្តការគណនេយ្យភាពត្រឹមត្រូវ ។

ប្រទេសប៉ាគីស្ថាន ៖ មានការរិះគន់ច្រើនថា រដ្ឋាភិបាលមូលដ្ឋាន ត្រូវបិតក្នុងកណ្តាប់ដៃរបបយោធាតឹងរឹង គឺមិនបិតនៅក្រោមរបបប្រជាធិបតេយ្យ តាមការបោះឆ្នោតទេ។

ប្រទេសហ្វីលីពីន៖ ការវិវឌ្ឍន៍ឈានទៅរកការធ្វើវិមជ្ឈការនីយកម្ម និងការផ្ទេរអំណាច គឺដើម្បីឆ្លើយតបទៅនឹងសម្រែកទាមទាស្វ័យគ្រប់គ្រង។ មាត្រា១០ នៃរដ្ឋធម្មនុញ្ញ ចែងកំណត់ច្បាស់

ថា សភាត្រូវតែអនុម័តក្រមសម្រាប់គ្រប់គ្រងរដ្ឋាភិបាលមូលដ្ឋាន ដែលធ្វើឱ្យរដ្ឋាភិបាលមូលដ្ឋាន មានរចនាសម្ព័ន្ធ មានលក្ខណៈកាន់តែមានការទទួលខុសត្រូវ និងគណនេយ្យភាព ដែលបង្កើតឡើងតាមរយៈប្រព័ន្ធវិមជ្ឈការ ដោយមានយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការកោះហៅ ការផ្តួចផ្តើមគំនិត និងការធ្វើប្រជាមតិ បែងចែកអំណាច ការទទួលខុសត្រូវ និងធនធាននានា ឱ្យដល់អង្គភាពរដ្ឋាភិបាលមូលដ្ឋាននានា និងចែងអំពីបញ្ហាដែលទាក់ទងនឹងការរៀបចំអង្គការ និងកិច្ចប្រតិបត្តិការរបស់អង្គភាពមូលដ្ឋាន ។

សាធារណរដ្ឋកូរ៉េ ៖ អស់រយៈពេលជិត៥០ឆ្នាំ មុនពេលមានការសន្យាផ្តល់ស្វ័យភាពមូលដ្ឋានឱ្យមានការបោះឆ្នោតពេញលេញនៅឆ្នាំ១៩៩៥ ដើម្បីជ្រើសរើសសមាជិកក្រុមប្រឹក្សា និងនាយកប្រតិបត្តិរបស់ក្រុមប្រឹក្សាមូលដ្ឋាន ។

ប្រទេសស្រីលង្កា ៖ រដ្ឋាភិបាលមូលដ្ឋាន បានបន្តទទួលឥទ្ធិពលពីរបតករបបគ្រប់គ្រងអាណានិគមអង់គ្លេសរហូតដល់ឆ្នាំ១៩៨០។ ដោយសារតែមានគោលបំណងដ៏ធំធេង ប្រទេសនេះបានចាប់ផ្តើមធ្វើវិមជ្ឈការ ចាប់ពីឆ្នាំ១៩៨៧ ។ ការរៀបចំលំដាប់ថ្នាក់អាជ្ញាធរមូលដ្ឋាន មិនមានការអនុវត្តជាទូទៅទេ។ ផ្ទុយទៅវិញ អាជ្ញាធរមូលដ្ឋាន ត្រូវបានលើកកម្ពស់ជាប្រចាំ ឬត្រូវបានធ្វើបច្ចុប្បន្នភាព។

ប្រទេសថៃឡង់ដ៏ ៖ ប្រទេសនេះ មិនស្ថិតនៅក្រោមអំណាចអាណានិគមណាមួយទេ។ ប៉ុន្តែប្រទេសនេះ បានស្ថិតនៅក្រោម

របបកជានិយមដាច់ខាត (ផ្តាច់ការ) ។ ចាប់តាំងពីពេលនោះមក អស់ពេលជិត៧០ឆ្នាំ ប្រជាពលរដ្ឋថៃបានតស៊ូទាមទារឱ្យមានរដ្ឋធម្មនុញ្ញមួយ ដែលគេអាចទទួលយកបាន។ សព្វថ្ងៃប្រជាពលរដ្ឋថៃមានសេចក្តីសង្ឃឹមយ៉ាងខ្លាំងថា ការតស៊ូទាមទារនឹងទទួលបានជោគជ័យលើកទី១៦ ។

## II. បញ្ហាស្វ័យគ្រប់គ្រងមូលដ្ឋាន

ផ្នែកនេះ ពិភាក្សាអំពីបញ្ហាស្វ័យគ្រប់គ្រងមូលដ្ឋានដែលមានការទទួលខុសត្រូវកាន់តែខ្ពស់។ បញ្ហាទាំងឡាយត្រូវបានក្តោបនៅក្នុងចំណុចធំៗចំនួន៣ គឺការរៀបចំរចនាសម្ព័ន្ធ និងស្ថាប័នអភិបាលកិច្ចមូលដ្ឋាន និងសមត្ថភាពរបស់មូលដ្ឋាន។

ដើម្បីឱ្យងាយយល់ក្នុងរឿងនេះ យើងនឹងបំបែកទៅជាផ្នែកតូចៗទៀត គឺចង់លើកឡើងអំពីបញ្ហានានា តាមរយៈរបាយការណ៍របស់ប្រទេសនីមួយៗ ដោយពិភាក្សាចំណុចនានា ដែលមានលើកឡើងនៅក្នុងរបាយការណ៍។

### ក-ការរៀបចំរចនាសម្ព័ន្ធ និងស្ថាប័ន

បញ្ហាហិរញ្ញវត្ថុ រដ្ឋបាល លិខិតបទដ្ឋានគតិយុត្ត និងទំនាក់ទំនងរវាងរដ្ឋាភិបាលថ្នាក់ជាតិ ជាមួយនឹងថ្នាក់មូលដ្ឋាន សំដៅកំណត់ក្របខ័ណ្ឌរចនាសម្ព័ន្ធនិងស្ថាប័នសម្រាប់ដំណើរការស្វ័យគ្រប់គ្រងមូលដ្ឋាន ។ បញ្ហាទាំងអស់នេះ ក៏អាចជួយសម្រួលកិច្ចប្រតិបត្តិការ ឬអាចបង្កឧបសគ្គក៏សឹងមាន។ នៅក្នុងន័យនេះយើងនឹងពិចារណាបញ្ហាទាំងអស់នេះ មួយចំណុចម្តងៗ នៅក្នុងរបាយការណ៍របស់ប្រទេសនីមួយៗ ។

**ខ-ហិរញ្ញវត្ថុ**

សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ គឺជាបញ្ហាសំខាន់សម្រាប់ស្វ័យគ្រប់គ្រងមូលដ្ឋាន។ ក្នុងចំណោមបណ្តាប្រទេសនានា ដែលយើងបានលើកយកមកនិយាយ ប្រទេសញូហ្ស៊ីឡែន មានបញ្ញត្តិស័ព្ទស្ទើរតែត្រឹមត្រូវបំផុត នៅក្នុងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុថ្មីរបស់ខ្លួន។ ចំពោះប្រទេសផ្សេងទៀត គឺមានការពឹងផ្អែកកម្រិតខុសៗគ្នា ទៅលើវិភាជន៍ពីថ្នាក់កណ្តាល និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ។

ចំពោះបណ្តាប្រទេសមួយចំនួន មិនមានប្រភពហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីផ្តល់ជូនសង្គមរបស់ខ្លួន ឱ្យលើសពីតម្រូវការមូលដ្ឋានទាបបំផុតទេ។

ឧទាហរណ៍ការចំណាយរបស់រដ្ឋាភិបាលមូលដ្ឋានប្រទេសហ្វីជី ត្រូវបានធ្វើដោយផ្អែកលើមូលដ្ឋានមូលនិធិតិចតួចដែលមានសម្រាប់ការងារថ្មី ឬការសាងសង់សំខាន់ៗ។ ធនធានហិរញ្ញវត្ថុបច្ចុប្បន្ន ហាក់ដូចជាបានត្រឹមតែរក្សាឱ្យប្រព័ន្ធនេះរស់ប៉ុណ្ណោះ។ នៅប្រទេសបង់ក្លាដេសវិញ រដ្ឋាភិបាលមូលដ្ឋាន អាចមានអំណាចធ្វើការសម្រេចនៅថ្នាក់មូលដ្ឋានបាន តែរដ្ឋាភិបាលមូលដ្ឋាន មិនមានប្រភពធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ទេ។ ដូចគ្នានេះដែរ រដ្ឋាភិបាលមូលដ្ឋានប្រទេសហ្វីលីពីន មានស្វ័យភាពខាងផ្នែករដ្ឋបាលយ៉ាងច្រើនប៉ុន្តែរដ្ឋាភិបាលកណ្តាលនៅតែកាន់"ខ្សែញាក់" ដដែល។ រដ្ឋាភិបាលកណ្តាល អាចធ្វើប្រតិភូកម្មបានច្រើន តាមដែលគេចង់ប៉ុន្តែវាហាក់ដូចជាគ្មានន័យទេ បើគេមិនមានប្រភពធនធានហិរញ្ញ

វត្ថុសមស្រប ។ រដ្ឋាភិបាលមូលដ្ឋានរបស់ប្រទេសម៉ាឡេស៊ី បើនិយាយក្នុងន័យម្យ៉ាង គឺមានអំណាចឆន្ទានុសិទ្ធិច្រើន ប៉ុន្តែអាចនិយាយម្យ៉ាងទៀតថា វាគ្រាន់តែជាសំនួនពេហាទេ ពីព្រោះការពិត រដ្ឋាភិបាលមូលដ្ឋានមិនមានមូលនិធិគ្រប់គ្រាន់ ដើម្បីធ្វើអ្វីមួយបានទេ សូម្បីតែខ្លួនមានអំណាចឆន្ទានុសិទ្ធិក៏ដោយ។ នៅថ្នាក់មូលដ្ឋាន នៅប្រទេសឥណ្ឌូនេស៊ី ចំនួនសមាមាត្រាចំណាយសម្រាប់ការអភិវឌ្ឍ ឬការងារថែទាំទីក្រុងត្រូវការថវិកាកាន់តែច្រើនឡើង ប៉ុន្តែចំណាយលើការងាររៀបចំទីក្រុង ក្រៅពីការងារថែទាំអាចជាការបំភាន់មួយ។ ជាញឹកញាប់ណាស់ វាគ្រាន់តែជាការបំប៉ោងខាងផ្នែកនយោបាយ ឱ្យមានភាពអស្ចារ្យ នៅពេលដែលអ្នកនយោបាយនៅមូលដ្ឋាន គ្រាន់តែកសាងវិមាន បង្ហាញមុខមាត់សម័យកាលកាន់តំណែង ការិយាល័យសាធារណៈច្រើនជាងការរ៉ាប់រងការងារសំខាន់ៗ។ លទ្ធផលចុងក្រោយ គឺហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ត្រូវខូចខ្ទេចខ្ទីអស់ រហូតដល់ទាមទារឱ្យមានការសាងសង់ថ្មីឡើងវិញ។

បណ្ដាប្រទេសមួយចំនួនទៀត ថ្វីបើមានមូលនិធិមិនច្រើនក៏ដោយ ក៏អាចធ្វើការផ្ដល់សេវាកម្រិតខ្ពស់បាន ។ ក្រុមប្រឹក្សាអូស្ត្រាលី កំពុងបោះជំហានចេញពីសម័យកសាងដំបូង ក្នុងការផ្ដល់នូវហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដូចជាមធ្យោបាយដឹកជញ្ជូន ប្រព័ន្ធលូ ទឹក និងអគ្គិសនី ដើម្បីឈានទៅផ្ដល់សេវាកម្រិតខ្ពស់ជាងមុន ឧទាហរណ៍ការផ្ដល់សេវា សិល្បៈ និងវប្បធម៌ ការរៀបចំទីធ្លាក់សាន្តជាដើម។ លទ្ធភាពក្នុងការផ្ដល់សេវាកម្រិតខ្ពស់នេះ

ត្រូវផ្តល់ឱ្យស្របតាមតម្រូវការ ដោយមានភាពបត់បែនកាន់តែខ្លាំង និងស្របតាមឆន្ទានុសិទ្ធិក្នុងការជ្រើសរើស សេវាអ្វីដែលត្រូវផ្តល់ជូន។ នៅប្រទេសញូហ្ស៊ីឡែន និងអូស្ត្រាលីក៏បានផ្តល់សេវាស្របទៅតាមតម្រូវការកម្រិតខ្ពស់ជាងមុន ដោយមានគណនេយ្យភាពជាមួយចំណូល និងចំណាយ ។ ប្រទេសញូហ្ស៊ីឡែន ផ្តល់នូវគំរូអនុវត្តសំខាន់ៗ ដែលមានធាតុផ្សំបួននៃរបបថ្មី គឺ

១-គណនេយ្យភាព

២-គោលការណ៍ណែនាំប្រតិបត្តិការ

៣-ការទទួលខុសត្រូវចំពោះលទ្ធផល និង

៤-ការប្រុងប្រយ័ត្ន។

ធាតុផ្សំមួយក្នុងចំណោមធាតុផ្សំសំខាន់ៗ គឺថារដ្ឋាភិបាលមូលដ្ឋាន ត្រូវតែពន្យល់ប្រាប់សាធារណជន អំពីមូលហេតុអ្វីដែលគេត្រូវការចំណាយ។ ជាមួយនឹងស្វ័យភាព ក៏ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពកាន់តែធំ ហើយរដ្ឋាភិបាលមូលដ្ឋានមួយចំនួន មិនចង់ឱ្យមានការទទួលខុសត្រូវ និងគណនេយ្យភាពនោះទេដោយចង់ទុកឱ្យរដ្ឋាភិបាលថ្នាក់លើជាអ្នកទទួលខុសត្រូវវិញ។ ការចូលរួមរបស់រដ្ឋាភិបាលកណ្តាលក្នុងការប្រមូល និងបែងចែកចំណាយទៅវិញ មានលក្ខណៈខុសៗពីគ្នា ពោលគឺស្របទៅតាមហេតុផលដោយឡែកៗពីគ្នា។ នៅប្រទេសចិនរដ្ឋាភិបាលកណ្តាល ធ្វើការពង្រីកសមត្ថភាពហិរញ្ញវត្ថុរបស់អាជ្ញាធរមូលដ្ឋាន របាយការណ៍របស់ប្រទេសនេះ សឱ្យឃើញថា ការនេះធ្វើឱ្យកើនមូលនិធិថ្នាក់កណ្តាល ប្រហែលជាដោយហេតុតែមូលនិធិមូល

ដ្ឋានដែលកើនឡើង ធ្វើឱ្យបាត់បង់បរិមាណមូលនិធិរបស់ថ្នាក់កណ្ដាលដែលត្រូវធ្វើការបែងចែក។ទោះបីគេមានសមត្ថភាពកើនឡើងបែបនេះក៏ដោយ ក៏ថវិការបស់ពួកគេនៅតែត្រូវការការឯកភាពយល់ព្រមពីរដ្ឋាភិបាលថ្នាក់ខ្ពស់ជាងដដែល ។ បទពិសោធន៍ប្រទេសឥណ្ឌូនេស៊ីបានលើកឡើងថា រដ្ឋាភិបាលកណ្ដាលគួរតែប្រមូលពន្ធទាំងឡាយណា ដែលមានភាពងាយស្រួលបំផុតដោយទុកឱ្យរដ្ឋាភិបាលមូលដ្ឋាន ប្រមូលពន្ធដែលពិបាកបំផុត។

នៅប្រទេសជប៉ុន មានទំនាក់ទំនងច្រាស់មួយដ៏គួរឱ្យចាប់អារម្មណ៍រវាងការប្រមូលចំណូលនិងចំណាយ។ ការប្រមូលចំណូលពន្ធ គឺប្រើរូបមន្ត ២:១ ដើម្បីគាំទ្រដល់រដ្ឋាភិបាលកណ្ដាល ប៉ុន្តែតាមរយៈការផ្ទេរសារពើពន្ធចំណាយ គឺមានលក្ខណៈច្រាស់មកវិញ គឺ២:១ ដើម្បីជាប្រយោជន៍សម្រាប់រដ្ឋាភិបាលមូលដ្ឋាន។ ការបែងចែកចំណូលតែមួយបែបនេះ គឺកើតចេញពីជំនឿយ៉ាងមុតមាំថា រដ្ឋាភិបាលមូលដ្ឋាន គឺជាចំណុចស្នូលនៃលទ្ធិប្រជាធិបតេយ្យ ហើយដោយសារជាកម្រិត រដ្ឋាភិបាលដែលនៅកិតជិតនឹងប្រជាពលរដ្ឋបំផុតនោះ រដ្ឋាភិបាលនេះ គួរតែមានចំណែកនៃចំណូលធំជាង ដើម្បីបំពេញតម្រូវការរបស់ខ្លួន។

ពន្ធនៅថ្នាក់មូលដ្ឋាន ត្រូវចែកចេញជាពីរប្រភេទ គឺពន្ធថ្នាក់ខេត្តដែលមានពន្ធលំនៅដ្ឋាន និងពន្ធរថយន្តនៅក្នុងខេត្ត និងពន្ធថ្នាក់ក្រុងដែលមានពន្ធធ្វើផែនការក្រុងនិងពន្ធលំនៅដ្ឋានក្នុងក្រុង ក្រៅពីពន្ធទាំងអស់ ដែលរដ្ឋាភិបាលមូលដ្ឋានប្រមូលផ្ទាល់ រដ្ឋាភិបាលមូលដ្ឋាននៅប្រទេសជប៉ុនមានសិទ្ធិទទួលបានចំណែកចំនួន

៣២ភាគរយនៃចំណូល ដែលបានពីពន្ធលើប្រាក់ចំណូលថ្នាក់ជាតិ ពន្ធសាជីវកម្ម និងពន្ធស្រា២៥ភាគរយបានពីពន្ធលើការប្រើប្រាស់ និង២៥ភាគរយ បានពីពន្ធបារី ។ ការធ្វើវិភាជន៍ទាំងអស់នេះ ត្រូវគិតទៅតាមប្រភពចំណូលឯករាជ្យ និងចំណូលដែលមានការធានាសម្រាប់រដ្ឋាភិបាលមូលដ្ឋាន ហើយគេមិនត្រូវដាក់កម្រិតទៅលើការប្រើប្រាស់របស់ពួកគេទេ។ ជាងនេះទៅទៀត ក្នុងករណីមានគ្រោះអាសន្ន ឬគ្រោះធម្មជាតិនានា ក្រសួងហិរញ្ញវត្ថុក៏ធ្វើការឧបត្ថម្ភធន តាមរយៈក្រសួងកិច្ចការផ្ទៃប្រទេស ។ ប្រភពចំណូលឯករាជ្យ មានស្ថិរភាពស្របតាមទំហំ អាចឱ្យរដ្ឋាភិបាលមូលដ្ឋានរបស់ជប៉ុន ធ្វើផែនការគម្រោងសម្រាប់រយៈពេលវែង និងបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋខ្លួនបាន។

**ប្រអប់ទី២៖ប្រភពចំណូលសំខាន់ៗរបស់រដ្ឋាភិបាលមូលដ្ឋាន**

ប្រទេសអូស្ត្រាលី ៖ ថវិកាជំនួយ និងថវិកាសម្រាប់គោលបំណងទូទៅ ឬពិសេសដែលផ្តល់ដោយ Commonwealth និងរដ្ឋាភិបាលរដ្ឋ មានចំនួនរហូតដល់២៣% នៃចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន។ ប្រភពផ្សេងៗទៀត រួមមានពន្ធលើអចលនទ្រព្យប្រាក់ឈ្នួលនិងប្រាក់ពិន័យ អតិរេកសរុបដែលបានពីសហគ្រាសពាណិជ្ជកម្ម និងការប្រាក់។

ប្រទេសបង់ក្លាដេស៖ពន្ធអាករប្រាក់ឈ្នួល និងកម្រៃដែលអង្គភាពមូលដ្ឋានប្រមូលបាន មានការជួល និងប្រាក់ចំណេញដែលបានមកពីទ្រព្យសម្បត្តិរបស់អង្គភាពមូលដ្ឋាន និងថវិកាសរុបដែលបានពីកម្រៃសេវារបស់ខ្លួន ។ អំណោយនិងកំចីរដ្ឋាភិបាល

ដែលអង្គភាពមូលដ្ឋាន អាចរកបាននិងការផ្ដល់មូលនិធិពីគម្រោងអន្តរជាតិគឺជាប្រភពចំណូលបន្ថែម ។ ពន្ធលើដីលំនៅដ្ឋាន គឺជាប្រភពចំណូលដ៏សំខាន់បំផុត នៅពេលប្រាក់កំចី និងការរួមវិភាគទានដោយស្ម័គ្រចិត្តមានកម្រិតស្ដួចស្ដើង។

ប្រទេសចិន៖ ពន្ធនៅមូលដ្ឋាន (ឧទាហរណ៍ពន្ធលើប្រាក់ចំណូលស្លាកអាជ្ញាប័ណ្ណនិងដីលំនៅដ្ឋាន) ពន្ធរំលែក (ឧទាហរណ៍ពន្ធលើផលិតផល-អគារ និងប្រាក់ចំណូល) និងចំណូលមិនមែនពន្ធ (ឧទាហរណ៍ចំណូល បានពីអាជ្ញាប័ណ្ណនិងឥណទាន ទ្រព្យសម្បត្តិ និងកូតាកំណត់)។

ប្រទេសហ្វីជី៖ ចំណូលដែលបានមកពីពន្ធលើដីធ្លី (អាករតាមឃុំ/សង្កាត់) និងចំណូលនៅមូលដ្ឋានផ្សេងៗទៀត ដូចជាអំណោយតាមទីកន្លែង ប្រាក់ឈ្នួល ភាស៊ីផ្សារ និងស្ថានីយ៍រថយន្តក្រុង កម្រៃអាជ្ញាប័ណ្ណធុរកិច្ច ប្រាក់ជួលអគារ និងកន្លែងចំណតជាដើម។ ក្រៅពីនេះ ក្រុមប្រឹក្សាភាគច្រើនបំផុតស្វែងរកកំចីពីផ្សារទុនមូលដ្ឋាន។អំណោយហិរញ្ញវត្ថុ ដែលបានពីរដ្ឋាភិបាលកណ្ដាលមានលក្ខណៈស្ដួចស្ដើងណាស់។

ប្រទេសឥណ្ឌា៖ ចំណូលបានពីពន្ធ (ដូចជាទ្រព្យសម្បត្តិពន្ធវិជ្ជាជីវៈ និងយានយន្ត)ចំណូលមិនមែនពន្ធ (ការចេញអាជ្ញាប័ណ្ណនិងការផ្ដល់សេវាផ្សេងៗ) ជំនួយជាអំណោយ និងការខ្ចី ឬកំចីពីរដ្ឋាភិបាលកណ្ដាល។

ប្រទេសឥណ្ឌូនេស៊ី៖ចំណូលពីពន្ធនៅមូលដ្ឋាន(ឧទាហរណ៍ពន្ធលើទ្រព្យសម្បត្តិ វិក្កយបត្រសណ្ឋាគារ និងភោជនីយដ្ឋាន និង

កន្លែងកំសាន្ត) ប្រាក់ឈ្នួល និងកម្រៃសេវាដែលត្រូវផ្តល់(ការផ្តល់វិភាគទានធំបំផុត សម្រាប់ជាចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន) ចំណូល(ប្រាក់ចំណេញ) ពីសហគ្រាសដែលជាកម្មសិទ្ធិរបស់រដ្ឋាភិបាលមូលដ្ឋាន ជំនួយបរទេសនិងមូលនិធិដែលបានពីរដ្ឋាភិបាលថ្នាក់ខ្ពស់។

ប្រទេសជប៉ុន៖ ពន្ធនៅមូលដ្ឋាន (ឧទាហរណ៍ពន្ធលើសហគ្រាស ទ្រព្យសម្បត្តិ និងរថយន្ត) ពន្ធវិភាជន៍នៅមូលដ្ឋាន (ជួយរក្សាសមតុល្យ ចំណូលរដ្ឋាភិបាលមូលដ្ឋាន និងធានាកម្រិតស្តង់ដារក្នុងការផ្តល់សេវា) ថវិកាផ្តល់តាមរយៈរតនាគារជាតិ ឬជំនួយជាអំណោយ និងកំចីរបស់រដ្ឋាភិបាលមូលដ្ឋាន។

ប្រទេសគីហ្សីស្ថាន ៖ ចំណូលឥណទាន និងថវិកាឧបត្ថម្ភពន្ធនៅមូលដ្ឋាន ប្រាក់ឈ្នួល និងកម្រៃ ព្រមទាំងមានចំណូលផ្សេងៗទៀត។ ពន្ធនៅមូលដ្ឋានសំខាន់ គឺពន្ធដីធ្លី។ ពន្ធដទៃទៀតរួមមានពន្ធសណ្ឋាគារ មណ្ឌលសុខភាពនិងពន្ធលក់ពាយនិងពន្ធ លើក្រុមហ៊ុនផ្តល់សេវាឯកជននានា។

ប្រទេសញូហ្ស៊ីឡែន៖ ប្រភពចំណូលគឺមានអាករលើទ្រព្យសម្បត្តិ កម្រៃដែលបានពីអ្នកប្រើប្រាស់ ប្រាក់ឈ្នួល ជំនួយហិរញ្ញវត្ថុមួយចំនួនពីរដ្ឋាភិបាលកណ្តាល ពន្ធលើប្រេងសាំង និងចំណូលពីវិនិយោគ។ អំណាចក្នុងការកំណត់អាករ និងកម្រៃនានាត្រូវបានចែងកំណត់ច្បាស់នៅក្នុងច្បាប់តាំងពីឆ្នាំ១៩៨៨និងនៅតែជាប្រភពដ៏សំខាន់នៃចំណូល ពន្ធមូលដ្ឋានសម្រាប់រដ្ឋាភិបាលមូលដ្ឋាន។

ប្រទេសម៉ាឡេស៊ី ៖ ថ្លៃឈ្នួល និងកម្រៃសេវាជំនួយការ

ឧបត្ថម្ភដែលផ្ដល់ដោយរដ្ឋ ឬរដ្ឋាភិបាលកណ្ដាល និងការប្រមូលពន្ធនៅមូលដ្ឋាន (ការកំណត់អត្រា)។ ជាងនេះទៅទៀត អាជ្ញាធរមូលដ្ឋានមួយចំនួន បានទទួលថវិកាជាអត្រាកំណត់តាមទីកន្លែងប្រភពផ្សេងៗទៀត អាចមានជាទម្រង់ចំណូលផ្សេងៗដូចជាប្រាក់ឈ្នួលនិងកម្រៃនានាដែលបានពីអាជ្ញាប័ណ្ណថ្លៃលក់ទម្រង់(ពាក្យសុំ)នានាក្នុងការប្រើសេវា ការដាក់ពិន័យលើការជួល និងការជួលបរិវេណ និងការប្រាក់។

ប្រទេសប៉ាគីស្ថាន៖ ពន្ធនិងពន្ធនៅមូលដ្ឋាន(ដែលរួមមានចំណូលសម្រាប់រដ្ឋាភិបាលមូលដ្ឋានចំនួន៦០%) និងប្រភពមិនមែនពន្ធ ។ ពន្ធដែលទាក់ទងនឹងទ្រព្យសម្បត្តិ (ដូចជាអាករនៅមូលដ្ឋាន ឬការជួលដីធ្លីដែលគេអាចប៉ាន់ស្មានបានជាប្រាក់ឈ្នួលចំណូលពីដី ឬចំណូលពីការប្រើប្រាស់ដី) ពន្ធលើការផ្ទេរកម្មសិទ្ធិ និងពន្ធនៅមូលដ្ឋាន គឺជាប្រភពចំណូលដ៏ធំបំផុត។

ប្រទេសហ្វីលីពីន ៖ ការបែងចែកចំណូលផ្ទៃក្នុង តាមរយៈការប្រមូលពន្ធនៅមូលដ្ឋាន ចំណែករបស់រដ្ឋាភិបាលមូលដ្ឋានដែលទទួលបានការបែងចែកធនធានពីថ្នាក់ជាតិ ចំណែកដែលរកបានពីមុខងារជាភ្នាក់ងាររដ្ឋ ឬសាជីវកម្មដែលរដ្ឋគ្រប់គ្រងធ្វើជាម្ចាស់ដែលទាក់ទងនឹងការប្រើប្រាស់ និងការអភិវឌ្ឍទ្រព្យសម្បត្តិជាតិ ការខ្ចី និងការចេញអាជ្ញាប័ណ្ណ ប័ណ្ណបំណុល មូលប័ត្រ និងប័ណ្ណធានារបស់រដ្ឋាភិបាលមូលដ្ឋាន។

សាធារណរដ្ឋកូរ៉េ៖ចំណូលដែលរកបានដោយខ្លួនឯង និងថវិកាពីរដ្ឋាភិបាលកណ្ដាល និងថ្នាក់លើ។ ប្រភេទចំណូលទាំងពីរ

នេះ ត្រូវបានបំបែកចេញជាថវិកា ថវិកាដែលជាចំណែក បានពីចំណូល (សំដៅដល់ការបំពេញតុល្យភាពហិរញ្ញវត្ថុ) និងពន្ធរំលែក (ឧទាហរណ៍ពន្ធលើ ស្រា ទូរស័ព្ទ និងពន្ធលើកម្មសិទ្ធិដីធ្លីដែលមានតម្លៃលើសចំនួនកំណត់ជាដើម)។

ប្រទេសស្រីលង្កា៖ អាករ ប្រាក់បន្ទុកពន្ធគយ ប្រាក់ឈ្នួល ប្រាក់ពិន័យ ប្រាក់ទណ្ឌកម្ម និងកម្រៃផ្សេងៗទៀត ព្រមទាំងថវិកាដែលបានមកពីការលក់ ការជួល ឬបានពីកិច្ចការផ្សេងៗ ចំណូលដែលបានពីទ្រព្យសម្បត្តិ និងជំនួយពីថ្នាក់រដ្ឋាភិបាលដទៃទៀត។

ប្រទេសថៃឡង់ដ៏៖ ការប្រមូលពន្ធ (ឧទាហរណ៍ពន្ធលើលំនៅដ្ឋាន និងដីធ្លី អាករបន្ថែម (VAT) លើទំនិញនិងសេវា និងពន្ធលើមុខរបរជាក់លាក់) ប្រាក់ឈ្នួល អាជ្ញាប័ណ្ណ និងប្រាក់ពិន័យ ចំណូលដែលបានពីទ្រព្យសម្បត្តិ អត្ថប្រយោជន៍សាធារណៈ និងសហគ្រាសរដ្ឋាភិបាលមូលដ្ឋាន ជំនួយ អំណោយ ការឧបត្ថម្ភពីរដ្ឋាភិបាលកណ្តាល និងកំចី។ ទន្ទឹមនឹងនេះ យោងតាមរដ្ឋធម្មនុញ្ញថ្មីនៅប្រទេសថៃ រដ្ឋាភិបាលមូលដ្ឋាន ត្រូវបានទទួល១០% នៃអាករបន្ថែម (VAT) ដែលប្រមូលដោយរដ្ឋាភិបាលកណ្តាល បន្ថែមពីលើប្រភពចំណូលដែលមាន ។ ប៉ុន្តែ ទោះជារដ្ឋធម្មនុញ្ញថ្មីនេះចែងយ៉ាងណាក៏ដោយ ក៏រចនាសម្ព័ន្ធអភិបាលកិច្ចរបស់ថៃនៅតែមានលក្ខណៈមជ្ឈការខ្លាំងក្លាដោយសាររដ្ឋាភិបាលកណ្តាលគឺជាអ្នកគ្រប់គ្រងពន្ធភាគច្រើននៅក្នុងប្រទេស និងគ្រប់គ្រងការបែងចែកជំនួយដល់រដ្ឋាភិបាលមូលដ្ឋានតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

អ្វីដែលគួរឱ្យចាប់អារម្មណ៍បំផុត គឺអង្គភាពរដ្ឋបាលរដ្ឋ

គឺហ្សីស្ថាន ការរៀបចំថវិកាផ្ដល់ទៅឱ្យក្រុមប្រឹក្សាមូលដ្ឋាន ត្រូវធ្វើការអនុម័ត ។ នៅពេលបានទទួលការអនុម័ត រដ្ឋបាលរបស់រដ្ឋត្រូវអនុវត្តថវិកា ។ ភារកិច្ចនេះ ស្នើឱ្យរដ្ឋាភិបាលថ្នាក់ខ្ពស់ ធ្វើការគ្រប់គ្រងថវិកា ដែលមានការយល់ព្រមពីកម្រិតក្រោម។

យុទ្ធសាស្ត្រពង្រឹងសមត្ថភាពហិរញ្ញវត្ថុមូលដ្ឋាន ដែលរដ្ឋមន្ត្រីក្រសួងលំនៅដ្ឋាន និងរដ្ឋាភិបាលមូលដ្ឋានម៉ាឡេស៊ី មានលក្ខណៈគួរឱ្យចាប់អារម្មណ៍ថា៖

-ការរៀបចំប្រភពចំណូលរបស់អាជ្ញាធរមូលដ្ឋានឡើងវិញ

-ស្វ័យភាពកាន់តែច្រើនឡើងក្នុងការបន្ថែមបន្ថយអត្រាពន្ធ

-ការមិនត្រួតត្រា និងការធ្វើឯកជនភាវូបនីយកម្ម

-ការបង្កើនការគាំទ្រពីរដ្ឋ និងសហព័ន្ធ

-ការគាំទ្រ និងការចូលរួមពីសហគមន៍កាន់តែច្រើនឡើង។

ប្រភពចំណូល នឹងត្រូវពិភាក្សាលម្អិតថែមទៀតនៅពេលក្រោយក្នុងជំពូកនេះ។ បើពិភាក្សាឱ្យគ្រប់ជ្រុងជ្រោយនៅទីនេះ យើងអាចនិយាយបានថា ចំណុចខ្សោយជាមូលដ្ឋាននៅក្នុងប្រព័ន្ធទាំងអស់នេះ គឺចំណូលមូលដ្ឋាន ត្រូវពឹងផ្អែកទៅលើការផ្ទេរសោរពើពន្ធតាមទម្រង់មួយចំនួនខាងលើ។ ការពឹងផ្អែកបែបនេះ តែងតែជួបប្រទះភាពមិនទៀងទាត់ពីរដ្ឋាភិបាលកណ្ដាល។ លទ្ធភាពនៃការប្រមូលពន្ធមូលដ្ឋាននឹងត្រូវបង្កើនប្រសិទ្ធភាពស្វ័យាភិបាលមូលដ្ឋាន ប៉ុន្តែបទប្បញ្ញត្តិច្បាប់បច្ចុប្បន្ន មានលក្ខណៈមិនច្បាស់លាស់។ ទម្រង់ចំណូលមួយ ក្នុងចំណោមទម្រង់ទូទៅបំផុត គឺជាពន្ធលើទ្រព្យសម្បត្តិនៅមូលដ្ឋាន។

ឧបសគ្គមួយ ក្នុងចំណោមឧបសគ្គនានា គឺការពឹងផ្អែកលើលទ្ធភាពរបស់ម្ចាស់ទ្រព្យសម្បត្តិនៅមូលដ្ឋាន ដែលត្រូវបង់ពន្ធ ហើយបទពិសោធន៍របស់ប្រទេសហ្វីជី បានបង្ហាញច្បាស់អំពីការលំបាកបែបនេះ ។ ឧបសគ្គមួយទៀត ដូចជាករណីនៅប្រទេសអូស្ត្រាលី សឱ្យឃើញស្រាប់ អំពីការជ្រៀតជ្រែកពីរដ្ឋាភិបាលកណ្ដាលតាមរយៈការរាំងខ្ទប់ ឬការកម្រិតកំណើនប្រចាំឆ្នាំចំពោះពន្ធលើទ្រព្យសម្បត្តិ ដែលគេអាចអនុវត្តបាន។ ជម្រើសផ្សេងទៀត ដូចជាពន្ធ អាករបន្ថែម (VAT) (និង GST បច្ចុប្បន្ននៅអូស្ត្រាលី) អាចមានលក្ខណៈគួរឱ្យទុកចិត្តច្រើនឡើង។ រឿងទាំងអស់នេះនឹងត្រូវបកស្រាយនៅពេលក្រោយ។

**គ-អំពីរដ្ឋបាល**

កំណែទម្រង់រដ្ឋបាល ត្រូវបានធ្វើទូទៅនៅក្នុងតំបន់។ ការធ្វើកំណែទម្រង់នេះ គឺសំដៅរកមធ្យោបាយ ធ្វើឱ្យប្រសើរឡើងនូវភាពស័ក្ដិសិទ្ធិ និងប្រសិទ្ធភាពរបស់អាជ្ញាធរមូលដ្ឋានដែលជាយន្តការក្នុងការផ្ដល់សេវា ។ កំណែទម្រង់មានបីប្រភេទ ដែលមាននៅក្នុងរបាយការណ៍ប្រចាំប្រទេស ពោលគឺ ការបែងចែកការទទួលខុសត្រូវផ្នែករដ្ឋបាល ក្នុងការចែករំលែកអំណាច និងការធ្វើសមាហរណកម្ម ក្នុងការផ្ដល់សេវាជូនប្រជាពលរដ្ឋ។

ការធ្វើកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ និងសហរដ្ឋបាល នៅប្រទេសឥណ្ឌូនេស៊ី គឺជាការបញ្ជាក់អំពីចលនា នៃបែងចែកក្នុងការទទួលខុសត្រូវផ្នែករដ្ឋបាល។ នៅក្នុងបរិបទប្រទេសឥណ្ឌូនេស៊ី ការធ្វើវិមជ្ឈការនីយកម្ម គឺសំដៅដល់ការផ្ទេរការទទួល

ខុសត្រូវ ពីថ្នាក់លើទៅឱ្យអង្គភាពមូលដ្ឋាន ឬខេត្ត ឬរដ្ឋាភិបាលមូលដ្ឋាន (ដែលហៅថាអង្គភាពស្វយ័តខេត្ត ឬរដ្ឋាភិបាលមូលដ្ឋាន) ហើយវិសហមជ្ឈការនីយកម្ម គឺសំដៅដល់ការធ្វើប្រតិភូកម្មមុខងាររដ្ឋបាល ពីថ្នាក់លើទៅឱ្យអង្គភាពថ្នាក់ក្រោម (ដែលហៅថាអង្គភាពរដ្ឋបាល)។ ក្នុងន័យនេះ សហរដ្ឋបាល គឺជាការចែករំលែកការទទួលខុសត្រូវ។

មានរបាយការណ៍ជាច្រើន បានពិភាក្សាអំពីការបែងចែកអំណាចរវាងក្រុមប្រឹក្សាមូលដ្ឋាន(មានផ្នែកនយោបាយ/ផ្នែកបញ្ញត្តិ) និងរដ្ឋបាលមូលដ្ឋាន(ផ្នែកប្រតិបត្តិ) ។ ការបែងចែកនេះ អាចមានទម្រង់ពីរ គឺ

១-ក្រុមប្រឹក្សាដែលកើតឡើងពីការបោះឆ្នោតដោយប្រជាពលរដ្ឋនៅមូលដ្ឋាន គឺត្រូវតែធ្វើការតែងតាំងអ្នកគ្រប់គ្រងទូទៅមួយ ដែលពាប់រងការងាររដ្ឋបាល ហើយក្រុមប្រឹក្សាត្រូវឯកភាព ដោយគ្មានការជ្រៀតជ្រែកណាមួយឡើយ (ឧទាហរណ៍ករណីអូស្ត្រាលី)

២-ស្នងការ ឬអ្នកគ្រប់គ្រងទូទៅ (ឬឋានៈស្មើ) គឺជាមន្ត្រីមុខងារសាធារណៈថ្នាក់កណ្ដាល ដែលមានការទទួលខុសត្រូវចំពោះរដ្ឋាភិបាលថ្នាក់លើ (ឧទាហរណ៍ការបែងចែកផ្នែកពិគ្រោះយោបល់សម្រេច និងផ្នែកប្រតិបត្តិរបស់អង្គភាពក្រុងនៅឥណ្ឌា)។ ប្រទេសមួយចំនួន បានធ្វើសមាហរណកម្មមន្ត្រីរាជការ តាមខ្សែបណ្ដោយ។ ប្រទេសឥណ្ឌូនេស៊ី គឺជាករណីសបញ្ជាក់ច្បាស់ អំពីការជ្រើសរើស តែងតាំង បណ្ដេញចេញ ការព្យួរ ការរៀបចំបៀវត្សសោធននិវត្តន៍ ការផ្ដល់បៀវត្សពាក់កណ្ដាល និងបញ្ហាផ្សេងៗ

ទៀត ដែលពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់របស់មន្ត្រីសាធារណៈ ថ្នាក់ខេត្ត និងមូលដ្ឋាន ស្របទៅតាមបទបញ្ជារដ្ឋបាលដែលចេញដោយក្រសួងមហាផ្ទៃ។ ការធ្វើសមាហរណកម្មខ្សែបណ្តោយអាចផ្តល់ស្ថិរភាព និងមាគ៌ាអាជីពសម្រាប់បុគ្គលិករដ្ឋាភិបាលមូលដ្ឋាន ប៉ុន្តែវាក៏អាចឈានទៅការត្រួតត្រាពីថ្នាក់កណ្តាល ដែលហាក់ដូចជាមានលក្ខណៈត្រឹមត្រូវបំផុត។

ឧទាហរណ៍ ដូចជាអង្គភាពក្រុងឥណ្ឌា ដែលស្នងការមានសម្ព័ន្ធភាពខ្លាំងជាមួយរដ្ឋាភិបាលថ្នាក់លើ ច្រើនជាងអង្គភាពបញ្ញត្តិរបស់ក្រុមប្រឹក្សាមូលដ្ឋានទៅទៀត។ ផ្ទុយទៅវិញ អូស្ត្រាលីបានឈប់ត្រួតត្រាទីផ្សារការងារផ្នែកសាធារណៈរបស់ខ្លួន ជាពិសេសនៅក្នុងរដ្ឋាភិបាលមូលដ្ឋាន ដើម្បីឱ្យមានចលនាបុគ្គលិកចេញ និងចូលកាន់តែទូលំទូលាយនៅក្នុងវិស័យសាធារណៈ និងឯកជន និងនៅក្នុងកម្រិតថ្នាក់ផ្សេងគ្នានៃផ្នែកសាធារណៈ ។ វាគ្មានកំណែទម្រង់ណាមួយ ក្នុងចំណោមកំណែទម្រង់ទាំងអស់នេះហាក់ដូចជាបង្ហាញពីសិទ្ធិស្វ័យភាពរបស់សហគមន៍មូលដ្ឋានដើម្បីកំណត់ជោគវាសនាផ្ទាល់របស់ខ្លួនទេ ។ ការធ្វើកំណែទម្រង់ គឺជាការផ្ទេរការទទួលខុសត្រូវផ្នែករដ្ឋបាល ដែលគេតែងតែអាចដកហូតយកទៅវិញ ច្រើនជាងការដើរឆ្ពោះទៅកាន់អភិបាលកិច្ចមូលដ្ឋានឱ្យកាន់តែទូលំទូលាយនោះទេ ។ នៅបង់ក្លាដេស បានកំណត់ទស្សនវិស័យដ៏គួរឱ្យចាប់អារម្មណ៍ ស្តីពីការគ្រប់គ្រងនៅតាមកន្លែង។ នៅពេលប្រព័ន្ធរដ្ឋបាលឯកភាព មានការបែងចែកមុខងារ ស្នងការអង្គភាពខេត្ត ដើរតួជាអ្នកគ្រប់គ្រងនៅនឹងកន្លែង

(ពោលគឺស្នងការត្រួតពិនិត្យ និងសម្របសម្រួលការងាររបស់ស្រុក ខណ្ឌ និងខេត្ត) ហេតុដូច្នេះប្រជាពលរដ្ឋ ត្រូវប្រឈមមុខនឹងកង្វះខាតការសម្របសម្រួលយ៉ាងធ្ងន់ធ្ងរ ។ ការឆ្លើយតបរបស់រដ្ឋាភិបាលបង់ក្លាដេស ចំពោះសំណើសុំឱ្យរដ្ឋាភិបាល នៃរាជធានី Dhaka ធ្វើការពន្យល់ការឆ្លើយតបរបស់រដ្ឋាភិបាលកណ្ដាល ចំពោះការដាក់សម្ពាធទៅលើស្វ័យភាពមូលដ្ឋាន គឺតាមរយៈការបង្កើតគណៈកម្មាធិការ(ការគ្រប់គ្រងតាមរយៈគណៈកម្មាធិការ)។ រដ្ឋាភិបាលកណ្ដាល គឺមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីការតាំងចិត្តជាទូទៅ ក្នុងការធ្វើកំណែទម្រង់ទេ ប្រសិនបើរដ្ឋាភិបាលកណ្ដាល មិនធ្វើការកែលម្អរដ្ឋបាល។

ការបង្ហាញពីកង្វះខាតការប្ដេជ្ញាចិត្តក្នុងការធ្វើកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋានដ៏សំខាន់នេះ គឺបង្កឱ្យមានអង្គការ និងភ្នាក់ងារច្រើនហួសហេតុ ទាំងនៅថ្នាក់កណ្ដាល ទាំងនៅថ្នាក់ក្រោមជាតិ ដែលជាញឹកញាប់ មានការជាន់គ្នា ឬមានទំនាស់អាណត្តិ ដែលត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងក្រុងធំៗ ។ នៅទីក្រុងបាងកក ជាឧទាហរណ៍ មានភ្នាក់ងារចំនួន១៧ផ្សេងៗពីគ្នា ដែលត្រូវដោះស្រាយបញ្ហានានា ហើយនៅក្នុងក្រុង ជារឿយៗ ការធ្វើការងារដោយគ្មានការសម្របសម្រួល។ នៅប្រទេសឥណ្ឌា ទីក្រុងអាចមានអង្គភាពសាជីវកម្មក្រុង (រដ្ឋាភិបាលមូលដ្ឋាន ដែលជាប់ឆ្នោត) អាជ្ញាធរអភិវឌ្ឍន៍ (ដែលទទួលខុសត្រូវចំពោះរដ្ឋាភិបាលថ្នាក់រដ្ឋ) គណៈគ្រប់គ្រង (ដែលឆ្លើយតបទៅក្រសួងការពារជាតិ) អាជ្ញាធរទឹកនិងប្រព័ន្ធលូ (ដែលទទួលខុសត្រូវចំពោះរដ្ឋាភិបាល

ថ្នាក់រដ្ឋ) បន្ថែមទៅលើភ្នាក់ងារខ្សែបណ្ដោយរបស់រដ្ឋ និងក្រសួង មន្ទីររដ្ឋាភិបាលសហព័ន្ធដែលមានកម្មវិធី និងផែនការផ្ទាល់នីមួយៗ របស់ខ្លួន។ ដោយហេតុថា ពួកគេត្រូវគ្រប់គ្រងដោយច្បាប់ផ្សេងៗ ពីគ្នានៅថ្នាក់រដ្ឋ និងថ្នាក់សហព័ន្ធ ដោយសារតែមានជម្លោះ នយោបាយ ជាពិសេសប្រសិនបើរដ្ឋាភិបាលមូលដ្ឋាន ត្រូវគ្រប់-គ្រងដោយគណបក្សមួយ ដែលប្រឆាំងនឹងរដ្ឋាភិបាលថ្នាក់រដ្ឋ នោះការសម្របសម្រួល ជាញឹកញាប់មិនអាចធ្វើទៅបានទេ។

អ្នកធ្វើបាយការណ៍នៅប្រទេសម៉ាឡេស៊ី បានលើកឡើង ពីបញ្ហាសំខាន់មួយ នៅពេលនិយាយអំពីតួនាទីពីរ សម្រាប់ឱ្យរដ្ឋាភិបាលមូលដ្ឋាន គឺដើរតួជាអ្នកផ្ដល់សេវា និងអ្នកសម្របសម្រួល កំណើនសេដ្ឋកិច្ច សង្គម ។ គំរូពីមុន គឺមានលក្ខណៈសមស្រប ច្រើនទៅនឹងបទប្បញ្ញត្តិ និងការធ្វើនិយ័តកម្មសេវា។ គំរូចាស់នេះ បានបង្កើតឱ្យមានឧបនិស្ស័យ សម្រាប់ការតែងតាំងមន្ត្រីជាភ្នាក់ងារដែលកាតច្រើនបំផុត ជាភ្នាក់ងាររបស់រដ្ឋាភិបាលថ្នាក់លើ។

ដោយសារការធ្វើឯកជនភាវូបនីយកម្ម មានការកើនឡើង ដូចមានចែងនៅក្នុងគោលនយោបាយគ្រប់គ្រងសាធារណៈ ជាឧទាហរណ៍នៅប្រទេសម៉ាឡេស៊ី រដ្ឋាភិបាលមូលដ្ឋានកាន់តែមាន សមត្ថភាពសម្របសម្រួលកំណើនសេដ្ឋកិច្ច សង្គម ។ មុខងារធ្វើ និយ័តកម្មរបស់ខ្លួន ក៏បានដកទៅធ្វើនិយ័តកម្ម សកម្មភាពទីផ្សារ ឯកជន ។ នៅពេលផ្ដល់លទ្ធភាពឱ្យរដ្ឋាភិបាលមូលដ្ឋាន មាន តួនាទីថ្មីទាំងអស់នេះ ទាមទារឱ្យមានយន្តការថ្មីៗ ដើម្បីធានា តម្លាភាព និងគណនេយ្យភាព ចំពោះសហគមន៍នានា។ អង្គភាព

រដ្ឋបាលពាក់កណ្តាលស្វ័យតរបស់រដ្ឋ និងអង្គភាពប្រហាក់ប្រហែល ដែលគ្មានសមាជិកភាពកើតចេញពីការបោះឆ្នោតដោយផ្ទាល់នឹង មិនធានាអំពីគណនេយ្យភាពចំពោះសហគមន៍ទេ។ តាមការពិត វាអាចមានតម្លាភាពតិចជាងគំរូចាស់ផងក៏ថាបាន។ បញ្ហាប្រឈម គឺត្រូវរក្សាឱ្យបាននូវតុល្យភាព រវាងតម្រូវការបង្កើនប្រតិបត្តិការ របស់ផ្នែកឯកជនប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព នៅពេលមានការធានាកម្រិតគ្រប់គ្រងសមស្របនៅសហគមន៍។

ភស្តុតាងបង្ហាញក្នុងរបាយការណ៍ទាំងអស់នេះ បានស្នើសុំថា គេគួរតែធ្វើការងារឱ្យបានច្រើនជាងនេះតទៅទៀត។

**ឃ-ការងារលើគម្ពុ**

រដ្ឋាភិបាលមូលដ្ឋាននៅបណ្តាប្រទេសទាំងអស់ ប្រតិបត្តិដោយផ្អែកលើមូលដ្ឋានច្បាប់ ដែលកំណត់ដោយអង្គនីតិប្បញ្ញត្តិនៅថ្នាក់ខ្ពស់ជាង ។ ក្នុងករណីមួយចំនួន នេះគឺជារដ្ឋាភិបាលកណ្តាល ក្នុងករណីផ្សេងទៀត វាជាអង្គនីតិប្បញ្ញត្តិរដ្ឋ (សភា) ដែលកំណត់អំពីអំណាចរាជ្ជាធរ ភារកិច្ច និងតួនាទីរបស់រដ្ឋាភិបាលមូលដ្ឋាន។ម្យ៉ាងវិញទៀត អ្វីដែលមានបញ្ជាក់ច្បាស់នៅក្នុងរបាយការណ៍តាមប្រទេសនីមួយៗ គឺជាការគិតគូរយ៉ាងច្រើន អំពីការធ្វើកំណែទម្រង់ទូលំទូលាយ ប៉ុន្តែរដ្ឋាភិបាលកណ្តាល មានការស្ទាក់ស្ទើរក្នុងការផ្លាស់ប្តូរសំខាន់ៗ ឱ្យមានប្រសិទ្ធភាព។ ដំណើរការលឿនលឿនបំផុត ប្រហែលជាមានក្រមទូទៅ ស្តីពីរដ្ឋាភិបាលមូលដ្ឋានរបស់ហ្វីលីពីនឆ្នាំ១៩៩១។ នៅប្រទេសបង់ក្លាដេស សម្ព័ន្ធរដ្ឋាភិបាល Awami គឺជាការគិតអំពីការផ្តល់អំណាចដល់រដ្ឋាភិ-

បាលមូលដ្ឋានកាន់តែច្រើន ទោះបីជាសភាមិនសូវយកចិត្តទុកដាក់យ៉ាងពិតប្រាកដ ដើម្បីធ្វើការផ្ដល់អំណាចក៏ដោយ។ ឱកាសមាននៅឆ្នាំ១៩៩០ និងឆ្នាំ១៩៩៧ សម្រាប់ការទទួលស្គាល់រដ្ឋាភិបាលមូលដ្ឋានដ៏សំខាន់របស់ប្រទេសហ្វីជី ក៏ប៉ុន្តែឱកាសទាំងអស់ត្រូវបានបាត់បង់ទៅវិញ ។ ដូចគ្នានឹងរដ្ឋាភិបាលកណ្ដាល ដែលពួកគេបានបង្កើតគណៈកម្មការត្រួតពិនិត្យមួយ សមាគមរដ្ឋាភិបាលមូលដ្ឋានរបស់ហ្វីជីបានធ្វើសំណើទៅគណៈកម្មការនេះដោយស្នើសុំស្វ័យភាព ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ហើយនៅពេលសរសេរសំណើ គេមិនបានដឹងពីលទ្ធផលទេ។

នៅក្នុងការធ្វើប្រជាមតិថ្នាក់ជាតិឆ្នាំ១៩៨៨ ប្រជាពលរដ្ឋអូស្ត្រាលី បានច្រានចោលសំណើឱ្យទទួលស្គាល់រដ្ឋាភិបាលមូលដ្ឋានដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេស។ចំណាប់អារម្មណ៍នេះ អាចកើតមានឡើងវិញនៅក្នុងកិច្ចពិភាក្សាបច្ចុប្បន្នថា តើប្រទេសអូស្ត្រាលី គួរក្លាយទៅជាសាធារណរដ្ឋមួយឬទេ ? ។ នៅពេលនោះ ការផ្លាស់ប្ដូរសំខាន់ៗ បានកើតឡើងនៅទសវត្សឆ្នាំ ១៩៩០ ដោយពង្រីកឆន្ទានុសិទ្ធិ ប៉ុន្តែមិនបញ្ឈប់ការត្រួតត្រាទេ។ អង្គភាពមូលដ្ឋាននៅទីប្រជុំជនរបស់ប្រទេសឥណ្ឌា ហាក់ដូចជាគិតទុកជាមុនអំពីការធ្វើកំណែទម្រង់ទ្រង់ទ្រាយធំ។នៅពេលឥណ្ឌាចាប់ផ្ដើមធ្វើកំណែទម្រង់ក្របខ័ណ្ឌច្បាប់សំខាន់ៗ រួមមានទាំងការទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញផងនោះ បញ្ហាត្រូវបានចោទឡើងថា តើនរណាជាអ្នកធ្វើឱ្យមានការផ្លាស់ប្ដូរ ? ។ បើមានឱកាសប្រជាពលរដ្ឋអូស្ត្រាលីនឹងច្រានចោលឱកាសនោះ ហើយការបោះ

ឆ្នោត គឺជាកាតព្វកិច្ចនៅប្រទេសអូស្ត្រាលី ។ ឱកាសក៏ត្រូវបាន បាត់បង់ទៅវិញផងដែរនៅប្រទេសហ្វីជី។

យើងមានការចាប់អារម្មណ៍គួរឱ្យកត់សម្គាល់ថា ក្រោយពីការតស៊ូអស់រយៈពេលយ៉ាងយូរពីសំណាក់ពួកបញ្ញវន្ត និងអ្នករដ្ឋបាលសាធារណៈ គឺថាស្វ័យភាពមូលដ្ឋាន ត្រូវបានចងជាក្រមនៅឆ្នាំ១៩៩១។នៅប្រទេសដែលមានអំណាចពលរដ្ឋ គេហាក់ដូចជាមិនមានសហគមន៍ធំ ដែលជំរុញឱ្យមានការធ្វើកំណែទម្រង់ទេ។ នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ ដូចរបាយការណ៍ប្រទេសឥណ្ឌា បង្ហាញយ៉ាងច្បាស់ថា ការទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនឹងមិនមានការចាំបាច់សម្រាប់បង្កើត "ស្ថាប័នលទ្ធិប្រជាធិបតេយ្យដ៏រស់រវើក និងមានប្រសិទ្ធភាព "ទេ។

**ប្រអប់ទី៣ ៖ ក្របខ័ណ្ឌគតិយុត្តសម្រាប់រដ្ឋាភិបាលមូលដ្ឋាន**

ប្រទេសអូស្ត្រាលី៖រដ្ឋាភិបាលមូលដ្ឋាន មិនត្រូវបានទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញទេ ។ ច្បាប់ស្ដីពីរដ្ឋាភិបាលមូលដ្ឋាន ត្រូវបានសភារដ្ឋនីមួយៗបង្កើតឡើង និងធ្វើវិសោធនកម្មយ៉ាងច្រើននៅទសវត្សរ៍ឆ្នាំ១៩៩០។ ជាទូទៅដំណើរការនេះ បានឃ្លាតឆ្ងាយពីច្បាប់បញ្ញត្តិ ដើម្បីផ្ដល់ក្របខ័ណ្ឌ លទ្ធភាពកាន់តែច្រើន ដែលអនុញ្ញាតឱ្យក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិមួយចំនួនដើម្បីដាក់បញ្ចូលសេចក្ដីណែនាំគោលនយោបាយផ្ទាល់របស់ពួកគេ។

ប្រទេសបង់ក្លាដេស ៖ នៅឆ្នាំ១៩៩៦ គណៈកម្មការរដ្ឋាភិបាលមូលដ្ឋានមួយ ត្រូវបានបង្កើតឡើង យោងតាមរបាយការណ៍ស្ដីពីការពង្រឹងស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន នៅឆ្នាំ១៩៩៧។

ប្រទេសចិន ៖ រដ្ឋធម្មនុញ្ញជាតិ និងច្បាប់ពាក់ព័ន្ធ

ប្រទេសហ្វីជី ៖ រដ្ឋាភិបាលមូលដ្ឋាន មិនត្រូវបានទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញទេ។ ច្បាប់គ្រប់គ្រងក្រុងត្រូវបានធ្វើឡើងស្របតាមការអនុម័តច្បាប់ស្តីពីរដ្ឋាភិបាលមូលដ្ឋានឆ្នាំ១៩៧២។ ក្រៅពីច្បាប់ដែលត្រូវបានធ្វើវិសោធនកម្ម កាលពីប៉ុន្មានឆ្នាំ នាពេលថ្មីៗនេះ អាជ្ញាធរមូលដ្ឋានត្រូវមានការទទួលខុសត្រូវ អនុលោមតាមបទដ្ឋានគតិយុត្តជាច្រើន។

ប្រទេសឥណ្ឌា៖ ច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៧៤ នៅឆ្នាំ១៩៩២សំដៅរកវិធីផ្តល់អំណាចនិងសមត្ថកិច្ចកាន់តែច្រើនដល់អង្គភាពមូលដ្ឋាននៅទីក្រុង ។ ការធានាស្ថិរភាពរដ្ឋាភិបាលថ្នាក់ក្រុង តាមបែបប្រជាធិបតេយ្យ តាមរយៈបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញ គឺជាគោលបំណងធំសំខាន់។ កម្មវិធីទី២០របស់ច្បាប់នេះរៀបរាប់អំពីមុខងាររបស់អង្គភាពមូលដ្ឋាន នៅទីក្រុង និងចែងបញ្ជាក់ពីអំណាច និងការទទួលខុសត្រូវរបស់អង្គភាពនោះ។

ប្រទេសឥណ្ឌូនេស៊ី៖ច្បាប់លេខ៥ស្តីពីរដ្ឋាភិបាលមូលដ្ឋាន នៅឆ្នាំ១៩៧៤ ដែលចែងថាស្វ័យភាពមូលដ្ឋាន គឺមានលក្ខណៈប្រាកដប្រជា និងទទួលខុសត្រូវផ្តោតទៅលើរដ្ឋាភិបាលមូលដ្ឋាន និងផ្តល់អាទិភាពដល់សុខដុមរមនា សំដៅបង្កើនភាពស័ក្តិសិទ្ធិ និងផលិតភាពក្នុងការផ្តល់សេវាសាធារណៈ និងក្នុងការរក្សាស្ថិរភាពនយោបាយ ព្រមទាំងសុចរិតភាពថ្នាក់ជាតិ ហើយគួរតែអនុវត្តតាមគោលការណ៍ទាំងផ្នែកវិមជ្ឈការ និងវិសហមជ្ឈការ។

ប្រទេសជប៉ុន ៖ ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន នៅឆ្នាំ

១៩៨៧ ត្រូវបានធ្វើវិសោធនកម្មនាពេលថ្មីៗ ដើម្បីបង្កើតប្រព័ន្ធក្រុងស្វូល សំដៅលើកកម្ពស់អាជ្ញាធររដ្ឋបាលក្រុង ឱ្យមានទំហំធំ និងសមត្ថភាពប្រហាក់ប្រហែលគ្នានឹងអង្គភាពសង្គម ជួយឱ្យក្រុងទាំងអស់នេះ អាចធ្វើការគ្រប់គ្រងនៅកិតនឹងប្រជាពលរដ្ឋបំផុតតាមដែលអាចធ្វើទៅបាន ព្រមទាំងមានប្រព័ន្ធសហប្រតិបត្តិការទូលំទូលាយ ដើម្បីដោះស្រាយតម្រូវការរដ្ឋបាលទូលំទូលាយច្រើនវិស័យ ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងធ្វើឱ្យប្រសើរឡើង នូវប្រព័ន្ធនេះ ដើម្បីទទួលការផ្ទេរសមត្ថកិច្ចពីរដ្ឋ។

ប្រទេសគីហ្ស៊ីស្ថាន៖ ច្បាប់បញ្ញត្តិដែលចែងអំពីស្វ័យគ្រប់គ្រង គឺមានរដ្ឋធម្មនុញ្ញរួមទាំងមានស្វ័យាភិបាលមូលដ្ឋាន ដែលជាសញ្ញាណ និងគោលការណ៍ជាច្បាប់ ជាក្រឹត្យរបស់ប្រធានាធិបតី និងរបស់រដ្ឋាភិបាល ដែលកំណត់អំពីមូលដ្ឋានហិរញ្ញវត្ថុ អំណាច និងមុខងាររបស់ស្វ័យគ្រប់គ្រងមូលដ្ឋាន និងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងរចនាសម្ព័ន្ធរដ្ឋនានា ។

ប្រទេសម៉ាឡេស៊ី ៖ ច្បាប់ស្ដីពីរដ្ឋាភិបាលមូលដ្ឋាន នៅឆ្នាំ១៩៧៦មានចែងអំពីអំណាច ភារកិច្ច ការទទួលខុសត្រូវ និងមុខងាររបស់អាជ្ញាធរមូលដ្ឋាន។

ប្រទេសញូហ្ស៊ីឡែន ៖ សេចក្ដីណែនាំគោលនយោបាយរបស់ រដ្ឋាភិបាល(ឆ្នាំ១៩៨៧) សំដៅធ្វើឱ្យមានកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាននៅឆ្នាំ១៩៨៩។គោលការណ៍ចម្បងនៃកំណែទម្រង់នេះ គឺថារដ្ឋាភិបាលមូលដ្ឋាន គួរត្រូវបានបោះឆ្នោតជ្រើសរើសដើម្បីទទួលខុសត្រូវឬបំពេញមុខងារទាំងឡាយ ដែលជាផល

ប្រយោជន៍រួម លើសពីការរៀបចំស្ថាប័នដទៃទៀត។ ក្រៅពីនេះ គោលការណ៍បែងចែកមុខងារ (subsidiarity principles) ត្រូវតែយកមកអនុវត្ត រួមទាំងមុខងារ ក៏ត្រូវធ្វើការបែងចែកទៅតាមសហគមន៍ ផលប្រយោជន៍សមស្រប ភាពស័ក្តិសិទ្ធិ ដែលត្រូវសម្រេចឱ្យបានក្នុងកិច្ចប្រតិបត្តិការ គោលដៅលុបបំបាត់ទំនាស់ការរៀបចំគោលដៅឱ្យបានច្បាស់លាស់ មានតម្លាភាព និងមានយន្តការគណនេយ្យភាពច្បាស់លាស់ ខ្លាំងក្លា ដែលជួយលើកកម្ពស់កិច្ចប្រតិបត្តិការងាររបស់រដ្ឋាភិបាលមូលដ្ឋាន។

ប្រទេសប៉ាគីស្ថាន ៖ រដ្ឋាភិបាលមូលដ្ឋាន មិនមានចែងជាផ្លូវការនៅក្នុងរដ្ឋធម្មនុញ្ញទេ ក៏ប៉ុន្តែមានចែងពីការត្រួតពិនិត្យរបស់រដ្ឋាភិបាលថ្នាក់ខេត្តនានា ដែលគ្រាន់តែបានធ្វើប្រតិភូកម្មមុខងារ និងការទទួលខុសត្រូវមួយចំនួន តាមរយៈការប្រកាសឱ្យប្រើបទបញ្ញានានា ដូចជាបទបញ្ញាស្តីពីអភិបាលកិច្ចមូលដ្ឋានឆ្នាំ១៩៧៩ និងឆ្នាំ១៩៨០។

ប្រទេសហ្វីលីពីនៈក្រមស្តីពីរដ្ឋាភិបាលមូលដ្ឋាន(ឆ្នាំ១៩៩១) និងឯកសារស្វែងយល់ពីរដ្ឋាភិបាលមូលដ្ឋាន ដែលនិយាយអំពីចេនាសម្ព័ន្ធ មុខងារ និងអំណាច រួមទាំងការយកពន្ធ និងទំនាក់ទំនងអន្តររដ្ឋាភិបាល។

សាធារណរដ្ឋកូរ៉េ ៖ មានច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ។

ប្រទេសស្រីលង្កា ៖ បទប្បញ្ញត្តិស្តីពីក្រុមប្រឹក្សាខេត្ត បទប្បញ្ញត្តិ ស្តីពីក្រុមប្រឹក្សាក្រុង និងច្បាប់សភា Pradeshiya។ លើកលែងតែលក្ខន្តិកៈពីរបី ដែលចែងអំពីការគ្រប់គ្រងរដ្ឋបាលមូល

ដ្ឋានសកម្មភាពសំខាន់ៗ ភាគច្រើនបំផុត ត្រូវបានគ្រប់គ្រងដោយច្បាប់ទាំងបីនេះ។

ប្រទេសថៃឡង់ដ៏ ៖ ច្បាប់រដ្ឋបាលសាធារណៈ (ឆ្នាំ១៩៣៣) ចែងអំពីមូលដ្ឋានរៀបចំរដ្ឋបាលមូលដ្ឋាន ។ ជាងនេះទៅទៀត អំណាចរដ្ឋបាល របស់រដ្ឋាភិបាលមូលដ្ឋាន ត្រូវបានគ្រប់គ្រងដោយភ្នាក់ងាររដ្ឋាភិបាលកណ្ដាល (ដូចជាអភិបាល និងមន្ត្រីស្រុក) និងមានលក្ខណៈជាប្រព័ន្ធមជ្ឈការខ្លាំង។

## III.ទំនាក់ទំនងថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន

ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាននៅគ្រប់ប្រទេសទាំងអស់ មានប្រវត្តិខុសៗគ្នា ប៉ុន្តែមានគោលបំណងប្រហាក់ប្រហែលគ្នា។ ប្រព័ន្ធទាំងអស់ត្រូវទាក់ទងនឹងរដ្ឋាភិបាលកម្រិតខ្ពស់ រហូតដល់ថ្នាក់រដ្ឋ ឬថ្នាក់ខេត្ត ឬដល់រដ្ឋាភិបាលថ្នាក់ជាតិក៏បាន ។ កម្រិតខ្ពស់ជាងជាទូទៅ មានឥទ្ធិពលលើទំនាក់ទំនងនានា។ ក្នុងនាមជាភ្នាក់ងាររបស់បណ្ដាញរដ្ឋាភិបាលថ្នាក់ខ្ពស់ មិនអាចបង្កើតស្វ័យគ្រប់គ្រងមូលដ្ឋានដោយខ្លួនឯងបានទេ ។ ដូចយើងបានជម្រាបជូនរួចហើយនៅក្នុងរបាយការណ៍របស់កូរ៉េ សូម្បីក្រុមប្រឹក្សាដែលមានការបោះឆ្នោតដោយសេរីក៏ដោយក៏មិនមានលក្ខណៈជាស្វ័យគ្រប់គ្រងដែរ ប្រសិនបើអ្នកនយោបាយមូលដ្ឋានទាំងអស់ ពិតជាធ្វើតាមតម្រូវការរបស់ថ្នាក់កណ្ដាលនោះ។ ការត្រួតពិនិត្យពីថ្នាក់កណ្ដាលលើការត្រួតពិនិត្យ ក្នុងការធ្វើសេចក្ដីសម្រេចចិត្តរបស់-អាជ្ញាធរមូលដ្ឋានក៏ដោយ ក៏កើតមាននៅក្នុងប្រទេសស្រីលង្កា។ ការពឹងផ្អែករបស់មូលដ្ឋាន ទៅលើមូលនិធិដែលវិភាជន៍ពីថ្នាក់

កណ្តាល ជួយពង្រឹងចំណុចខ្សោយ និងចំណុចខ្លាំងរបស់ថ្នាក់ទាំងពីរ។

មានសញ្ញាជាច្រើន ក្នុងការបង្កើនកម្លាំងនៅថ្នាក់មូលដ្ឋាន និងកិច្ចសហប្រតិបត្តិការរវាងថ្នាក់នីមួយៗ ។ នៅប្រទេសចិន ជាតួយ៉ាងរដ្ឋាភិបាលមូលដ្ឋាន ចូលរួមចំណែកកាន់តែច្រើនឡើងនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ហើយរដ្ឋាភិបាលមូលដ្ឋានមួយចំនួន កំពុងចាប់ផ្តើមបង្កើនឥទ្ធិពលទៅលើរដ្ឋាភិបាលកណ្តាល ។ ជាទូទៅ នៅប្រទេសមួយចំនួនមានភាពចំណុះ និងបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក នៅក្នុងទំនាក់ទំនងរដ្ឋាភិបាលថ្នាក់កណ្តាលជាមួយនឹងថ្នាក់មូលដ្ឋាន។ នគរូបនីយកម្ម និងកំណើនទីក្រុងធំៗយ៉ាងឆាប់រហ័ស ដូចជាទីក្រុងបាងកក តូក្យូ និងម៉ានីល បានផ្តល់ឋានៈពិសេសដល់ទីក្រុងទាំងនេះ តាមរយៈការរៀបចំពិសេសពីគេ។ តែទោះជាយ៉ាងណាក៏ដោយទំហំរបស់ទីក្រុង មិនបានធានានូវការរៀបចំពិសេសនោះទេ ទំហំគ្រាន់តែជាការធៀបនឹងទំហំនៃរដ្ឋាភិបាលមូលដ្ឋានរបស់ទីក្រុង។ ទីក្រុងស៊ីដនីដែលមានប្រជាពលរដ្ឋសរុបប្រមាណជាង៤លាននាក់ មិនបានទទួលឋានៈពិសេសនេះទេដោយហេតុថាទីក្រុងមេត្រូប៉ូលីតានស៊ីដនី មានរដ្ឋាភិបាលមូលដ្ឋានចំនួន៤០ ដែលមូលដ្ឋានមួយចំនួន មានប្រជាពលរដ្ឋប្រហែលពីរម៉ឺននាក់ ។ រដ្ឋ និងខេត្ត អាចធ្វើទំនាក់ទំនងមូលដ្ឋានទៅថ្នាក់កណ្តាល ។ នេះអាចបណ្តាលមកពីការទទួលខុសត្រូវត្រួតគ្នា ដូចជាប្រទេសថៃឡង់ដ៍ ឬប្រទេសម៉ាឡេស៊ីជាដើម រដ្ឋនៅរក្សាការត្រួតពិនិត្យ សូម្បីនៅពេលរដ្ឋាភិបាលកណ្តាល ផ្តល់

ថវិកា ដោយផ្ទាល់ទៅឱ្យរដ្ឋាភិបាលមូលដ្ឋាន។ យ៉ាងណាក៏ដោយ ខេត្តនានា អាចជាច្រកសម្រាប់ទទួលបានស្វ័យភាពមូលដ្ឋានកាន់តែច្រើនឡើងៗ។

នៅប្រទេសប៉ាគីស្ថាន យុទ្ធសាស្ត្រក្នុងការសម្រេចឱ្យបានស្វ័យភាពមូលដ្ឋាន និងការទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ គឺទី១ ត្រូវធានាស្វ័យភាពថ្នាក់ខេត្ត និងការទទួលស្គាល់។ ក៏ប៉ុន្តែការធ្វើដូច្នេះក៏អាចមានហានិភ័យដែរ។ អ្វីដែលរដ្ឋាភិបាលមូលដ្ឋាន គួរមានពិតប្រាកដ គឺរដ្ឋាភិបាលថ្នាក់ខេត្ត ត្រូវមានការធានាស្វ័យភាព និងការទទួលស្គាល់ ពេលនោះរដ្ឋាភិបាលមូលដ្ឋាននឹងមានការធានាស្វ័យភាពមូលដ្ឋាន និងការទទួលស្គាល់ ។ ម្យ៉ាងទៀត សមត្ថភាពរបស់រដ្ឋាភិបាលមូលដ្ឋាន ត្រូវធ្វើទំនាក់ទំនងតាមផ្នែករបស់ខ្លួន។ អ្នកនយោបាយមូលដ្ឋានមួយចំនួនមិនសូវយកចិត្តទុកដាក់ក្នុងការកសាងទំនាក់ទំនងឱ្យបានខ្លាំងក្លានោះទេ។

នៅប្រទេសហ្វីជី មានសក្តានុពលច្រើនធ្វើឱ្យផ្នែកនយោបាយមានលក្ខណៈល្វនបានយ៉ាងល្អប៉ុន្តែអ្នកនយោបាយមូលដ្ឋានមិនអាចឆ្លើយតបបានទេ។ ការទទួលបានសេរីភាពកាន់តែច្រើនពីការគ្រប់គ្រងថ្នាក់កណ្តាល នឹងបំបាត់ចោលនូវតម្រូវការសម្រាប់គណនេយ្យភាព តែតាមការពិត គួរតែមានគណនេយ្យភាពឱ្យកាន់តែច្រើន ចំពោះសហគមន៍មូលដ្ឋានរបស់ខ្លួន ។

នៅប្រទេសអូស្ត្រាលី និងញូហ្ស៊ីឡែន គណនេយ្យភាពដែលកើនឡើងចំពោះសហគមន៍មូលដ្ឋាន នេះគឺជាលទ្ធផលដ៏មានសារសំខាន់ ដែលកើតពីការធ្វើកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាន។

## ប្រអប់ទី៤ ៖ រចនាសម្ព័ន្ធរដ្ឋាភិបាល

ប្រទេសអូស្ត្រាលី ៖ នៅមានកម្រិតសហគមន៍រដ្ឋ Com monwealth រដ្ឋាភិបាលមាននាយករដ្ឋមន្ត្រី និងសភាដែលមានសភាតំណាងរាស្ត្រ និងព្រឹទ្ធសភា ក្រសួងជាច្រើន និងអាជ្ញាធរ គណៈអភិបាល គណៈកម្មការនានាជាច្រើនដែលមានលក្ខន្តិកៈរបស់ខ្លួន។ប្រព័ន្ធតុលាការ និងរដ្ឋាភិបាលដែនដី រួមមានតុលាការកំពូល តុលាការសហព័ន្ធ តុលាការគ្រួសារ និងស្ថាប័នតុលាការផ្សេងៗទៀត។ រដ្ឋ និងរដ្ឋាភិបាលដែនដី មានរចនាសម្ព័ន្ធប្រហាក់ប្រហែលគ្នា និងមាននាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី និងសភា ដែលភាគច្រើនមានសភាពីរ ។ នៅកម្រិតរដ្ឋាភិបាលមូលដ្ឋាន ក្រុមប្រឹក្សាដែលមានសមាជិកក្រុមប្រឹក្សា និងដែលដឹកនាំដោយអភិបាល ឬចៅហ្វាយក្រុង និងអ្នកគ្រប់គ្រងក្រុង គឺជាអ្នកទទួលខុសត្រូវ ។ តាំងពីការកើតសហព័ន្ធនៅឆ្នាំ១៩០១ ក៏កើតមានប្រព័ន្ធរដ្ឋាភិបាលដែលដំណើរការដោយពហុបក្ស។ ផ្ទុយពីការបោះឆ្នោតរដ្ឋាភិបាលមូលដ្ឋាន ការបោះឆ្នោតនៅថ្នាក់ Common wealth និងរដ្ឋ ឬដែនដី គឺជាកាតព្វកិច្ច។

ប្រទេសបង់ក្លាដេស៖ មានទម្រង់រដ្ឋាភិបាលឯកត្តរដ្ឋដែលចែកចេញជាអង្គភាពរដ្ឋបាលចំនួន០៦ ដឹកនាំដោយស្នងការអង្គភាព។ អង្គភាពនីមួយៗ ត្រូវចែកចេញជាមណ្ឌល ដែលមានស្នងការមណ្ឌល ឬស្នងការរង គឺជានាយករដ្ឋបាល។ មណ្ឌលទាំងឡាយត្រូវចែកចេញជាអនុមណ្ឌល។ កម្រិតអង្គភាពខេត្ត គឺជាឋានានុក្រមរដ្ឋបាលខ្ពស់បំផុត បន្ទាប់ពីថ្នាក់ជាតិ ចំណែកឯថ្នាក់

មណ្ឌល គឺជាអង្គភាពបង្គោលនៅក្នុងប្រព័ន្ធរដ្ឋបាល។ រដ្ឋាភិបាលមូលដ្ឋាន ត្រូវធ្វើជាអង្គបោះឆ្នោតឱ្យក្រុងនៅតំបន់ទីក្រុង និងបោះឆ្នោតក្រុមប្រឹក្សាសហភាពនៅតំបន់ជនបទ ។ ក្រុងចំនួនបួនក្នុងចំណោមក្រុងដែលធំបំផុតនានា ត្រូវបានទទួលឋានៈ ជាអង្គភាពទីក្រុងមេត្រូប៉ូលីតាន និងដឹកនាំដោយចៅហ្វាយក្រុង ដែលកើតចេញពីការបោះឆ្នោត ។ ជាងនេះទៅទៀត មណ្ឌលទីក្រុងមួយចំនួនត្រូវឋិតនៅក្រោមការគ្រប់គ្រងរបស់គណៈបញ្ជាការយោធា។

ប្រទេសចិន៖ សភាប្រជាជនចិន គឺជាអង្គការកំពូលនៃអំណាចរដ្ឋ ហើយអង្គការគណៈអចិន្ត្រៃយ៍របស់សភានេះ គឺជាគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលអនុវត្តអំណាចនីតិប្បញ្ញត្តិ។ សភាប្រជាជនមូលដ្ឋាន នៅកម្រិតផ្សេងៗគ្នា គឺជាអង្គការអំណាចរដ្ឋនៅថ្នាក់មូលដ្ឋាន។ ក្រុមប្រឹក្សារដ្ឋ គឺជាអង្គការរដ្ឋបាលកំពូលរបស់រដ្ឋ និងជាអង្គនីតិប្រតិបត្តិ នៃអង្គការកំពូលនៃអំណាចរដ្ឋ។ តុលាការប្រជាជននៅកម្រិតថ្នាក់ផ្សេងៗគ្នា គឺជាអង្គតុលាការ។ តុលាការប្រជាជននៅថ្នាក់មូលដ្ឋាន គឺតុលាការប្រជាជនពិសេស និងតុលាការកំពូលប្រជាជនអនុវត្តអំណាចតុលាការ។ អាណាព្យាបាលកំពូល មូលដ្ឋាននិងអាណាព្យាបាលពិសេសរបស់ប្រជាជននៅថ្នាក់មូលដ្ឋានគឺជាអង្គការត្រួតពិនិត្យច្បាប់របស់រដ្ឋ។ រដ្ឋាភិបាលមូលដ្ឋាន គឺជាអង្គរដ្ឋបាលរបស់រដ្ឋ ដែលឋិតក្រោមការដឹកនាំរបស់ក្រុមប្រឹក្សារដ្ឋ ដែលចែកចេញជារដ្ឋាភិបាលស្វយ័តថ្នាក់តំបន់ជនជាតិ និងរដ្ឋាភិបាលតំបន់រដ្ឋបាលពិសេស។ ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន ត្រូវចែកចេញជាថ្នាក់ខេត្ត ក្រុង ស្រុក និងភូមិ។

ប្រទេសហ្វីជី៖ រដ្ឋធម្មនុញ្ញ ចែងកំណត់អំពីប្រព័ន្ធសភាហុបក្ស តំណាងឱ្យកម្រិតរដ្ឋាភិបាលថ្នាក់ជាតិ ដែលមានប្រធានាធិបតីជាប្រមុខរដ្ឋ និងនាយករដ្ឋមន្ត្រីសម្រាប់ដឹកនាំរដ្ឋាភិបាល។ សភាមានពីរថ្នាក់ គឺព្រឹទ្ធសភា និងសភាតំណាងរាស្ត្រ។ មណ្ឌលបោះឆ្នោតឃុំ សង្កាត់ ធ្វើការបោះឆ្នោតជ្រើសរើសសមាជិកសភា ចំណែកឯសមាជិកព្រឹទ្ធសភាត្រូវកើតចេញពីការតែងតាំង។ នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីផ្សេងៗទៀត ដែលដឹកនាំក្រសួងនីមួយៗរបស់ខ្លួនបង្កើតបានជាគណៈរដ្ឋមន្ត្រី ។ រដ្ឋាភិបាលមូលដ្ឋាន ត្រូវគ្រប់គ្រងតាមរយៈក្រុមប្រឹក្សាខេត្ត ក្រុង ដែលកើតចេញពីការបោះឆ្នោតដែលមានសមាជិកក្រុមប្រឹក្សាជាប់ឆ្នោត ដែលតំណាងគណបក្សនយោបាយធំៗ ដែលសកម្មនៅថ្នាក់ជាតិ និងដែលដឹកនាំដោយអភិបាល ឬចៅហ្វាយក្រុងជាប់ឆ្នោត ព្រមទាំងអាជ្ញាធរមូលដ្ឋាននៅទីជនបទនានា។

ប្រទេសឥណ្ឌា៖ រដ្ឋាភិបាលកណ្ដាល មានប្រធានាធិបតីដែលមានអំណាចកោះប្រជុំ ឬលើកពេលប្រជុំសភា ឬសភាប្រជាជន សភានីតិប្បញ្ញត្តិ (ស្ថាប័នកំពូលផ្នែកនីតិប្បញ្ញត្តិ) សភាប្រជាជន និងក្រុមប្រឹក្សារដ្ឋ ។ រដ្ឋាភិបាលមូលដ្ឋាន មានក្រុមប្រឹក្សាខេត្ត ក្រុងក៏បាន ឬសាជីវកម្មខេត្តក៏បាន។ អង្គភាពមូលដ្ឋាននៅទីប្រជុំជនទាំងអស់ មានសមាជិកក្រុមប្រឹក្សា និងត្រូវដឹកនាំដោយចៅហ្វាយក្រុង ដែលកើតចេញពីការបោះឆ្នោតជាទៀងទាត់ ឬជាប់ឆ្នោតឡើងវិញ ត្រូវចាត់ជាស្ថាប័នប្រជាធិបតេយ្យ ដែលផ្អែកលើគោលការណ៍ស្វ័យគ្រប់គ្រង និងតំណាងឱ្យបំណងប្រាថ្នា និង

កម្លាំងរបស់ប្រជាជន។

ប្រទេសឥណ្ឌូនេស៊ី ៖ សភាប្រជាជន មានអំណាចខ្ពស់បំផុត។ ប្រធានាធិបតី ដែលតែងតាំងដោយសភាប្រជាជន គឺជាអ្នកប្រតិបត្តិខ្ពស់បំផុត ថ្នាក់ជាតិ និងប្រតិបត្តិស្របទៅតាមសភាតំណាងរាស្ត្រ។ សភាតំណាងរាស្ត្រ គឺជាអង្គបោះឆ្នោត ដែលមានតំណាងគណបក្សនយោបាយ និងអ្នកដែលត្រូវតែងតាំងដោយកងកម្លាំងប្រដាប់អាវុធ។ តុលាការកំពូល គណៈសវនកម្មរដ្ឋ និងក្រុមប្រឹក្សាពិគ្រោះយោបល់ជាន់ខ្ពស់ គឺឋិតក្នុងទីតាំងស្មើគ្នានឹងប្រធានាធិបតី និងឋិតនៅក្រោមសភាប្រជាជន។ ប្រធានាធិបតីបង្កើតនិងដឹកនាំគណៈរដ្ឋមន្ត្រី និងតែងតាំងរដ្ឋមន្ត្រី ដើម្បីដឹកនាំក្រសួងនានា។ រដ្ឋាភិបាលថ្នាក់តំបន់ មានអភិបាល ដែលមានលេខាធិការដ្ឋាន និងការិយាល័យតំបន់របស់ក្រសួងថ្នាក់កណ្ដាលក្នុងពេលដែលរដ្ឋាភិបាលថ្នាក់ខេត្ត មានអភិបាលដែលមានលេខាធិការដ្ឋាន និងមន្ទីរមួយចំនួន ព្រមទាំងសភាតំណាងថ្នាក់ខេត្ត។ រដ្ឋាភិបាល មូលដ្ឋាននៅថ្នាក់ក្រុង ស្រុក និងខណ្ឌ ត្រូវអនុវត្តតាមរយៈមូលដ្ឋានស្វយ័ត ដែលដឹកនាំដោយស្នងការក្រុង ឬចៅហ្វាយក្រុង។

ប្រទេសជប៉ុន ៖ សភា គឺជាអង្គនីតិប្បញ្ញត្តិថ្នាក់ខ្ពស់បំផុតតែមួយគត់ ដែលមានសភាតំណាង ដែលមានសមាជិកចំនួន៥០០នាក់ និងសភាក្រុមប្រឹក្សា ដែលមានសមាជិក២៥២នាក់។ តំណាងមកពីសភាទាំងពីរ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត។ គណៈរដ្ឋមន្ត្រី គឺជាអង្គនីតិប្រតិបត្តិកំពូល និងត្រូវទទួល

ខុសត្រូវរួមចំពោះសភា ក្នុងការអនុវត្តអំណាចនីតិប្រតិបត្តិរបស់ខ្លួន។ អង្គតុលាការ រួមមានតុលាការកំពូល និងតុលាការជាន់ខ្ពស់ជាច្រើន តុលាការតំបន់ តុលាការសង្ខេប និងតុលាការគ្រួសារ។ រដ្ឋាភិបាលមូលដ្ឋាន ដែលមានខេត្ត និងក្រុង ត្រូវចាត់ថ្នាក់ជាអង្គភាពសាធារណៈមូលដ្ឋានធម្មតា ចំណែកឯសង្កាត់ពិសេសសហប្រតិបត្តិការក្រុង ផ្នែកទ្រព្យសម្បត្តិ និងសាជីវកម្ម អភិវឌ្ឍមូលដ្ឋាន ត្រូវចាត់ទុកជាអង្គភាពសាធារណៈមូលដ្ឋាន ពិសេស និងមានការទទួលខុសត្រូវមានកម្រិត។

ប្រទេសគីហ្ស៊ីស្ថាន ៖ រចនាសម្ព័ន្ធរដ្ឋាភិបាលថ្នាក់ជាតិត្រូវចែកជាបីផ្នែក គឺមានផ្នែកនីតិប្រតិបត្តិ នីតិប្បញ្ញត្តិ និងតុលាការ។ ផ្នែកនីតិប្រតិបត្តិ ត្រូវដឹកនាំដោយប្រធានាធិបតី ដែលជាប្រមុខរដ្ឋ និងមានរដ្ឋាភិបាល និងអ្នករដ្ឋបាលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន។ ផ្នែកនីតិប្បញ្ញត្តិ មានសភាដែលមានពីរថ្នាក់ គឺសភានីតិប្បញ្ញត្តិ និងសភាតំណាងប្រជាពលរដ្ឋ។ តុលាការ មានតុលាការធម្មនុញ្ញ តុលាការកំពូល តុលាការមជ្ឈត្តវិនិច្ឆ័យកំពូល និងតុលាការថ្នាក់ក្រោមនិងចៅក្រម។ ស្វ័យគ្រប់គ្រងមូលដ្ឋាន ត្រូវបានអនុវត្តតាមរយៈក្រុមប្រឹក្សាមូលដ្ឋានដែលជាប់ឆ្នោត ដែលមានតំណាងដែលជាប់ឆ្នោត ដឹកនាំដោយប្រធានជាប់ឆ្នោត និងអង្គប្រតិបត្តិតាមរយៈប្រជាមតិផ្ទាល់ពីសភាប្រជាជន ។

ប្រទេសម៉ាឡេស៊ី ៖ សភា គឺមានសភាពីរថ្នាក់ដែលមានសភាតំណាងរាស្ត្រ និងព្រឹទ្ធសភា។ គណៈរដ្ឋមន្ត្រីមានក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលដឹកនាំក្រសួង និងមន្ទីរពាក់ព័ន្ធ និងភ្នាក់ងារនានា។

គណៈរដ្ឋមន្ត្រី ត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី និងមានសមាជិកសភាមួយចំនួន ដែលមិនមានការបញ្ជាក់។ នៅកម្រិតរដ្ឋាភិបាលថ្នាក់រដ្ឋ អ្នកគ្រប់គ្រងតាមបែបតំណាងពួជ គឺថ្នាក់កំពូល ដែលដើរតួជាការផ្ដល់យោបល់ ក្រុមប្រឹក្សាប្រតិបត្តិរដ្ឋ ដែលដឹកនាំដោយនាយករដ្ឋមន្ត្រី។ រដ្ឋទាំងអស់ មានអង្គនីតិប្បញ្ញត្តិមួយថ្នាក់ ដែលកើតចេញពីការបោះឆ្នោត។ គណៈកម្មាធិការប្រតិបត្តិ គឺជាគណៈរដ្ឋមន្ត្រីសហព័ន្ធ ដែលស្មើនឹងថ្នាក់រដ្ឋ ហើយជាអង្គសម្របសម្រួលខ្ពស់បំផុត។ នៅថ្នាក់មូលដ្ឋាន រដ្ឋាភិបាលក្រុមប្រឹក្សាស្រុក ដែលដឹកនាំដោយមន្ត្រីស្រុក និងក្រុមប្រឹក្សាក្រុង គឺជាអ្នកទទួលបន្ទុក។ អាជ្ញាធរទាំងពីរថ្នាក់ ឋិតក្រោមយុត្តាធិការដោយឡែករបស់រដ្ឋាភិបាលរដ្ឋ។

ប្រទេសញូហ្ស៊ីឡែន ៖ រដ្ឋាភិបាលកណ្ដាល គឺផ្អែកលើប្រព័ន្ធសភាមួយថ្នាក់ ។ ប្រព័ន្ធបោះឆ្នោត ត្រូវបានចាត់ទុកថា ជាប្រព័ន្ធចម្រុះ តំណាងសមាមាត្រ ដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោតបោះឆ្នោតរើសគណបក្ស និងបោះឆ្នោតជ្រើសរើសសមាជិកសរុបចំនួន១២០រូប ដើម្បីធ្វើជាសមាជិកសភា ។ រដ្ឋាភិបាលមូលដ្ឋានត្រូវប្រតិបត្តិតាមរយៈអាជ្ញាធរតំបន់ទោល និងអាជ្ញាធរដែនដី ព្រមទាំងអាជ្ញាធរដែលមានគោលបំណងតែមួយ។ មានក្រុមប្រឹក្សារួមថ្នាក់តំបន់ ថ្នាក់ស្រុក និងគណៈសហគមន៍។ គណៈសហគមន៍ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សា មានសមាសភាពសមាជិកក្រុមប្រឹក្សាជាប់ឆ្នោតចំនួនពាក់កណ្ដាល ដែលតែងតាំងដោយក្រុង ស្រុក និងពាក់កណ្ដាលបោះឆ្នោត ដោយអ្នកបោះឆ្នោតនៅ

មូលដ្ឋាន។ នៅក្នុងអង្គភាពអាជ្ញាធរទោល និងអាជ្ញាធរដែនដី ចៅហ្វាយក្រុង ត្រូវកើតចេញពីការបោះឆ្នោតទូទៅ។ ក្រុមប្រឹក្សាតំបន់ជ្រើសរើសសមាជិកម្នាក់ ក្នុងចំណោមសមាជិកទាំងឡាយរបស់ខ្លួនឱ្យធ្វើជាប្រធាន ដែលភាគច្រើនបំផុតធ្វើការបោះឆ្នោត តាមប្រៃសណីយ៍។

ប្រទេសប៉ាគីស្ថាន៖ នៅកម្រិតថ្នាក់ជាតិ ប្រព័ន្ធរដ្ឋាភិបាលមានពីរថ្នាក់ ដែលមានប្រធានាធិបតី ជាប្រមុខរដ្ឋ មាននាយករដ្ឋមន្ត្រី ដែលកើតចេញពីការបោះឆ្នោតសភាជាតិ និងព្រឹទ្ធសភា។ម្យ៉ាងទៀតសភាថ្នាក់ខេត្តចំនួន៤ ប្រតិបត្តិការនៅកម្រិតរដ្ឋាភិបាលខេត្ត។ ការបោះឆ្នោត គឺត្រូវធ្វើឡើងរៀងរាល់ប្រាំឆ្នាំម្តងដោយប្រជាពលរដ្ឋប៉ាគីស្ថាន ដែលមានអាយុចាប់ពី២១ឆ្នាំឡើងដែលមានសិទ្ធិបោះឆ្នោតរើសតំណាង ចេញពីមណ្ឌលបោះឆ្នោតនីមួយៗ។ ប្រព័ន្ធនយោបាយ និងបោះឆ្នោតរបស់ប៉ាគីស្ថាន គឺអាស្រ័យយ៉ាងទូលាយ លើគោលការណ៍គំរូពីបស្ចឹមប្រទេស។ ប្រព័ន្ធពហុបក្សជឿនលឿន មានទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ រដ្ឋាភិបាលមូលដ្ឋាន មានគណៈកម្មាធិការក្រុង ក្រុមប្រឹក្សាស្រុក គណៈកម្មាធិការសាជីវកម្មក្រុង ឬសាជីវកម្មក្រុង ដោយផ្អែកលើទំហំអង្គភាពពាក់ព័ន្ធ។

ប្រទេសហ្វីលីពីន ៖ រដ្ឋាភិបាលថ្នាក់ជាតិ មានអង្គនីតិប្រតិបត្តិ ដែលដឹកនាំដោយប្រធានាធិបតី អង្គនីតិប្បញ្ញត្តិ និងអង្គតុលាការ។ នីតិប្រតិបត្តិ មានលេខាធិការគណៈរដ្ឋមន្ត្រី ការិយាធិបតេយ្យថ្នាក់ជាតិ និងយោធា។ នីតិប្បញ្ញត្តិ ឬសភាមានព្រឹទ្ធសភា

ដែលមានសមាជិកចំនួន២៨រូប និងសភាតំណាងរាស្ត្រ ដែលមានសមាជិកចំនួន២២០រូប។ តុលាការ មានតុលាការកំពូល សាលាឧទ្ធរណ៍ សាលាជំនុំជម្រះ និងតុលាការពិសេស (តុលាការអនីតិជន តុលាការគ្រួសារ ឬតុលាការទទួលបន្ទុក)។ អនុសាខានយោបាយរបស់រដ្ឋ មានខេត្ត ក្រុង ស្រុកនិងភូមិ។

សាធារណរដ្ឋកូរ៉េ ប្រព័ន្ធពហុបក្សតាមបែបប្រធានាធិបតី មានចរិកលក្ខណៈជាប្រជាធិបតេយ្យ ដែលមានការបែងចែកអំណាចរវាងអង្គបីនៃរដ្ឋាភិបាលថ្នាក់ជាតិ ពោលគឺមានអង្គនីតិប្បញ្ញត្តិ ប្រតិបត្តិ និងតុលាការ។ ប្រធានាធិបតី ត្រូវបានបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ និងមានអំណាចទូលំទូលាយ ។ នីតិប្រតិបត្តិ មានគណៈអភិបាល ក្រសួង ការិយាល័យរដ្ឋបាល និងការិយាល័យសេវាក្រៅជាដើម។ អង្គនីតិប្បញ្ញត្តិ មានសភាមួយដែលហៅថា រដ្ឋសភាជាតិ ដែលមានសមាជិកចំនួន២៥០រូប កើតចេញពីការបោះឆ្នោត និងសមាជិកចំនួន២៥៨រូប កើតពីការតែងតាំង។ អង្គតុលាការ មានតុលាការកំពូល សាលាឧទ្ធរណ៍ និងសាលាជំនុំជម្រះ ព្រមទាំងមានតុលាការពិសេស តុលាការអនីតិជន និងតុលាការគ្រួសារ។ រដ្ឋាភិបាលមូលដ្ឋាន ត្រូវបែងចែកជារដ្ឋាភិបាលមូលដ្ឋានជាន់ខ្ពស់ និងរដ្ឋាភិបាលមូលដ្ឋានថ្នាក់ក្រោម។ រដ្ឋាភិបាលជាន់ខ្ពស់ គឺជាអាជ្ញាធរស្វយ័តនៅមូលដ្ឋានដែលមានយុត្តាធិការទូលាយស្របទៅតាមដែនដី ចំណែកឯរដ្ឋាភិបាលថ្នាក់ក្រោម គឺជាអាជ្ញាធរមូលដ្ឋានកម្រិតមូលដ្ឋាន ។ ក្រុមប្រឹក្សាមូលដ្ឋានត្រូវបោះឆ្នោតដោយសេរី។

ប្រទេសស្រីលង្កា ៖ ប្រព័ន្ធរដ្ឋាភិបាលតាមបែបប្រជាធិបតេយ្យត្រូវគ្រប់គ្រងដោយរដ្ឋធម្មនុញ្ញឯកត្តរដ្ឋ។ អំណាចនីតិប្បញ្ញត្តិរបស់ប្រជាជន មានសភាដែលមានសមាជិកជាប់ឆ្នោតតាមមូលដ្ឋានមកពីគណបក្សនយោបាយ ចំណែកប្រធានាធិបតី ដែលជាប់ឆ្នោតចេញពីមណ្ឌលបោះឆ្នោតទូទាំងប្រទេស អនុវត្តអំណាចនីតិប្រតិបត្តិ។ សភាអនុវត្តអំណាចតុលាការ តាមរយៈតុលាការ និងសាលាជំនុំជម្រះផ្សេងៗ សម្រាប់គោលបំណងអធិបតេយ្យ។ទោះជាយ៉ាងណាក្ដី តុលាការកំពូល សាលាឧទ្ធរណ៍ និងតុលាការផ្សេងៗ រួចផុតពីអន្តរាគមន៍ពីខាងក្រៅ និងរក្សាឯករាជ្យភាពតុលាការ។ អនុសាខានយោបាយនៅថ្នាក់រដ្ឋាភិបាលផ្សេងៗ រួមមានក្រុមប្រឹក្សាខេត្ត និងអាជ្ញាធរមូលដ្ឋានដែលកើតចេញពីការបោះឆ្នោត ដូចជាក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុងប្រជុំជន និងក្រុមប្រឹក្សាជនបទ ដែលដឹកនាំដោយចៅហ្វាយក្រុង តែងតាំងឬប្រធាន និងមានគណៈកម្មាធិការមួយចំនួន។

ប្រទេសថៃឡង់ដ៍ ៖ សភាមានពីរថ្នាក់ គឺសភាតំណាងរាស្ត្រដែលមានសមាជិកចំនួន៥០០នាក់ និងព្រឹទ្ធសភា ដែលមានសមាជិកកើតចេញពីការបោះឆ្នោតចំនួន២០០នាក់។ សភាតំណាងរាស្ត្រ មានតំណាងសមាមាត្រចំនួន១០០រូប និងសមាជិកសភាចំនួន៤០០រូប ដែលកើតចេញពីការបោះឆ្នោតដោយផ្ទាល់ចេញពីមណ្ឌលបោះឆ្នោតចំនួន៤០០។ រដ្ឋបាលកណ្ដាល មានការិយាល័យនាយករដ្ឋមន្ត្រី ក្រសួងចំនួន១៣ និងរដ្ឋមន្ត្រីចំនួន៣៦រូប ដែលបង្កើតបានជាគណៈរដ្ឋមន្ត្រី។ អភិបាលខេត្ត អភិបាលស្រុក

និងអភិបាលរង គឺទទួលផ្នែករដ្ឋបាលខេត្ត។ រដ្ឋាភិបាលមូលដ្ឋាននៅទីប្រជុំជន ត្រូវអនុវត្តតាមរយៈរដ្ឋបាលទីក្រុងបាងកក មជ្ឈ-មណ្ឌលនានា ដែលគ្រប់គ្រងក្រុងនៅតាមខេត្តនិងក្រុងប៉ាតាយ៉ា។ រដ្ឋាភិបាលមូលដ្ឋាននៅជនបទ រួមមានអង្គការរដ្ឋបាលខេត្ត អង្គការរដ្ឋបាលតំបន់ និងអង្គការរដ្ឋបាលសុខាភិបាល។

## IV-អភិបាលកិច្ចមូលដ្ឋាន

ផ្នែកខាងដើម បានលើកឡើងអំពីបញ្ហារចនាសម្ព័ន្ធ និងស្ថាប័ន ។ ការត្រួតពិនិត្យពីថ្នាក់កណ្ដាល ទៅលើរដ្ឋាភិបាលមូលដ្ឋានត្រូវបានកំណត់ដោយការត្រួតពិនិត្យហិរញ្ញវត្ថុ នៅក្នុងករណីមួយចំនួន តាមរយៈការតែងតាំងមន្ត្រីជាន់ខ្ពស់ និងអ្នកនយោបាយមូលដ្ឋាន ការកំណត់អំណាច មុខងាររបស់អាជ្ញាធរមូលដ្ឋាន និងទំនាក់ទំនងមិនល្អ រវាងថ្នាក់រដ្ឋាភិបាល។ ផ្នែកនេះនឹងផ្ដោតលើការផ្លាស់ប្ដូរអភិបាលកិច្ច។ ស្វ័យភាពមានវិសាលភាពពីរ គឺស្វ័យ-ភាពរដ្ឋបាលហិរញ្ញវត្ថុ និងស្វ័យភាពអភិបាលកិច្ច។ រដ្ឋបាលអាចត្រូវបានធ្វើប្រតិភូកម្ម ជាមុខងារ ជាភ្នាក់ងារ ប៉ុន្តែអភិបាលកិច្ច ជាពិសេសស្វ័យគ្រប់គ្រងមូលដ្ឋាន ត្រូវមានមូលដ្ឋាននៅមូលដ្ឋាន ឬនៅជិតប្រជាពលរដ្ឋបំផុត។អភិបាលកិច្ចមូលដ្ឋាន គឺនិយាយពីការត្រួតពិនិត្យចុងក្រោយ ។ អភិបាលកិច្ច គឺលទ្ធភាពឈានទៅធ្វើសេចក្ដីសម្រេចនៅមូលដ្ឋាន ដោយគ្មានការត្រួតពិនិត្យពីរដ្ឋាភិ-បាលថ្នាក់លើ។ អភិបាលកិច្ចមូលដ្ឋាន ត្រូវនិយាយអំពីស្វ័យភាពមូលដ្ឋាន ការបោះឆ្នោតនៅមូលដ្ឋាន សង្គមស៊ីវិល និងការចូលរួមរបស់ប្រជាពលរដ្ឋ។

### ក-ស្វ័យភាពមូលដ្ឋាន

ធម្មនុញ្ញពិភពលោកស្ដីពីស្វ័យគ្រប់គ្រងមូលដ្ឋានដែលត្រូវបានព្រាងឡើង គឺផ្អែកលើគោលការណ៍ស្វ័យភាព គោលការណ៍បែងចែងមុខងារ និងភាពនៅជិតនឹងប្រជាពលរដ្ឋបំផុត។ សំណៅអត្ថបទនេះ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ។ មាត្រា៣ និងមាត្រា៤ នៃសេចក្ដីព្រាង ដែលផ្ដល់ជូនសម្រាប់កិច្ចពិភាក្សា នៅខែឧសភា ឆ្នាំ១៩៩៨ បានគូសបញ្ជាក់ពីគោលគំនិត និងវិសាលភាពស្វ័យគ្រប់គ្រងមូលដ្ឋាននេះតែម្ដង ពោលគឺ៖

មាត្រា៣- គោលគំនិតស្ដីពីស្វ័យគ្រប់គ្រងមូលដ្ឋាន

-ស្វ័យគ្រប់គ្រងមូលដ្ឋានរៀបរាប់ពីសិទ្ធិនិងលទ្ធភាពរបស់អាជ្ញាធរមូលដ្ឋាន នៅក្នុងក្របខ័ណ្ឌច្បាប់ ដើម្បីធ្វើនិយតកម្ម និងគ្រប់គ្រងចំណែកការងារសាធារណៈសំខាន់ៗ ដែលឋិតក្រោមការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ និងដែលជាផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

-ក្រុមប្រឹក្សា ត្រូវអនុវត្តសិទ្ធិ ឬធ្វើការប្រជុំក្រុមប្រឹក្សាដែលមានសមាជិក កើតចេញពីការបោះឆ្នោតដោយសេរី ដោយសន្លឹកឆ្នោតសម្ងាត់ ដោយផ្ទាល់ ដោយស្មើភាព ការបោះឆ្នោតជាសាកល និងដែលអាចមានអង្គនីតិប្រតិបត្តិ ទទួលខុសត្រូវការងារនេះ។

មាត្រា៤-វិសាលភាពស្វ័យគ្រប់គ្រងមូលដ្ឋាន

-អាជ្ញាធរមូលដ្ឋាន ត្រូវមានឆន្ទានុសិទ្ធិពេញលេញ ដើម្បីធ្វើការផ្ដួចផ្ដើមគំនិតរបស់ខ្លួន ចំពោះគ្រប់បញ្ហាទាំងអស់ ដែល

កំណត់ដោយច្បាប់ ស្របតាមសមត្ថកិច្ចរបស់ខ្លួន ដែលមិនមែនជាសមត្ថកិច្ចរបស់អាជ្ញាធរផ្សេងទៀត។

-អំណាច និងការទទួលខុសត្រូវជាមូលដ្ឋានរបស់អាជ្ញាធរមូលដ្ឋាន ត្រូវតែមានចែងដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់ ។ តែយ៉ាងណាក៏ដីបទប្បញ្ញត្តិនេះ មិនត្រូវហាមឃាត់ការកំណត់អំណាច និងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន សម្រាប់គោលបំណងជាក់លាក់នោះទេ។

-យោងតាមគោលការណ៍បែងចែកមុខងារ អាជ្ញាធរទាំងឡាយ ដែលនៅជិតនឹងប្រជាពលរដ្ឋបំផុត ជាទូទៅត្រូវទទួលខុសត្រូវជាសាធារណៈ។ នៅក្នុងស្មារតីនេះ ការបែងចែកការទទួលខុសត្រូវដល់អាជ្ញាធរមួយណាក៏ដោយ ត្រូវតែផ្អែកទៅលើតម្រូវការឱ្យមានភាពស័ក្តិសិទ្ធិខាងផ្នែកបច្ចេកទេស ឬសេដ្ឋកិច្ច។

-អំណាចដែលផ្តល់ឱ្យអាជ្ញាធរមូលដ្ឋាន តាមធម្មតាត្រូវតែមានលក្ខណៈដោយឡែក និងពេញលេញ។ អំណាចមិនត្រូវបានធ្វើឱ្យអន្តរាយ និងមិនអាចដាក់កម្រិត ដោយអាជ្ញាធរមួយទៀតទេ លើកលែងតែមានចែងក្នុងច្បាប់។

-កន្លែងណាដែលអាជ្ញាធរកណ្តាល ឬតំបន់ ធ្វើប្រតិភូកម្មអំណាចឱ្យរដ្ឋាភិបាលមូលដ្ឋាន អាជ្ញាធរមូលដ្ឋាន ត្រូវតែបានទទួលឆន្ទានុសិទ្ធិ ក្នុងការសម្របសម្រួល ការអនុវត្តរបស់ខ្លួន ឱ្យស្របតាមលក្ខខណ្ឌនៅមូលដ្ឋាន។

-អាជ្ញាធរមូលដ្ឋានត្រូវតែមានការចូលរួមតាមពេលកំណត់ និងតាមរបៀបត្រឹមត្រូវក្នុងការធ្វើផែនការ និងដំណើរការធ្វើសេចក្តី

សម្រេចចំពោះគ្រប់បញ្ហាទាំងអស់ ដែលមានផលប៉ះពាល់ដល់ពួកគេ។

ក្នុងន័យនេះ រដ្ឋាភិបាលមូលដ្ឋាននៅប្រទេសញូហ្ស៊ីឡែន ហាក់ដូចជាមានស្វ័យភាពធំបំផុត ដែលរដ្ឋាភិបាលកណ្ដាល បានធ្វើការផ្ទេរអំណាច និងការទទួលខុសត្រូវសំខាន់ៗឱ្យថ្នាក់មូលដ្ឋាន។

រដ្ឋាភិបាលអូស្ត្រាលី៖ ប្រព័ន្ធនេះ ជារឿយៗត្រូវបានកំណត់ដោយហេតុថា រដ្ឋាភិបាល Commonwealth ធ្វើការប្រមូល និងកាន់កាប់ថវិកាទាំងអស់ រដ្ឋទាំងឡាយក្ដោបក្ដាប់អំណាចទាំងអស់ ហើយរដ្ឋាភិបាលមូលដ្ឋាននៅមានបញ្ហាគ្រប់បែបយ៉ាង។

រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ៖ នៅមានការស្ទាក់ស្ទើរក្នុងការផ្ទេរអំណាច និងនៅរក្សាការគ្រប់គ្រងលើកិច្ចការមូលដ្ឋានរហូតដល់គ្រប់គ្រងរថយន្ត និងអាហារថ្ងៃត្រង់ផង ។ តែយ៉ាងណាក៏ដោយ ក៏នៅមានការលើកលែងដែរថា ប្រធានាធិបតីនឹងផ្ដល់អំណាចដល់ថ្នាក់មូលដ្ឋាន។

រដ្ឋាភិបាលចិន៖ ស្វ័យភាពមូលដ្ឋាន មានស្វ័យភាពរណបជាប្រភេទសេដ្ឋកិច្ចបញ្ហាមិនយុត្តិធម៌។ ពោលគឺ រដ្ឋាភិបាលថ្នាក់ក្រោម ត្រូវតែបំពេញភារកិច្ច ដែលទទួលបានពីរដ្ឋាភិបាលថ្នាក់លើ ហើយអ្វីដែលស្វ័យភាពមូលដ្ឋានត្រូវអនុវត្ត អ្វីដែលអាចធ្វើទៅបានលុះត្រាតែមានគោលការណ៍ណែនាំពីថ្នាក់លើ។ចំណុចនេះមាន លក្ខណៈខុសគ្នាពីគោលគំនិតស្ដីពីការបែងចែកមុខងារ ដែលស្វ័យភាពមូលដ្ឋាន ត្រូវបានលើកលែង នៅពេលដែលច្បាប់

មិនបានរាប់បញ្ចូលសមត្ថកិច្ចរបស់ពួកគេ ឬតម្រូវអាជ្ញាធរផ្សេងទៀតទេ។

រដ្ឋាភិបាលហ្វីលីពីន៖ ប្រព័ន្ធមជ្ឈការខ្លាំង ត្រូវបានបង្កើតឡើង ក្រោមរបបអាណានិគមអេស្ប៉ាញ ។ ការធ្វើឲ្យហ្វីលីពីនូបនីយកម្មនៃរដ្ឋាភិបាលថ្នាក់ជាតិ ត្រូវប្រព្រឹត្តទៅក្នុងកំឡុងរដ្ឋាភិបាលអាណានិគមរបស់សហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៩១រដ្ឋាភិបាលថ្នាក់ជាតិ បានឈានទៅរកស្វ័យភាពមូលដ្ឋាន និងវិមជ្ឈការ។ រដ្ឋាភិបាលកណ្តាល មានតួនាទីធ្វើគោលនយោបាយ និងកំណត់ស្តង់ដារស្របនឹងអំណាចត្រួតពិនិត្យទូទៅ។ រដ្ឋាភិបាលកណ្តាលមានអំណាចបណ្តេញចេញ ហើយអាចធ្វើដូច្នេះបាន ត្រូវផ្អែកលើមូលដ្ឋានប្រជាមតិគាំទ្រ។

រដ្ឋាភិបាលស្រីលង្កា ៖ គឺជាអង្គភាពរដ្ឋបាលតាមបែបប្រជាធិបតេយ្យ ស្របតាមគោលនយោបាយជាតិ និងការត្រួតពិនិត្យ ការគ្រប់គ្រងថ្នាក់ខេត្ត ប៉ុន្តែមិនមានស្វ័យភាពទេ។

ការសិក្សានេះ មិនត្រឹមតែចាប់អារម្មណ៍លើការផ្ទេរអំណាចពីរដ្ឋាភិបាលថ្នាក់លើទៅឱ្យថ្នាក់ក្រោម ឬការជំទាស់មិនផ្ទេរអំណាចនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការលើកទឹកចិត្ត និងជាដំណើរការទៀតផង។ប្រទេសញូហ្ស៊ីឡេន និងប៉ាគីស្ថាន បង្ហាញឧទាហរណ៍ផ្ទុយ ។ នៅញូហ្ស៊ីឡេន បានធ្វើការផ្ទេរអំណាច ចំណែកឯនៅប៉ាគីស្ថាន រដ្ឋាភិបាលកណ្តាលបានរក្សាអំណាច។ រីឯប្រទេសជប៉ុនគិតថា រដ្ឋាភិបាលមូលដ្ឋាន គឺមានសារសំខាន់ចំពោះលទ្ធិប្រជាធិបតេយ្យ ហើយរដ្ឋាភិបាលមូលដ្ឋានញូហ្ស៊ីឡេន បានទទួល

ឯករាជ្យភាព និងមានស្វ័យភាព តាមរយៈការធ្វើកំណែទម្រង់ ការគ្រប់គ្រងសេដ្ឋកិច្ចរបស់ញូហ្ស៊ីឡែន ដោយផ្អែកលើគោលការណ៍ភាពស័ក្តិសិទ្ធិនិងការបែងចែកមុខងារ។ ឯករាជ្យភាព និងស្វ័យភាពបន្តបន្ទាប់ បានកើតមានជាបឋម ដោយការធ្វើឱ្យរដ្ឋាភិបាលមូលដ្ឋានទទួលខុសត្រូវដោយផ្ទាល់ ចំពោះសហគមន៍មូលដ្ឋានរបស់ខ្លួន តាមរយៈដំណើរការធ្វើផែនការប្រចាំឆ្នាំ និងតាមរយៈការដកថវិកាពីថ្នាក់កណ្តាលដោយបង្ខំ ដើម្បីផ្តល់ថវិកាដល់មូលដ្ឋាន។ ជាពិសេស នៅពេលរដ្ឋាភិបាលមូលដ្ឋាន នៅមានតួនាទីត្រួតពិនិត្យ ប្រតិភូរដ្ឋាភិបាលមូលដ្ឋាន រដ្ឋាភិបាលកណ្តាលគ្មានអំណាចបណ្តេញក្រុមប្រឹក្សា ឬចាត់ចែងក្រុមប្រឹក្សាបានទេ ។ ដូចរបាយការណ៍ប្រចាំប្រទេសបានគូសបញ្ជាក់ថា សព្វថ្ងៃនេះការធ្វើកំណែទម្រង់មីក្រូសេដ្ឋកិច្ច គឺនៅពីក្រោយក្រុមប្រឹក្សា ហើយប្រទេសញូហ្ស៊ីឡែនយល់ឃើញបញ្ហាប្រឈម គឺជាការបង្កើតទស្សនវិស័យនិងអនាគតសម្រាប់រដ្ឋាភិបាលមូលដ្ឋាន។ អ្នកយុទ្ធសាស្ត្រខាងផ្នែកគ្រប់គ្រងស្នើថា ទស្សនវិស័យគួរតែគេបង្កើតឡើង ជាដំបូង ហើយបន្ទាប់មក គេត្រូវឱ្យមានការផ្លាស់ប្តូរជាចាំបាច់។ ក៏ប៉ុន្តែក្នុងករណីរបស់ញូហ្ស៊ីឡែន គឺមានលក្ខណៈផ្ទុយទៅវិញ។ ដូចជាតំបន់ Victoria (អូស្ត្រាលី) ការផ្លាស់ប្តូរ មានលក្ខណៈឆាប់រហ័សខ្លាំងក្លា និងគ្រប់កន្លែង។ បញ្ហាគឺថា តើការផ្លាស់ប្តូរបានកើតឡើងតាមវិធីសាស្ត្រវិចារណកម្មច្រើន ឬទេ ? ។ គេសង្ស័យថា បើគ្មានការផ្លាស់ប្តូរភ្លាមៗទេ គេអាចនិយាយបានយ៉ាងច្រើន ប៉ុន្តែការផ្លាស់ប្តូរពិតប្រាកដ គឺមានទំហំតិចតួចណាស់។

ទោះបីមានប្រវត្តិ យូរលង់ក៏ដោយ ក៏រដ្ឋាភិបាលមូលដ្ឋាន នៅក្នុងប្រទេសប៉ាគីស្ថាន អស់រយៈពេល៥០ឆ្នាំចុងក្រោយនេះ បានក្លាយជា ទំនិញមួយដែលមិនសូវចាំបាច់របស់រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ខេត្ត សម្បីរដ្ឋាភិបាលធ្វើប្រតិបត្តិយោធាក្រោមច្បាប់អាជ្ញាសឹកក្តី ឬតាមរយៈការបោះឆ្នោតតាមបែបប្រជាធិបតេយ្យក្តី។ នៅប៉ាគីស្ថានរដ្ឋាភិបាលមូលដ្ឋានដែលកើតចេញពីការបោះឆ្នោតនាពេលថ្មីៗនេះ ត្រូវបានស្តារឡើងវិញតែនៅក្នុងខេត្តមួយប៉ុណ្ណោះ ចាប់តាំងពីការរំលាយខ្លួននៅឆ្នាំ១៩៨៩។ នៅក្នុងខេត្តបីផ្សេងទៀត រដ្ឋាភិបាលមូលដ្ឋាន គឺឋិតក្នុងកណ្តាប់ដៃអ្នករដ្ឋបាល ដែលតែងតាំងដោយរដ្ឋាភិបាលថ្នាក់ខេត្ត ។ របាយការណ៍ប្រចាំប្រទេស ធ្វើការគូសបញ្ជាក់ថា រដ្ឋាភិបាលខេត្ត អាចបណ្តេញរដ្ឋាភិបាលមូលដ្ឋានដោយខ្លួនឯង ឬតាមរយៈការផ្តល់យោបល់ ជូនរដ្ឋាភិបាលសហព័ន្ធ។ វាប្រាកដណាស់ថា នេះគឺជាទំនាក់ទំនងមួយ ដែលប្រកបដោយប្រធានវិស័យខ្ពស់ លើសលប់លើរដ្ឋាភិបាលមូលដ្ឋាន ដោយសារតែគ្មានឯករាជ្យភាព ប្រើតែឥទ្ធិពលពីរដ្ឋាភិបាលខេត្ត។ របាយការណ៍ប្រចាំប្រទេសក៏ចង្អុលបង្ហាញថា មូលនិធិត្រូវផ្តល់ជូនអ្នកនយោបាយថ្នាក់កណ្តាល ដើម្បីចាយលើគម្រោងអភិវឌ្ឍនៅតាមមណ្ឌលបោះឆ្នោតរបស់ខ្លួន។ គេអាចលើកអំណះអំណាងបានថា អ្នកនយោបាយ មានការចាប់អារម្មណ៍ច្រើនជាងអ្នកការិយាល័យចំពោះតម្រូវការ ដែលលើកឡើងដោយអង្គបោះឆ្នោតនៅមូលដ្ឋានរបស់ខ្លួន និងថាការដាក់ឱ្យមានការទទួលខុសត្រូវទៅលើអ្នកនយោបាយ ដែលជាប់ឆ្នោតជួយធានាគណនេយ្យ-

ភាព ដល់សហគមន៍មូលដ្ឋាន។ និយាយដូច្នេះ ក៏ចេះតែថាបាន ក៏ប៉ុន្តែគេក៏ត្រូវផ្តល់អំណាចឱ្យបានច្រើនដល់អ្នកនយោបាយ និង បើកឱ្យមានការទទួលការគាំទ្រ និងឧបត្ថម្ភខាងផ្នែកនយោបាយ។

**ខ-៦ឯកជនភាវូបនីយកម្ម-សាជីវកម្មនីយកម្ម**

ទិដ្ឋភាពសំខាន់បំផុតនៃស្វ័យភាពមូលដ្ឋានជានិន្នាការផ្ទេរ អំណាចពីអាជ្ញាធរមូលដ្ឋានទៅឱ្យភ្នាក់ងារណាបខេត្តផ្សេងៗទៀត (ដែលជាកូនរបស់រដ្ឋាភិបាល) តាមរយៈការធ្វើសាជីវកម្មនីយកម្ម ឬ តាមរយៈការធ្វើឯកជនភាវូបនីយកម្ម ។ សាជីវកម្មនីយកម្ម សំដៅដល់ការរៀបចំឡើងវិញនូវអង្គការរដ្ឋ ដើម្បីប្រតិបត្តិការតាម គោលការណ៍អង្គការ សាជីវកម្មខាងវិស័យឯកជន។ ភ្នាក់ងារ សាធារណៈដែលមានលក្ខណៈជាអង្គការសាជីវកម្មជារឿយៗត្រូវ បានហៅថាជាភ្នាក់ងាររដ្ឋ។ ការធ្វើឯកជនភាវូបនីយកម្ម សំដៅ ដល់ការផ្ទេរមុខងារទាំងស្រុង ទៅឱ្យវិស័យឯកជន។ ការធ្វើដូច្នេះ អាចប្រព្រឹត្តទៅតាមរយៈការធ្វើកិច្ចសន្យាប្រគល់ជាមួយអាជ្ញាធរ មូលដ្ឋាន ដោយរក្សាទុកយន្តការត្រួតពិនិត្យមួយចំនួន ឬដោយ ផ្តល់មុខងារទាំងស្រុង ដោយការធ្វើការផ្តល់ទំនិញ និងសេវាតាម ទីផ្សារ។

ឯកជនភាវូបនីយកម្មនិងសាជីវកម្មនីយកម្ម ត្រូវបានអនុវត្ត និងជំរុញឱ្យរីកចម្រើនយ៉ាងខ្លាំងនៅញូហ្ស៊ីឡែន ។ នៅអូស្ត្រាលី បានចាប់ផ្តើមដើរតាមផ្លូវរបៀបនេះ ទោះបីជានៅដំណាក់កាល នេះមិនមានជំហានដូចគ្នាក៏ដោយ ក៏មានលក្ខណៈខ្លាំងក្លាណាស់។ អ្វី ដែលយើងចាត់ទុកថាជា "ការធ្វើពិសោធន៍ដ៏មហិមា"នោះ គឺ

ប្រទេសញូហ្ស៊ីឡែន ចាប់ផ្តើមធ្វើកំណែទម្រង់ពីថ្នាក់កណ្តាល ស្របតាមគោលការណ៍ថា រដ្ឋគឺជាអ្នកផ្តល់គោលនយោបាយទំនិញ និងសេវា តែនៅទីណា ដែលទីផ្សារមិនបានផ្តល់ជូនប្រជាពលរដ្ឋបានពិតប្រាកដ។ទីណាដែល រដ្ឋនៅតែធ្វើជាអ្នកផ្តល់សេវាដូចជាគោលនយោបាយទំនិញ និងសេវា ទាំងអស់នោះ ដែលមិនបានផ្ទេរទៅឱ្យទីផ្សារ តាមរយៈការធ្វើឯកជនភាវូបនីយកម្មទេ គោលការណ៍សាជីវកម្ម ត្រូវតែយកមកប្រើ។ នៅថ្នាក់មូលដ្ឋាន សាជីវកម្មនីយកម្ម បានកើតមានឡើងកាន់តែច្រើននៅទីណាដែលរដ្ឋាភិបាលមូលដ្ឋាន មានគោលនយោបាយតម្រង់ទៅកាន់ទីផ្សារច្រើនឡើង ហើយការផ្គត់ផ្គង់អាវុធជាតិផ្ទុះ ត្រូវបានញែកដាច់ដោយឱ្យសហគ្រាសពាណិជ្ជកម្មរដ្ឋ កាន់កាប់ទាំងស្រុង ជាអ្នកអនុវត្ត ហើយសកម្មភាពនានា ត្រូវបានធ្វើកិច្ចសន្យាប្រគល់ឱ្យក្រុមហ៊ុនឯកជន ។ គណនេយ្យភាព គឺទាមទារឱ្យផ្តល់ទៅសហគមន៍មូលដ្ឋាន ជាជាងឱ្យទៅរដ្ឋាភិបាលកណ្តាល តាមរយៈការពិគ្រោះយោបល់ល្អិតល្អន់ និងការធ្វើរបាយការណ៍។ រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់រដ្ឋរបស់អូស្ត្រាលី បានខិតខំរិះរកគោលនយោបាយ ធ្វើឯកជនភាវូបនីយកម្ម និងសាជីវកម្មនីយកម្ម ទោះបីមានការលើកលែងចំពោះរដ្ឋវិចតូរៀក៏ដោយ ក៏ការធ្វើឯកជនភាវូបនីយកម្មនៅមានលក្ខណៈតិចតួចនៅឡើយ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមូលដ្ឋានមានលក្ខណៈ ជាអង្គការសាជីវកម្មកាន់តែច្រើនឡើង ជាពិសេសដោយដាក់ឱ្យមានតំរូវជា "អ្នកទិញ ឬអ្នកផ្តល់សេវា"។

កំណែទម្រង់នេះ ត្រូវបានពង្រឹងដោយសារមានគោលនយោបាយប្រកួតប្រជែងថ្នាក់ជាតិ ដែលទាមទារឱ្យមានភាពប្រកួតប្រជែងទីផ្សារក្នុង ការផ្ដល់សេវានិងទំនិញ។ អ្នកស្រាវជ្រាវជនជាតិអូស្ត្រាលី បានសិក្សាស៊ីអំពីរដ្ឋាភិបាលមូលដ្ឋាន បានអធិប្បាយអំពីបទពិសោធន៍របស់រដ្ឋវិចតូរៀ ។ អាជ្ញាធរមូលដ្ឋានវិចតូរៀបានជំរុញឱ្យមានការប្រកួតប្រជែង ក្នុងការផ្ដល់សេវាជាច្រើនរបស់ខ្លួន។ ដើម្បីធ្វើការនៅក្នុងបរិយាកាសប្រកួតប្រជែងនេះបានអាជ្ញាធរមូលដ្ឋានបានបង្កើតក្រុមការងារផ្ទៃក្នុង ដែលជួយបំពេញការងារជូនក្រុមប្រឹក្សារបស់ខ្លួន ដោយមានការប្រកួតប្រជែង ជាមួយអង្គការខាងក្រៅ។ ដើម្បីយកឈ្នះលើក្រុមការងារខាងក្នុង គឺអ្នកម៉ៅការមកពីខាងក្រៅ ត្រូវមានសមត្ថភាពខ្លាំង។ មិនមែនអ្នកម៉ៅការមកពីខាងក្រៅទាំងអស់ សុទ្ធតែចេញពីផ្នែកឯកជននោះទេ ហើយពួកគេមិនមែនសុទ្ធតែជាអង្គការអូស្ត្រាលីទេ។ នៅក្នុងឧទាហរណ៍ជាច្រើន អ្នកម៉ៅការដែលមានជោគជ័យ មានក្រុមការងារក្រុមប្រឹក្សាញូហ្ស៊ីឡែន។ ជាទូទៅ គេមិនបានស្វាគមន៍ចំពោះការផ្លាស់ប្ដូរជាច្រើន ដូចជា ការកាត់បន្ថយកម្លាំងការងាររបស់រដ្ឋាភិបាលមូលដ្ឋាន។ អ្នកខ្លះបានពោលអះអាងថា ការដកការផ្ដល់សេវារបស់អាជ្ញាធរមូលដ្ឋាន បានជួយបង្កើនឱកាសធុរកិច្ចមូលដ្ឋានអ្នកខ្លះទៀត បានសម្ដែងការសោកស្ដាយចំពោះផលប៉ះពាល់ ដែលថា ការកាត់បន្ថយកម្លាំងការងារ ជាពិសេសគឺសម្រាប់សហគមន៍តូចៗ (Aulich 1997) ។ ក៏ប៉ុន្តែនិន្នាការទាំងអស់នេះមិនបានរាំងដល់ប្រទេសទាំងពីរនេះទេ។ រដ្ឋាភិបាលម៉ាឡេស៊ី

កំពុងខិតខំរិះរកគោលនយោបាយបញ្ឈប់ការត្រួតត្រា និងការធ្វើឯកជនភាវូបនីយកម្ម រួមទាំងការបញ្ឈប់ការចេញច្បាប់ត្រួតពិនិត្យអគារ ដោយផ្តល់ភារកិច្ចនេះទៅឱ្យអង្គភាពអាជីព ឬដោយធ្វើឯក-ជនភាវូបនីយកម្ម ការសំអាត និងការងារថែទាំសួនច្បារទៅឱ្យអ្នកម៉ៅការឯកជន ។ ដើម្បីតម្រង់ទិសទៅកាន់ទីផ្សារ កាន់តែច្រើនឡើង ដោយប្រើវិធីសាស្ត្រសាជីវកម្ម និងយកអតិថិជនជាធំនោះម៉ាឡេស៊ី កំពុងដាក់ឱ្យប្រើប្រាស់បច្ចេកទេសគ្រប់គ្រង តាមបែបអង្គការសាជីវកម្ម គឺការគ្រប់គ្រងគុណភាពទាំងស្រុង ការបម្រើអតិថិជន ស្របតាមស្តង់ដារ ISO 9000។ រហូតមកដល់ពេលថ្មីៗនេះ រដ្ឋាភិបាលមូលដ្ឋាននៅប៉ាគីស្ថាន មានបុគ្គលិកផ្ទាល់របស់ខ្លួន នៅក្នុងមន្ទីរពន្ធដារ ដើម្បីធ្វើការប្រមូលពន្ធ ប៉ុន្តែសព្វថ្ងៃនេះពន្ធត្រូវបានប្រមូលដោយអ្នកម៉ៅការ ដែលដេញថ្លៃបានដោយចំហ។ អ្នកម៉ៅការទាំងអស់ ដែលទាញយកផលប្រយោជន៍ ពីការធានាដែលមានកម្រិតទាបបំផុត ធ្វើខសន្យាក្នុងតម្លៃអប្បបរិមាណាមួយ ។ នៅប្រទេសស្រីលង្កា មុខងាររបស់អាជ្ញាធរមូលដ្ឋានមួយចំនួន ត្រូវបានផ្តល់ឱ្យ គណៈអភិបាល/អង្គការសាជីវកម្ម ឬអាជ្ញាធរ តាមលក្ខន្តិកៈដែលប្រតិបត្តិការ និងគ្រប់គ្រងដោយរដ្ឋាភិបាល ដើម្បីបម្រើសហាគមន៍មូលដ្ឋានដោយផ្ទាល់ ។ អ្នកដឹកនាំមូលដ្ឋាន បានបាត់បង់ឥទ្ធិពលលើរដ្ឋាភិបាលកណ្តាល ប៉ុន្តែការសិក្សាជាច្រើន ចង្អុលបង្ហាញថា សាធារណជនចង់ឱ្យមានអង្គការសាជីវកម្មរដ្ឋាភិបាល ដើម្បីគ្រប់គ្រងការប្រើប្រាស់សាធារណៈដូចជាទឹក និងអគ្គិសនី ។ ស្ថានភាពនៅតាមភូមិនៅតំបន់ទីក្រុង

របស់ប្រទេសហ្វីជី បានបង្វែរការចាប់អារម្មណ៍លើឯកជនភាវូបនីយកម្មវិញ។ ដោយហេតុថា ភូមិទាំងឡាយមិនបង់ពន្ធឱ្យក្រុង ហើយក្រុមប្រឹក្សាធ្វើតែការងារចំពោះមុខ ហេតុនេះពួកគេសម្លឹងមើលអ្នកមៅការឯកជន ដើម្បីជួយផ្តល់សេវា ដូចជាការប្រមូលសំរាមជាដើម។ សាជីវកម្មនីយកម្ម និងឯកជនភាវូបនីយកម្ម មានសញ្ញាល្អ សម្រាប់ស្វ័យគ្រប់គ្រងមូលដ្ឋាន ដោយហេតុថា វាអាចជួយដល់ការធ្វើសេចក្តីសម្រេចនៅមូលដ្ឋាន ប៉ុន្តែមិនចាំបាច់ត្រូវតែមានអភិបាលកិច្ចមូលដ្ឋាន ឬប្រជាធិបតេយ្យមូលដ្ឋានទេ។ ដូចដែលយើងបានពិភាក្សាពីខាងដើមមកហើយថា ទីណាដែលមានគណៈកម្មាធិការមូលដ្ឋាន នៅក្នុងអង្គការចំណុះរដ្ឋ ពេលនោះសមាជិកភាពជាធម្មតាឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ និងជំនាញការពិសេស ជាជាងសហគមន៍ ដែលប្រមូលផ្តុំដោយប្រជាពលរដ្ឋ។ សមាជិកភាពភាគច្រើនបំផុត ត្រូវបានតែងតាំង ជាជាងកើតចេញពីការបោះឆ្នោតនិងចេញពីសហគមន៍។ទំនោរទាំងអស់នេះ គឺសំដៅបង្កើតគណៈកម្មាធិការ និងក្រុមប្រឹក្សា ទោះបីមានសមាជិកភាពមូលដ្ឋានក៏ដោយ ក៏បង្ហាញពីការស្វាគមន៍វិធីសាស្ត្រប្រើប្រាស់ជំនាញអ្នកគ្រប់គ្រង ។ នេះគឺជាវប្បធម៌ត្រួតពិនិត្យបច្ចេកទេស ដែលលើកឡើងពីព័ត៌មាន គឺមិនមែនជាការវិនិច្ឆ័យចាញ់-ឈ្នះទេ ។ ការធ្វើសេចក្តីសម្រេច ត្រូវបានផ្តល់ទៅឱ្យក្រុមអ្នកជំនាញផ្នែកបច្ចេកទេស ឬអ្នកដែលមានផលប្រយោជន៍ពិសេស។ តួនាទីរបស់ពួកគេក្នុងការធ្វើសេចក្តីសម្រេច គឺមានសារសំខាន់ ប៉ុន្តែនឹងមិនឆ្លុះបញ្ចាំងមតិយោបល់និងតម្លៃទូទៅរបស់សហគមន៍

ទេ។ នេះអាចជាការធ្វើសេចក្ដីសម្រេចនៅមូលដ្ឋាន មិនមែនជាអភិបាលកិច្ចមូលដ្ឋានទេ។

**គ-ការបោះឆ្នោតមូលដ្ឋាន**

-មាត្រា៣ នៃសេចក្ដីព្រាងធម្មនុញ្ញពិភពលោកស្ដីពីស្វ័យគ្រប់គ្រងមូលដ្ឋាន ចែងអំពីសិទ្ធិបោះឆ្នោតរបស់មូលដ្ឋាន។

-មាត្រា៣ នៃគោលគំនិតស្ដីពីស្វ័យគ្រប់គ្រងមូលដ្ឋាន

១-ស្វ័យគ្រប់គ្រងមូលដ្ឋាន រៀបរាប់អំពីសិទ្ធិ និងលទ្ធភាពរបស់អាជ្ញាធរមូលដ្ឋាននៅក្នុងក្របខ័ណ្ឌច្បាប់ ដើម្បីធ្វើនិយតកម្ម និងគ្រប់គ្រងចំណែកការងារសាធារណៈសំខាន់ៗ ដែលឋិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ និងជាផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

២-ក្រុមប្រឹក្សាត្រូវអនុវត្តសិទ្ធិ ឬធ្វើការប្រជុំក្រុមប្រឹក្សាដែលមានសមាជិក កើតចេញពីការបោះឆ្នោតជាសាកល ដោយសេរី ដោយសន្លឹកឆ្នោតសម្ងាត់ ដោយផ្ទាល់ ដោយស្មើភាព និងមានអង្គនីតិប្រតិបត្តិ ដែលទទួលខុសត្រូវការងារនេះ។

ភាពប្រាកដប្រជានៃសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឬសភាមូលដ្ឋាននេះ មានលក្ខណៈផ្សេងពីគ្នាទូទាំងតំបន់ ។ នៅគីហ្ស៊ីស្ថាន មូលដ្ឋានត្រូវបានបោះឆ្នោត ដោយប្រជាពលរដ្ឋរបស់ខ្លួន ដោយផ្អែកលើសិទ្ធិបោះឆ្នោតទូទៅ ដោយស្មើភាព និងដោយផ្ទាល់ ដោយសន្លឹកឆ្នោតសម្ងាត់ ទោះបីភាពជាអ្នកដឹកនាំរដ្ឋបាលរដ្ឋ និងក្រុង Bishkek ឋិតក្រោមការត្រួតពិនិត្យចុងក្រោយរបស់ប្រធានាធិបតីគីហ្ស៊ីស្ថាន។ ការចូលរួមនយោបាយ គឺជាខ្លឹម

សារសំខាន់ក្នុងការចូលរួមរបស់ប្រជាជន ។ នៅប្រទេសចិន សហគមន៍នានា បោះឆ្នោតជ្រើសរើសសភាតាមសហគមន៍របស់ខ្លួន ដែលសភានេះជាអ្នកជ្រើសរើសអ្នករដ្ឋបាលឃុំ សង្កាត់ ស្រុក ក្រុង និងខេត្ត។ នៅបង់ក្លាដេស តំណាងមូលដ្ឋាន និងចៅហ្វាយក្រុង និងខេត្តធំៗកាន់តែច្រើន ត្រូវបានជ្រើសរើសដោយផ្ទាល់ពីប្រជាជន។ បញ្ហាជាច្រើនជាប់ពាក់ព័ន្ធនឹងអភិបាលកិច្ចមូលដ្ឋាន។

ទី១-ត្រូវមានបទប្បញ្ញត្តិពិសេសចែងអំពីស្ត្រី។ ស្ត្រីនៅបង់ក្លាដេសអាចឈរឈ្មោះដណ្តើមអាសនៈ ដោយចំហរ ឬអ្នកបម្រុងសម្រាប់ពួកគេ ។ បទប្បញ្ញត្តិប្រហាក់ប្រហែលនេះ ក៏មានអនុវត្តនៅប្រទេសឥណ្ឌាដែរ។

ទី២-ការត្រួតពិនិត្យពីថ្នាក់កណ្តាល ទៅលើអ្នកជាប់ឆ្នោតគឺមានកម្រិត។ ការបោះឆ្នោតនៅហ្វីជីត្រូវបានត្រួតពិនិត្យរដ្ឋបាល និងនយោបាយ ពីថ្នាក់កណ្តាល ចាត់ចែងដោយគណៈកម្មការបោះឆ្នោតដែលសម្រេច អំពីចំនួនសមាជិកក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សាទាំងមូល និងសម្រាប់មណ្ឌលបោះឆ្នោត។ ឥណ្ឌាមានប្រព័ន្ធពីរពាក់ព័ន្ធនឹងសមាជិកក្រុមប្រឹក្សា ដែលកើតចេញពីការបោះឆ្នោត និងការតែងតាំង។ ចំពោះអង្គការសាធារណកម្មក្រុង ឬក្រុមប្រឹក្សាក្រុងនីមួយៗ សហគមន៍បោះឆ្នោតដោយផ្ទាល់ជ្រើស-រើសសមាជិកក្រុមប្រឹក្សា តាមចំនួនដែលបានកំណត់។ បន្ទាប់មកសមាជិកក្រុមប្រឹក្សាទាំងអស់នេះ ធ្វើការតែងតាំងសមាជិកក្រុមប្រឹក្សាបន្ថែម ដោយផ្អែកលើមូលដ្ឋានចំណេះដឹង ឬបទពិសោធន៍ពិសេសនៅក្នុងរដ្ឋបាលក្រុង ។ ប្រព័ន្ធពីរនេះ ជៀសវាងបញ្ហាធ្វើ

សេចក្តីសម្រេច ដែលបិតក្នុងដៃតំណាងជាប់ឆ្នោតដែល មិនអាចមានជំនាញនៅក្នុងវិស័យនេះ។ ប្រព័ន្ធនេះ ក៏ជៀសវាងការលើកឡើងពីការិយាធិបតេយ្យ ដែលការធ្វើសេចក្តីសម្រេច ត្រូវផ្តល់ជូនអ្នកជំនាញការ ដែលមិនមានគិតគូរឬមិនចាប់អារម្មណ៍នឹងតម្លៃ និងផលប្រយោជន៍សហគមន៍មូលដ្ឋាន។ ម៉ាឡេស៊ី មានរដ្ឋាភិបាលមូលដ្ឋានតាមបែបម៉ាឡេស៊ី ដោយដើរចេញពីគំរូមរតកអង់គ្លេស ទៅប្រើប្រព័ន្ធមជ្ឈការកាន់តែខ្លាំង ដោយផ្តល់អំណាចមានកម្រិត។ សមាជិកក្រុមប្រឹក្សា ត្រូវបានតែងតាំងដោយរដ្ឋាភិបាល ដើម្បីអង្គុយនៅក្នុងក្រុមប្រឹក្សាមូលដ្ឋាន។ សូម្បីរដ្ឋាភិបាលរដ្ឋ តែងតាំងសមាជិកក្រុមប្រឹក្សាក៏ដោយ ក៏សមាជិកក្រុមប្រឹក្សាអាចត្រូវបានចាត់ទុកជាតំណាងតំបន់ដែលប្រជាជនគាំទ្រ ឬដោយតំណាងសហគមន៍ធុរកិច្ច ឬក្រុមផលប្រយោជន៍គាំទ្រ ។

ទី៣-ជាមូលដ្ឋាន និយាយពីបញ្ហាបណ្តេញចេញ ឬដកហូតសិទ្ធិបោះឆ្នោត ។ ការត្រួតពិនិត្យចុងក្រោយផ្នែកនយោបាយ ត្រូវបានបង្ហាញច្រើននៅប្រទេសហ្វីជី នៅពេលបោះឆ្នោត ត្រូវបានព្យួរក្រោយពីរដ្ឋប្រហារយោធានៅឆ្នាំ១៩៨៧ ។ ប៉ាគីស្ថានផ្តល់នូវរូបភាពក្តីសង្ឃឹម ធ្វើឱ្យមានការបោះឆ្នោតឡើងវិញ ប្រឆាំងនឹងតថភាពនៃការស្ទាក់ស្ទើររបស់ថ្នាក់កណ្តាល ដែលមិនចង់ធ្វើការបោះឆ្នោត ។ យើងអាចស្រង់សម្តី ពីរបាយការណ៍ប្រចាំប្រទេសបាន គឺ៖ ហេតុផលអ្វី ? ដែលមិនបានរៀបចំធ្វើការបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលមូលដ្ឋាននឹងបើកបង្ហាញ។ ប្រសិនបើយើងក្រលេកមើលប្រវត្តិរដ្ឋាភិបាលមូលដ្ឋាន យើងនឹងជួបរឿងគួរឱ្យ

ចាប់អារម្មណ៍ថា ការបោះឆ្នោតត្រូវបានរៀបចំឡើងដោយរបបផ្តាច់ការយោធាប៉ាគីស្ថានចំនួនពីរ គឺរបប Ayub Khan និង Ziaul Haq ។ ចាប់ពីមធ្យោបាយផ្សេងៗទៀត សម្រាប់ឱ្យមានការចូលរួមពីសាធារណជនត្រូវបានបញ្ចប់ ក្រោមរបបផ្តាច់ការ ហើយការបោះឆ្នោតជ្រើសរើសសភាថ្នាក់ជាតិ និងថ្នាក់ខេត្ត មិនត្រូវបានអនុញ្ញាត ប្រហែលជាការបោះឆ្នោតជ្រើសរើស អង្គភាពមូលដ្ឋានគ្រាន់តែជាផែនការរបស់មេផ្តាច់ការប្រើប្រាស់ ដើម្បីឱ្យសាធារណជនមានការជឿជាក់ខ្លះក្នុងការចូលរួម។ គួរឱ្យចាប់អារម្មណ៍សូម្បីបិតនៅក្រោមរបបយោធាទាំងពីរក៏ដោយ ក៏ស្ថាប័នមូលដ្ឋានដែលកើតចេញពីការបោះឆ្នោត បានដើរតួដ៏មានប្រយោជន៍និងអំណោយផលដល់ផ្នែកជាច្រើននៃជីវិតប្រជាជន។ តែយ៉ាងណាក្តី ប្រសិនបើនិយាយពីលទ្ធិប្រជាធិបតេយ្យវិញ នៅពេលមានការបោះឆ្នោតសភាជាតិ និងសភាខេត្ត អង្គភាពមូលដ្ឋានដែលកើតចេញពីការបោះឆ្នោត បាត់បង់សារសំខាន់ភាគច្រើនរបស់ខ្លួន ហើយតួនាទីនិងសក្តានុពល ត្រូវបានខូចខាតយ៉ាងធ្ងន់ធ្ងរ ដោយតំណាងដែលកើតពីការបោះឆ្នោតចេញរបស់រដ្ឋាភិបាលថ្នាក់លើ។ ទោះជាយ៉ាងណាក្តី នេះគឺជាការពិត គឺថាសមាជិកសភាជាតិ និងសភាខេត្តជាច្រើន ត្រូវបានបោះឆ្នោតជ្រើសរើសមុនពេល ធ្វើជាក្រុមប្រឹក្សាមូលដ្ឋាន នៅពេលទម្រង់តំណាងផ្សេងទៀតមិនទាន់មាន។ ជាងនេះទៀត ការឧបត្ថម្ភ និងការផ្តល់ជំនួយដល់សមាជិកសភាខេត្តនិងសភាជាតិ ដោយធ្វើឱ្យរដ្ឋាភិបាលមូលដ្ឋានដើរផ្លូវវាង ជួយធ្វើឱ្យរដ្ឋាភិបាលមូលដ្ឋានកាន់តែមានជំហរទន់ខ្សោយថែមទៀត។

បើអាចធ្វើទៅបាន តាមរយៈការប្រើប្រាស់ សក្តានុពលរបស់រដ្ឋាភិបាលមូលដ្ឋានដ៏មានប្រសិទ្ធភាព តំណាងរបស់រដ្ឋាភិបាលថ្នាក់លើភាគីច្រើន នៅក្នុងចំណោមពួកគេសុទ្ធតែមានបទពិសោធន៍អំណាចនៅថ្នាក់ក្រោម ហើយធ្លាប់ដើរតួនាទីសំខាន់ នៅថ្នាក់មូលដ្ឋានមានអារម្មណ៍ថា ត្រូវតម្រាមកំហែងដោយលទ្ធភាព ដែលរដ្ឋាភិបាលថ្នាក់នេះ នឹងបំផ្លាញតួនាទី និងបុព្វសិទ្ធិថ្មីរបស់ពួកគេ។ ហេតុដូច្នេះ ពួកគេមានការស្ទាក់ស្ទើរក្នុងការសើរើស្ថាប័ននេះ។ ទោះបីលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ប៉ាគីស្ថានបានជួបប្រទះនូវសេង្គតិភាព និងឧបសគ្គយ៉ាងខ្លាំងក៏ដោយ ក៏ដំណើរការ គ្មានការរំខានក្នុងការចូលរួមនៅគ្រប់ថ្នាក់រដ្ឋាភិបាលទាំងអស់ អាចតាមពេលកំណត់ ធ្វើការផ្តួចផ្តើមដំណើរការ ដែលគួរធ្វើឱ្យគុណភាពនៃការចូលរួម និងការតំណាងបានកាន់តែប្រសើរឡើង នេះគឺជាអភិបាលកិច្ច ។ ដូចនេះ លក្ខខណ្ឌអប្បបរមា សម្រាប់លើកកម្ពស់រដ្ឋាភិបាល និងអភិបាលកិច្ច គឺថាការបោះឆ្នោត ត្រូវរៀបចំធ្វើតាមពេលកំណត់ជាទៀងទាត់នៅគ្រប់ថ្នាក់រដ្ឋាភិបាលទាំងអស់។

## V-ការចូលរួមរបស់សង្គមស៊ីវិល និងសហគមន៍

ស្វ័យគ្រប់គ្រងមូលដ្ឋាន មានន័យហួសពីរចនាសម្ព័ន្ធ និងឧបករណ៍របស់រដ្ឋាភិបាល ។ គឺរួមទាំងមានការចូលរួមរបស់ប្រជាពលរដ្ឋ ជាសមាគមស្ម័គ្រចិត្ត ជាបណ្តាញសម្ព័ន្ធភាព និងទម្រង់ផ្សេងៗទៀត ក្នុងទំនាក់ទំនង ដែលជួយដល់អភិបាលកិច្ចមូលដ្ឋាន។

ដើម្បីជាក់ច្បាស់ យើងសូមលើកសេចក្ដីព្រាងធម្មនុញ្ញពិភពលោក មកនិយាយម្ដងទៀត៖

មាត្រា១០-ការចូលរួមរបស់ប្រជាពលរដ្ឋ និងភាពជាដៃគូ

-អាជ្ញាធរមូលដ្ឋាន ត្រូវមានសិទ្ធិធ្វើការកំណត់ទម្រង់សមស្របចំពោះការចូលរួមរបស់ប្រជាជន និងសកម្មភាពប្រជាជនក្នុងការចូលរួមធ្វើសេចក្ដីសម្រេចចិត្ត និងក្នុងការបំពេញមុខងាររបស់ពួកគេ ក្នុងការដឹកនាំសហគមន៍។

-អាជ្ញាធរមូលដ្ឋាន ត្រូវតែមានអំណាចចងក្រង និងបង្កើតភាពជាដៃគូ ជាមួយគ្រប់វិស័យសង្គមស៊ីវិលទាំងអស់ ជាពិសេសអង្គការមិនមែនរដ្ឋាភិបាល និងអង្គការដែលមានមូលដ្ឋាននៅតាមសហគមន៍ និងជាមួយវិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗទៀតដែលមានការចាប់អារម្មណ៍។

**ក-តម្រូវការឱ្យមានការចូលរួម**

ការចូលរួមគឺទាមទារឱ្យមានទាំងសងខាង ។ អ្នកខ្លះមានអំណះអំណាងថា ប្រជាពលរដ្ឋគួរតែចូលរួមក្នុងកិច្ចការរបស់រដ្ឋ។ គេបានធ្វើការចាប់អារម្មណ៍និងលើកកម្ពស់សារសំខាន់ថាជាសិទ្ធិតាមបែបប្រជាធិបតេយ្យ ដូចជានៅប្រទេសចិន ការចូលរួម គឺជាការសំដែងមតិ និងជាលក្ខណៈពិសេស នៃប្រព័ន្ធប្រជាធិបតេយ្យសង្គមនិយម។ អ្នកខ្លះទៀតដូចករណីប្រទេសបង់ក្លាដេសបង្ហាញស្រាប់ថា ក្រុមសង្គមស៊ីវិល សព្វថ្ងៃកំពុងធ្វើដំណើរទៅមុខ ដើម្បីចាប់ផ្ដើមធ្វើសកម្មភាព និងលើកទឹកចិត្តឱ្យរដ្ឋាភិបាលមូលដ្ឋានចូលរួមជាមួយពួកគេ ។ នេះជាការឆ្លើយតបចំពោះការមិនធ្វើ

សកម្មភាព ឬអសមត្ថភាពរបស់រដ្ឋាភិបាលមូលដ្ឋាន ដើម្បីបង្កើតវិធីសាស្ត្រដោះស្រាយបញ្ហាឱ្យមានការផ្លាស់ប្ដូរ ។ ដូចគ្នានេះដែរ ការចូលរួមរបស់សាធារណជន ដែលមានការកើនឡើងនៅជប៉ុន បានបញ្ជាក់ពីការឆ្លើយតបជាសកម្មភាពរបស់ប្រជាពលរដ្ឋ ។

មានការពិភាក្សាច្រើនអំពីការចូលរួម ដែលអះអាងថា ប្រជាជននឹងចូលរួម ។ ការសន្និដ្ឋានបែបនេះ អាចមិនត្រឹមត្រូវ។

ឧទាហរណ៍គេបានប៉ងដោយមិនបានជោគជ័យក្នុងការធ្វើឱ្យប្រជាពលរដ្ឋចូលរួមកាន់តែច្រើន តាមរយៈក្រុមប្រឹក្សា អភិវឌ្ឍសហគមន៍នៅកូឡុំបូ។

លោកអ្នកអាចផ្ដល់យន្តការឱ្យប្រជាពលរដ្ឋ ចូលរួមបាន ប៉ុន្តែអ្នកមិនអាចបង្ខំឱ្យពួកគេធ្វើដូច្នោះទេ ។ អ្នកធ្វើរបាយការណ៍ប្រទេសស្រីលង្កា សំដែងការសោកស្ដាយថា ជូនកាលគេធ្វើការកត់សម្គាល់យ៉ាងខកចិត្តថា ការចូលរួមរបស់ប្រជាពលរដ្ឋ ចប់នៅក្រោយពីការបោះឆ្នោត ដោយរកវិធីឱ្យមានការចូលរួមពីសមាជិកខ្លាំងៗតាមបែបបវេណី ។ គេអាចនិយាយបានថា ប្រជាពលរដ្ឋពិតជាមិនចង់ចូលរួមទេ ។ ប៉ុន្តែស្រែកទាមទារសិទ្ធិដែលអាចចូលរួមបាន ប្រសិនបើឱ្យពួកគេជ្រើសរើស ។ម្យ៉ាងវិញទៀត ពួកគេចង់បានសិទ្ធិចូលរួម ប៉ុន្តែមិនចង់បានការទទួលខុសត្រូវក្នុងការចូលរួមនោះទេ។កត្តាភូមិសាស្ត្រ និងប្រជាជនក៏ជារូបភាពដ៏សំខាន់ដែលជួយកំណត់រូបភាពនៃការចូលរួមផងដែរ ។ ដូចជាករណីប្រទេសហ្វីជី ភាពនៅជិត និងការដែលសហគមន៍មូលដ្ឋាន អាចចូលជិតអ្នកនយោបាយថ្នាក់ជាតិរបស់ខ្លួនបាន អាចក្នុងទំហំណា

មួយ ធ្វើការបដិសេធសេចក្តីត្រូវការសម្រាប់សកម្មភាពពលរដ្ឋនៅតាមមូលដ្ឋាន។ ផ្ទុយទៅវិញគេយល់ឃើញថា អ្នកនយោបាយមូលដ្ឋាននៅប្រទេសឥណ្ឌា ប្រឈមមុខនឹងភារកិច្ចដ៏សែនរួញរាក្នុងការធ្វើឱ្យប្រជាជនចូលរួមច្រើនបែបនេះ។ តំបន់ធំៗ និងប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់ មានន័យថា ប្រជាជនតាមរយៈក្រុមតូចៗរបស់គេ អាចជាយន្តការដ៏មានប្រសិទ្ធភាព សម្រាប់តែឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋប៉ុណ្ណោះ។

**ខ-ក្រុមសង្គមស៊ីវិល**

របាយការណ៍របស់ប្រទេសម៉ាឡេស៊ី បានបង្ហាញពីរូបភាពចូលរួមទូទៅចំនួន៤ គឺតាមរយៈការពិគ្រោះយោបល់ ការចូលរួមដោយផ្ទាល់ ការចែករំលែកអំណាចនិងសកម្មភាពសហគមន៍។ ការលេចចេញនូវវណ្ណៈកណ្តាលកាន់តែធំឡើងៗ បានផ្តល់កំណើនចំណាប់អារម្មណ៍ ផលប្រយោជន៍ ក្រុមដាក់សម្ពាធ និងអង្គការមិនមែនរដ្ឋាភិបាល អង្គការបម្រើផ្នែកសង្គមដោយស្ម័គ្រចិត្ត ក្រុមតាមដានប្រជាពលរដ្ឋ អ្នកប្រើប្រាស់ សមាគមអ្នកជិតខាង និងអង្គការសង្គមការពារបរិស្ថាន។ តាមផ្នែកនីមួយៗ ក្រុមបែបនេះខិតខំស្វែងរកមធ្យោបាយ ចូលរួមក្នុងបញ្ហានានា ដែលទាក់ទងនឹងការគ្រប់គ្រងទីក្រុង ដូចជាការបំពុលបរិស្ថាន ការកែលម្អសោភ័ណភាព។ ការលើកកម្ពស់គុណភាពជីវិតរបស់អ្នកស្រុក និងការថែរក្សាបេតិកភណ្ឌរបស់សហគមន៍។ រដ្ឋាភិបាលម៉ាឡេស៊ី បានដាក់ដើមទុនក្នុងរឿងនេះ តាមរយៈការលើកកម្ពស់ និងគាំទ្រកម្មវិធីជំរុញសហគមន៍ ដូចជាកម្មវិធីយុទ្ធនាការស្រឡាញ់ទន្លេរបស់

អ្នកជាដើម ។ សហគមន៍នានា ត្រូវបានផ្ដល់កម្ចី បំពាក់ឧបករណ៍ ដូចជាឡូរី ផ្ដល់ការបណ្ដុះបណ្ដាលឱ្យចេះជួយខ្លួនឯង និងទទួលបានសេវាប្រចាំថ្ងៃ ។ ដូចដែលគេបានបង្ហាញឱ្យឃើញច្បាស់ អំពីការចូលរួមក្នុងគម្រោងកែលម្អសំណង់អាណាធិបតេយ្យ នៅប្រទេសបង់ក្លាដេសជាពិសេសការចូលរួមរបស់ស្ត្រី ពោលគឺការជំរុញឱ្យប្រជាពលរដ្ឋចូលរួម គម្រោងដែលគេអាចស្គាល់បានមានលក្ខណៈងាយស្រួល ជាងការបញ្ចុះបញ្ចូលឱ្យពួកគេជឿពីគោលគំនិតទូទៅ ស្ដីពីលទ្ធិប្រជាធិបតេយ្យនៃការចូលរួម។ រដ្ឋាភិបាលជប៉ុន បានទទួលស្គាល់ថា ដោយសារតែសង្គម បានបង្កើនភាពស្មុគ្រស្មាញកាន់តែច្រើន ហើយការគិត និងខ្លឹមសារនៃតម្លៃរបស់មនុស្ស មានលក្ខណៈផ្ទុយគ្នាកាន់តែច្រើន ហេតុនេះពួកគេត្រូវតែធ្វើការផ្ដួចផ្ដើមរកវិធីថ្មី ដើម្បីជំរុញសហគមន៍របស់ពួកគេ។ ពួកគេមិនពឹងផ្អែកលើវិធីចាស់បានទេ ការទទួលខុសត្រូវ គឺបិតនៅលើអាជ្ញាធរត្រូវបង្កើតយន្តការប្រកបដោយការច្នៃប្រឌិត សម្រាប់បង្កើតភាពជាដៃគូជាមួយសង្គមស៊ីវិល ។ នៅពេលគ្មានការចូលរួមអាជ្ញាធរមូលដ្ឋាន អាចនិយាយស្ដីបន្ទោស អំពីភាពស្ពឹកស្រពន់របស់សហគមន៍មូលដ្ឋាន ជាជាងការស្វែងយល់កង្វះខាត ផ្នែកបច្ចេកទេសដែលមិនទាន់សម័យរបស់អាជ្ញាធរ។

## ប្រអប់ទី៥ ៖ បច្ចេកទេសសម្រាប់ឱ្យមានការចូលរួម

-ការចូលរួមដោយផ្ទាល់នៅតាមទីក្រុង អាចធ្វើទៅបានតាមរយៈអង្គការមិនមែនរដ្ឋាភិបាល ដែលមានភារកិច្ចជាក់លាក់ដែលគិតគូរប្រយុទ្ធនឹងការងារអភិវឌ្ឍ ឬបញ្ហាដោះស្រាយមួយ

ចំនួននៅឥណ្ឌា

-ការចូលរួមដោយផ្ទាល់បន្តិចបន្តួចអាចប្រព្រឹត្តទៅបានតាមរយៈយន្តការផ្ទួចជាប្រព័ន្ធផ្សព្វផ្សាយ និងការសរសេរលិខិតទៅកាន់អ្នកសារព័ត៌មាន ប័ណ្ណប្រកាស និងសរសេរសៀវភៅនៅឥណ្ឌា

-បំណងជាផ្លូវការក្នុងការចូលរួម បានប្រព្រឹត្តតាមរយៈប្រព័ន្ធ មណ្ឌលដែលមានសមាជិក ដើរតួជាសវនការសាធារណៈពាក់ព័ន្ធក្នុងដំណើរការអភិវឌ្ឍនៅឥណ្ឌា

-វិធីដែលអនុវត្តភាគច្រើនបំផុត សម្រាប់ឱ្យសហគមន៍មូលដ្ឋានចូលរួម គឺតាមរយៈយន្តធ្វើផែនការ ដែលគេហៅថា ពីក្រោមឡើងលើនៅឥណ្ឌូនេស៊ី

-ការធ្វើសន្និសីទ ឬការជួបជុំគ្នាក្រៅផ្លូវការ ត្រូវប្រារព្ធធ្វើនៅតាមតំបន់នីមួយៗ និងការធ្វើអង្កេតតាមបញ្ជីសំណួរ ព្រមទាំងអាចលើកទឹកចិត្តប្រជាជនឱ្យបញ្ចេញមតិនិងគំនិតរបស់ខ្លួននៅជប៉ុន

-គណៈទីប្រឹក្សាសហគមន៍ នៅប្រទេសញូហ្ស៊ីឡែន ធ្វើប្រតិបត្តិការតាមតួនាទីពីរ។ ពួកគេបង្កការរៀបចំឱ្យមានការចូលរួមកាន់តែច្រើនឡើង សម្រាប់ប្រជាជនដែលមានការភ័យខ្លាចចំពោះអង្គការធំៗ។ ក្នុងនាមសហគមន៍ពួកគេក៏ត្រូវធ្វើការសង្ខេបអំពីការតាមដាន ការអនុវត្តការងាររបស់អាជ្ញាធរមូលដ្ឋាន

-ការចូលរួមដោយផ្ទាល់ ធ្វើឡើងតាមទម្រង់ពិគ្រោះយោបល់និងកិច្ចពិភាក្សាសង្គម ការសរសេរលិខិត និងការចូលទស្សនាអង្គការវដ្ឋ សមាជិកកម្មករ និងបុគ្គលិក (ករណីប្រទេសចិន)

-ញត្តិតវ៉ារបស់ប្រជាពលរដ្ឋការបោះឆ្នោតសំណូមពររបស់

អ្នកស្រុកសុំឱ្យមានការធ្វើសវនកម្ម និងស៊ើបអង្កេតការចូលរួមក្នុងគណៈកម្មាធិការជាដើម។ល។ នៅសាធារណរដ្ឋកូរ៉េ

-រូបភាពចូលរួមដ៏មានសារសំខាន់នៅក្នុងតំបន់ គឺការធ្វើប្រជាមតិ ឬទម្រង់ប្រហែលគ្នានឹងប្រជាធិបតេយ្យដោយផ្ទាល់

-ការប្រើប្រាស់តុលាការអភិបាលកិច្ច ឬតុលាការរដ្ឋបាល (មាត្រា២៧៦-២៨០)ដែលទទួលបន្ទុកដោះស្រាយវិវាទ រវាងប្រជាពលរដ្ឋ និងរដ្ឋ និងមន្ត្រីរដ្ឋ ។ ការិយាល័យសភាទទួលពាក្យបណ្ដឹងពលរដ្ឋ(Parliamentary Ombudsman) នឹងត្រូវបង្កើតឡើងដើម្បីទទួលពាក្យបណ្ដឹង និងញត្តិនានា។ គណៈកម្មការប្រឆាំងអំពើពុករលួយ ឯករាជ្យ ក៏នឹងត្រូវបង្កើតឡើងផងដែរដោយសភាដើម្បីធ្វើការស៊ើបអង្កេតនៅប្រទេសថៃឡង់ដ៍ ។

-ការចូលរួមដោយផ្ទាល់អាចធ្វើឡើងជាផ្លូវការ តាមរយៈការធ្វើប្រជាមតិ ការបោះឆ្នោត ញត្តិ ការចូលរួមកិច្ចប្រជុំគណៈកម្មាធិការ និងក្រៅផ្លូវការតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ក្រុមសកម្មភាពសហគមន៍ ជាដើមនៅអូស្ត្រាលី ។

**ក-ការបំពាក់សម្ភារសម្រាប់ឱ្យមានការចូលរួម**

រដ្ឋាភិបាលកណ្ដាលដែលចាត់ទុកការចូលរួមថា ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យជាតិថ្មីបំផុត ដែលមានការប្រឆាំងក្រុមស៊ីវិលបញ្ចូលគ្នា គឺមិនធានាឱ្យមានការចូលរួមប្រកបដោយជោគជ័យ ។ ដូចដែលយើងបានបង្ហាញនៅក្នុងរបាយការណ៍ប្រទេសថៃ ពួកគេផ្ដល់សក្ដានុពលតែទៅលើការចូលរួម។ គ្មានរចនាសម្ព័ន្ធស្ថាប័នណាមួយនឹងធានាឱ្យមានការចូលរួមប្រកបដោយន័យ

ខ្លឹមសារនៅពេលដែល សាធារណជនជាទូទៅមានចំណេះដឹងតិចតួច អំពីរដ្ឋាភិបាលមូលដ្ឋាន ហើយប្រព័ន្ធអប់រំនៅគ្រប់កម្រិតផលិតនិស្សិតដែលមានចំណេះដឹងតិចតួច ឬដែលគ្មានចំណេះដឹងអំពីការប្រព្រឹត្តទៅបញ្ហា និងកិច្ចការទូទៅរបស់រដ្ឋាភិបាលមូលដ្ឋាន ។ រដ្ឋាភិបាល មិនមែនគ្រាន់តែរៀបចំតិចនិកថ្មីជំរុញការចូលរួមប៉ុណ្ណោះទេ ប៉ុន្តែពួកគេត្រូវតែបំពាក់សម្ភារឱ្យសហគមន៍បានចូលរួមផងដែរ។ នេះគឺជាកត្តាដ៏សំខាន់ក្នុងការរៀបចំ បង្កើតមូលធនសង្គមរបស់សហគមន៍។

ដូចដែលបានបង្ហាញខាងលើជាច្រើន នូវអំណះអំណាងក្នុងរបាយការណ៍ទាំងអស់នេះ បង្ហាញពីភាពស្ទាក់ស្ទើរជាច្រើនរបស់រដ្ឋាភិបាលថ្នាក់លើ ក្នុងការបំពាក់ឧបករណ៍ឱ្យប្រជាពលរដ្ឋអាចចូលរួមជាមួយពួកគេបាន។ ស្ថានភាពនៅប្រទេសប៉ាគីស្ថានសបញ្ជាក់ពីបញ្ហារបស់ស្ថាប័នផ្លូវការ ដែលគ្រប់គ្រងដោយថ្នាក់កណ្ដាលចំពោះការចូលរួមរបស់សាធាណជនដែរ ទោះបីដើរតួនាទីលេចធ្លោយ៉ាងខ្លាំង នៅក្នុងជីវិតរបស់ប្រជាជននៅប៉ាគីស្ថានក៏ដោយ ក៏រដ្ឋាភិបាលមូលដ្ឋាន ដែលកើតចេញពីការបោះឆ្នោតនៅប៉ាគីស្ថាន បានបាត់រូបរាងអស់រយៈពេលជិតប្រាំមួយឆ្នាំ ។

**ខ-ការចូលរួមរបស់ក្រុមដែលបាត់បង់ផលប្រយោជន៍**

នៅក្នុងបុព្វកថានៃសេចក្ដីព្រាងធម្មនុញ្ញពិភពលោកបានរៀបរាប់ពីជំនឿយ៉ាងមុតមាំថា សមភាពយេនឌ័រ និងការរាប់បញ្ចូលនៅក្នុងសង្គម ត្រូវតែដើរទន្ទឹមគ្នានឹងលទ្ធិប្រជាធិបតេយ្យមូលដ្ឋាន និងការចូលរួម ហើយថាគោលដៅទាំងអស់នេះ ត្រូវពង្រឹងគ្នាទៅ

វិញទៅមក។ យោងតាមមូលដ្ឋានរបាយការណ៍ប្រចាំប្រទេសទាំងអស់ យើងសង្កេតឃើញថា ទាំងសមភាពយេនឌ័រ និងទាំងការរាប់បញ្ចូលក្នុងសង្គម មិនមានការរីកចម្រើនណាស់ណាទេ។

ការរាប់បញ្ចូលប្រជាជនជនជាតិដើមភាគតិច ក្នុងស្វ័យគ្រប់គ្រងមូលដ្ឋាន គឺជាចំណោទបញ្ហានៅប្រទេសអូស្ត្រាលី ហ្វីជី និងញូហ្ស៊ីឡែនទោះបីមានការរាប់បញ្ចូលបានល្អប៉ុណ្ណាក៏ដោយ។ ជនជាតិដើមហ្វីជី សម្តែងសេចក្តីរីករាយចំពោះឋានៈពិសេសក្រោមការទំនុកបម្រុង ពីមហាក្រុមប្រឹក្សាប្រមុខ។ ចំពោះជនជាតិដើម Aborigines របស់អូស្ត្រាលី និងជនជាតិដើម Maoris របស់ញូហ្ស៊ីឡែន អាចជាបញ្ហាការប្តេជ្ញាចិត្តផ្ទាល់ខ្លួន ជាជាងការរាប់បញ្ចូលក្នុងគន្លងស្ថាប័នអាណានិគមគ្រប់គ្រង។ ជាពិសេសសមាសភាពពហុវប្បធម៌នៃសហគមន៍អូស្ត្រាលី តម្រូវឱ្យមានការដាក់បញ្ចូលបន្ថែមទៀត។

បណ្តាប្រទេសជាច្រើន មានបទប្បញ្ញត្តិចែងជាក់លាក់សម្រាប់ការបោះឆ្នោតរបស់ស្ត្រី ហើយប្រទេសផ្សេងទៀតកំពុងតែធ្វើដំណើរតាមគន្លងនេះ ។ ការផ្លាស់ប្តូរមួយ ក្នុងការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស តាមរយៈការធ្វើច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៧៤របស់ឥណ្ឌានៅឆ្នាំ១៩៩២ បានបម្រុងទុកអាសនៈមួយចំនួន គឺមួយភាគបីសម្រាប់ស្ត្រី និងផ្នែកដែលទន់ខ្សោយនៅក្នុងអង្គភាពក្រុង ។ ប៉ាគីស្ថាន មានចែងបទប្បញ្ញត្តិឱ្យមានតំណាងដោយឡែកពីក្រុមមិនមែនមូស្លីម កសិករ កម្មករ និងស្ត្រី ទោះបីតំណាងនេះហាក់ដូចជាមិនមានន័យ បើគេមិនរៀបចំឱ្យមានការ

បោះឆ្នោតនោះ។ ការបោះឆ្នោតរបស់ស្ត្រីបង់ក្លាដេស រហូតមកដល់ពេលនេះមានលក្ខណៈប្រយោល។ គណៈកម្មការរដ្ឋាភិបាលមូលដ្ឋានរបស់រដ្ឋាភិបាលបច្ចុប្បន្ន បានស្នើឱ្យមានការបោះឆ្នោតជ្រើសរើសតំណាងស្ត្រី (តាមអាសនៈដែលបានបម្រុងទុក)ដោយផ្ទាល់ ដោយប្រជាពលរដ្ឋ នៅគ្រប់លំដាប់ថ្នាក់រដ្ឋាភិបាលមូលដ្ឋានទាំងអស់។

តុល្យភាពយេនឌ័រនិងការរាប់បញ្ចូលក្នុងសង្គម មិនអាចសម្រេចបានដោយងាយស្រួលនោះទេ ។ នៅប្រទេសស្រីលង្កា ចំណាយដ៏ច្រើន លើសលប់ក្នុងការរៀបចំការបោះឆ្នោត មិនសមនឹងភាពជាតំណាងរបស់ប្រជាជនក្រីក្រទេ។ សេដ្ឋកិច្ចកាន់តែខ្លាំងស្របគ្នានឹងកំណើនចំណូលត្រូវបានគេមើលឃើញថាជាដំណោះស្រាយមួយផ្នែក តាមរយៈការអនុញ្ញាតឱ្យប្រជាជនកាន់តែច្រើនផ្តល់មូលនិធិដល់យុទ្ធនាការឃោសនាបោះឆ្នោត ។ ការសម្រេចឱ្យបាននូវតុល្យភាពយេនឌ័រ អាចប្រឈមមុខនឹងបញ្ហាវប្បធម៌។ នៅស្រីលង្កាចន្លោះឆ្នាំ១៩៩១ និងឆ្នាំ១៩៩៧ តំណាងស្ត្រីគឺមានលក្ខណៈតិចតួចណាស់ទៅហើយ។ ហេតុផលចំពោះបញ្ហានេះ មានភាពស្ទាក់ស្ទើររបស់ពួកគេ ក្នុងការប្រកួតប្រជែងជាមួយបុរសនៅក្នុងគណបក្សនយោបាយផ្សេងៗ ទំហំចំណាយខ្ពស់ នៅក្នុងប្រព័ន្ធតំណាងសមាមាត្រសព្វថ្ងៃ មូលដ្ឋានវប្បធម៌ ដែលស្ត្រីមានភាពស្ទាក់ស្ទើរក្នុងការចូលរួម ក្នុងស្ថានភាពជម្លោះនយោបាយជាដើម។ល។ យុទ្ធនាការពុំរ៉ៃ ក៏មិនមែនជា "ចំណូលចិត្តរបស់ស្ត្រី" ទេ។

## VI-សមត្ថភាពរបស់មូលដ្ឋាន

ការសម្លឹងមើលតួនាទីថ្មីៗ សម្រាប់រដ្ឋាភិបាលមូលដ្ឋាននិងការផ្លាស់ប្តូរគំរូអនុវត្តពីការផ្តល់សេវា ទៅជាអ្នកសម្របសម្រួលកំណើននោះ គឺវាមានដំណើរល្អណាស់ ក៏ប៉ុន្តែការពេញចិត្តបែបនេះ ត្រូវតែសម្របតាមតថភាពរបស់រដ្ឋាភិបាលមូលដ្ឋានមួយចំនួនជាពិសេសរដ្ឋាភិបាលដែលតូចជាង ដើម្បីធ្វើការងារជាក់ស្តែងអ្វីក៏ដោយឱ្យកាន់តែច្រើនឡើង។ គេពិបាកនឹងរកមើលឃើញអាជ្ញាធរមូលដ្ឋាន ជាអ្នកសម្របសម្រួល អ្នកកំណត់គោលដៅ និងជានិយ័តករក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដើម្បីឱ្យពួកគេអាចចូលរួមវិភាគទានប្រកបដោយ ប្រសិទ្ធភាពក្នុងការប្រកួតប្រជែងរបស់ជាតិ នៅពេលដែលអាជ្ញាធរមូលដ្ឋាន មិនអាចមានសម្បីហិរញ្ញវត្ថុជាមូលដ្ឋាន សម្រាប់ទ្រទ្រង់ដំណើរការរបស់ខ្លួន នៅម៉ាឡេស៊ី ។ បទពិសោធន៍នៅប្រទេសស្រីលង្កា ក៏មានលក្ខណៈដូច្នេះដែរ។ ទោះបីមានច្បាប់បានផ្តល់អំណាចយ៉ាងទូលាយ ដើម្បីបង្កើតបរិយាកាសប្រកបដោយចីរភាព និងដែលអាចរស់បាននៅតំបន់ក្រុង ឬស្រុកក៏ដោយ ក៏អាជ្ញាធរមូលដ្ឋានមិនមានសមត្ថភាពសម្រេចគោលដៅនោះទេនៅស្រីលង្កា។ ដូចគ្នានឹងនៅប្រទេសប៉ាគីស្ថានដែរប្រទេសស្រីលង្កាទោះបីមានបទប្បញ្ញត្តិច្បាប់ និងការរៀបចំអង្គការសម្រាប់រដ្ឋាភិបាលមូលដ្ឋាន ដើម្បីបំពេញតួនាទីធំធេងក៏ដោយ ក៏តថភាពជាក់ស្តែងគឺថា ក្រុមប្រឹក្សាមូលដ្ឋានជាក់ស្តែងមិនអាចបំពេញមុខងាររបស់ខ្លួនបាន ដូចជាសេវាប្រមូលសម្រាមការថែទាំផ្លូវថ្នល់ និងការបំភ្លឺផ្លូវជាដើមនៅស្រីលង្កា។

របាយការណ៍របស់ប្រទេសបង់ក្លាដេស ដែលស្រង់សម្ដីលោកសាស្ត្រាចារ្យ Ahmed ផ្ដោតយ៉ាងសំខាន់លើប្រសិទ្ធភាពនៃ"រដ្ឋបាលវិមជ្ឈការដែលមានការចូលរួម"។បរាជ័យនៅបង់ក្លាដេសមិនមែនកើតឡើង ដោយសារការគ្រប់គ្រងច្រើនហួសហេតុពីថ្នាក់កណ្ដាលទេ ប៉ុន្តែដោយសារតែអសមត្ថភាពរបស់ថ្នាក់មូលដ្ឋាន។ អាជ្ញាធរមូលដ្ឋាន អសមត្ថភាពលើវិស័យចំនួនបី សមត្ថភាពរដ្ឋបាលខ្សោយធនធាន ហិរញ្ញវត្ថុ និងធនធានមនុស្សមានកម្រិត និងការចូលរួមរបស់សាធារណជនតិចតួច។ (Ahmed 1997)សមត្ថភាពរដ្ឋបាលនិងការចូលរួមរបស់សាធារណជន ត្រូវបាននិយាយពីខាងដើមរួចហើយ។ នៅទីនេះយើងផ្ដោតការយកចិត្តទុកដាក់ជាបឋម លើការគ្រប់គ្រងធនធានមនុស្ស។

**ក-ធនធានមនុស្ស**

តម្រូវការអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបានទទួលស្គាល់នៅគ្រប់ប្រទេស ដែលយើងបានបង្ហាញនៅក្នុងអត្ថបទនេះ។ វិធីសាស្ត្រអភិវឌ្ឍធនធានមនុស្ស មានលក្ខណៈខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។

**ខ-ការតែងតាំង**

វិធីសាស្ត្រតែងតាំងបុគ្គលិកផ្ដើមចេញពីការត្រួតពិនិត្យនិងប្រព័ន្ធដ៏តឹងរឹង ដូចករណីអនុវត្តនៅប្រទេសចិន មានទីផ្សារការ-ងារដែលមានការបន្ធូរបន្ថយពីរដ្ឋ ដូចករណីអូស្ត្រាលី និងញូហ្ស៊ី-ឡែនដែរ។ សកម្មជនមូលដ្ឋាននៅប្រទេសចិន ត្រូវបានគ្រប់គ្រងតាមរយៈប្រព័ន្ធគណៈកម្មាធិការគណបក្សកុម្មុយនីស្ត រួមមានការ

តែងតាំង និងការត្រួតពិនិត្យ ដើម្បីគ្រប់គ្រងការិយាធិបតេយ្យ ការកែតម្រូវនិន្នាការដែលខុសឆ្គង និងដើម្បីបម្រើប្រជាពលរដ្ឋឱ្យអស់ពីចិត្តនៅប្រទេសចិន។ ផ្ទុយទៅវិញ ក្រុមប្រឹក្សាអូស្ត្រាលី និងញូហ្ស៊ីឡែនតែងតាំងមន្ត្រីនាយកប្រតិបត្តិ ប៉ុន្តែបុគ្គលិកដទៃទៀតគឺជានិយោជិតរបស់នាយកប្រតិបត្តិ(CEO)។ ប្រទេសផ្សេងទៀតគឺនៅចន្លោះករណីទាំងពីរនេះ។ ប្រទេសបង់ក្លាដេសមានការរៀបចំមន្ត្រីចម្រុះ ដែលកើតចេញពីការបោះឆ្នោតនិងការតែងតាំង។ នៅពេលដែលរដ្ឋាភិបាល មិនបានដាក់សញ្ញាសម្គាល់ មន្ត្រីដោយឡែកសម្រាប់រដ្ឋាភិបាលមូលដ្ឋានទេ អ្នករាជការ និងបុគ្គលិកបច្ចេកទេសមួយចំនួន នឹងបានទទួលការគាំទ្រសម្រាប់រយៈពេលជាក់លាក់តាមធម្មតាសម្រាប់រយៈពេលបីឆ្នាំ ។ ដោយមាននៅក្នុងផ្នែកនៃការធ្វើកំណែទម្រង់នៅស្រីលង្កា បុគ្គលិកត្រូវបានបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីខេត្ត ដែលក្លាយជាមន្ត្រីក្នុងមុខងារសាធារណៈថ្នាក់ខេត្ត។ ដោយសារប្រព័ន្ធនេះ ល្អជាងក្របខ័ណ្ឌរដ្ឋាភិបាលមូលដ្ឋានពីមុនការផ្លាស់ប្តូរក៏បង្កឱ្យមានភាពដែលអាចផ្ទេរបានរវាងអាជ្ញាធរមូលដ្ឋាននានា ។ ក្រៅពីប្រព័ន្ធកែលម្អនេះ អាជ្ញាធរមូលដ្ឋាននៅស្រីលង្កា នៅខ្វះមន្ត្រីជាន់ខ្ពស់ ត្រូវកាន់មុខងារដូចជាផ្នែកហិរញ្ញវត្ថុ រដ្ឋបាល និងវិស្វកម្ម។ ក្រុមប្រឹក្សាមួយចំនួនរបស់ហ្វីជី បានកត់សម្គាល់បញ្ហា ដែលក្រុមប្រឹក្សាថ្នាក់ទាបជាច្រើនកំពុងប្រឈមមុខ ពោលគឺអសមត្ថភាពមិនអាចទាក់ទាញនិងរក្សាបុគ្គលិកដែលមានសមត្ថភាពបាន។ បំណងដែលយើងលើករឿងនេះឡើង រួមមានការបែងចែកបុគ្គលិករវាងក្រុមប្រឹក្សា និងការ

ទាញយកប្រយោជន៍ ពីក្រុមផ្តល់សេវាពិគ្រោះយោបល់ដោយស្ម័គ្រចិត្ត ។ នៅប្រទេសហ្វីជី ករណីនេះដំណើរការតាមកម្មវិធីប្រតិបត្តិក្រៅប្រទេស (AESOP) របស់អូស្ត្រាលី ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី។ គម្រោងនេះធ្វើការផ្តល់អ្នកស្ម័គ្រចិត្តពីអូស្ត្រាលី ដែលមានជំនាញខ្ពស់ តាមធម្មតាជាមន្ត្រីអាជីពចូលនិវត្តន៍ ដើម្បីជួយដោះស្រាយបញ្ហាមួយចំនួនសម្រាប់មួយរយៈពេលខ្លី។ ក្រុមប្រឹក្សាដែលជាអ្នកទទួល គឺមានភារៈជួយផ្តល់ការស្នាក់នៅ និងការឧបត្ថម្ភការរស់នៅបន្តិចបន្តួច (ករណីប្រទេសហ្វីជី) ។ វិធីសាស្ត្រជម្នះលើចំណុចខ្សោយរបស់បុគ្គលិកមូលដ្ឋាន គឺត្រូវធ្វើឯកជនភាវូបនីយកម្ម ឬធ្វើកិច្ចសន្យាប្រគល់មុខងារណាមួយ ។ នៅម៉ាឡេស៊ី គេបានដឹងច្បាស់ហើយថា ដំណើរការជ្រើសរើសមន្ត្រី គឺមានសារសំខាន់ណាស់ ដោយផ្តោតការយកចិត្តទុកដាក់ដល់ការរើសបុគ្គលិកត្រឹមត្រូវ ស្របតាមមុខងារ និងការងារ។ បុគ្គលិក អាចជាបុគ្គលិកអចិន្ត្រៃយ៍ និងដែលអាចទទួលសោធននិវត្តន៍បាន ក្នុងនាមជាបុគ្គលិកអចិន្ត្រៃយ៍ និងមិនអាចទទួលសោធននិវត្តន៍បាន ក្នុងនាមជាបុគ្គលិកបណ្តោះអាសន្ន(សម្រាប់រយៈពេលជាក់លាក់ ឬផ្អែកលើមូលដ្ឋានកិច្ចសន្យាមួយខែម្តង) ជាបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត។ ក្នុងន័យទូលាយ នេះគឺជាប្រព័ន្ធតម្លើងថ្នាក់ ដែលមុននឹងតម្លើងជាបុគ្គលិកអចិន្ត្រៃយ៍ បុគ្គលត្រូវតែបម្រើការនៅមុខតំណែងខ្ពស់ជាងតំណែងដែលកំពុងបំពេញការងារ ដើម្បីបង្ហាញពីសមត្ថភាពការងាររបស់ពួកគេ។ ប្រាកដណាស់ថា គោលបំណងគឺដើម្បីធានាថា

រដ្ឋាភិបាលមូលដ្ឋាន ធ្វើការជ្រើសរើសមនុស្សបានត្រឹមត្រូវចាប់តាំងពីដំបូងមក។

**គ-ការបណ្តុះបណ្តាល និងការបំពាក់សម្ភារ**

ការតែងតាំងបុគ្គលិកគឺជារឿងសំខាន់តែការបណ្តុះបណ្តាលបន្ថែមនិងការបំពាក់សម្ភារក៏ជាការសំខាន់ដែរ។ ការធ្វើដូច្នេះគឺជាពិសេសសម្រាប់រយៈពេលផ្លាស់ប្តូរគំរូអនុវត្ត និងការធ្វើកំណែទម្រង់សំខាន់ៗ ។ គំរូអនុវត្តថ្មីសម្រាប់ស្វ័យគ្រប់គ្រងមូលដ្ឋាន នឹងតម្រូវឱ្យមានមនុស្សដែលមានចំណេះដឹង និងជំនាញថ្មីៗ ។ នេះគឺជាការដាក់សម្ពាធហួសហេតុ ទៅលើអាជ្ញាធរមូលដ្ឋានដូចជាអាជ្ញាធរមួយចំនួន អាជ្ញាធរនៅតែខិតខំដោះស្រាយចំណុចខ្សោយតាមចំណេះដឹងមូលដ្ឋាន ជំនាញដែលខ្លួនមាន ។ ផ្ទុយទៅវិញ នៅប្រទេសប៉ាគីស្ថាន ដោយសារតែកង្វះធនធាន ធ្វើឱ្យគេគ្មានថវិកាសម្រាប់ធ្វើការបណ្តុះបណ្តាល ពោលគឺមានន័យថា យ៉ាងហោចណាស់សម្រាប់មន្ត្រីថ្នាក់ក្រោម មានឱកាសបានទទួលការបណ្តុះបណ្តាលតិចតួចខុសគ្នាឆ្ងាយ (ករណីរបស់ប៉ាគីស្ថាន)។ ម៉ាឡេស៊ីកំពុងតែខិតខំដោះស្រាយបញ្ហាប្រឈមថ្មីៗទាំងអស់នេះ តាមរយៈការធ្វើកំណែទម្រង់រដ្ឋាភិបាលរបស់ខ្លួន ដោយញ៉ាំងឱ្យមានសមត្ថភាព និងការខិតខំកសាងសមត្ថភាពជាប្រចាំ ការធ្វើកំណែទម្រង់ការធ្វើសនវកម្ម និងការមានឆន្ទៈចង់រៀនដកពិសោធន៍ពីអ្នកដទៃ (ករណីម៉ាឡេស៊ី)។

កិច្ចខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ទាំងអស់នេះ គឺសំដៅបង្កើតឧត្តមភាពក្នុងមុខងារសាធារណៈដែលពឹងផ្អែកលើតម្លៃស្នូល

គឺគុណភាព ផលិតភាព សុចរិតភាព គណនេយ្យភាព សនរកម្ម វិន័យ និងវិជ្ជាជីវនិយម ។

**ប្រអប់ទី៦៖ ការផ្តោតលើកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាន**

នៅប្រទេសម៉ាឡេស៊ី៖

-ការផ្តល់សេវាដែលផ្តោតទៅលើអតិថិជន

-ការកែលម្អប្រព័ន្ធ និងនីតិវិធីធ្វើការ

-ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានកាន់តែធំធេងឡើង

-ការពង្រឹងទំនាក់ទំនងជាមួយវិស័យឯកជន

-ការធ្វើឱ្យប្រសើរឡើងនូវរចនាសម្ព័ន្ធគ្រប់គ្រង និងការគ្រប់គ្រងធនធានមនុស្ស

-ការលើកកម្ពស់គណនេយ្យភាព និង វិន័យ និង

-ការប្រកាន់ខ្ជាប់នូវតម្លៃ និងឧត្តមភាព។

ម៉ាឡេស៊ី មិនមែនជាប្រទេសមួយតែឯង ក្នុងការយកចិត្តទុកដាក់ការអភិវឌ្ឍតម្លៃស្នូលនេះទេ ។ ឥរិយាបថប្រកបដោយសីលធម៌ និងវិន័យ បុគ្គលិក គឺជាផ្នែកមួយនៃប្រព័ន្ធអភិវឌ្ឍធនធានមនុស្សរបស់ប្រទេសជប៉ុន។ ប្រទេសចិនក៏ដូចគ្នាដែរ សុទ្ធតែទទួលស្គាល់ ពីសារសំខាន់នៃការបង្កើនសង្វាក់ការសមត្ថភាពរបស់មន្ត្រី ទាំងផ្នែកមន្ត្រីនយោបាយ និងមន្ត្រីអាជីពរបស់ខ្លួន។ គេអាចសម្រេចការងារនេះបាន តាមរយៈការបណ្តុះបណ្តាល ទាំងនៅកន្លែងធ្វើការ និងទាំងនៅក្រៅកន្លែងធ្វើការ។

លទ្ធផលមួយ ក្នុងចំណោមលទ្ធផលជាច្រើនដែលកើតចេញពីវិធីសាស្ត្របន្ធូរបន្ថយការគ្រប់គ្រង ដោយយកទីផ្សារជាធំ

ក្នុងការគ្រប់គ្រងធនធានមនុស្ស ដូចជាគេបានអនុវត្តនៅប្រទេសអូស្ត្រាលី និងញូហ្ស៊ីឡែន គឺថាការបណ្តុះបណ្តាល ត្រូវតែធ្វើជាលក្ខណៈប្រព័ន្ធឱ្យកាន់តែទូលាយឡើង ។ ការបណ្តុះបណ្តាលរដ្ឋាភិបាលមូលដ្ឋាននៅអូស្ត្រាលី នៅតែរក្សាការបែងចែកតាមផ្នែក និងតាមការស្ម័គ្រចិត្ត ។ បំណងលើកទឹកចិត្តក្រុមប្រឹក្សាមូលដ្ឋាន ដើម្បីវិនិយោគលើការអប់រំ និងការបណ្តុះបណ្តាលឱ្យច្រើនមិនបានទទួលជោគជ័យទេ ។ ប្រព័ន្ធសមាហរណកម្មខ្សែបណ្តោយ ដូចដែលបានអនុវត្តនៅប្រទេសម៉ាឡេស៊ី បង់ក្លាដេស និងឥណ្ឌាជាដើម អនុញ្ញាតឱ្យមានវិធីសាស្ត្រថ្នាក់ជាតិ ដើម្បីធ្វើការអប់រំ និងបណ្តុះបណ្តាល។ ឥណ្ឌាមានវិទ្យាស្ថានបណ្តុះបណ្តាលថ្នាក់ជាតិដ៏ល្បីល្បាញជាច្រើន ដែលផ្តល់ការបណ្តុះបណ្តាលសម្រាប់ ទាំងបុគ្គលិកប្រតិបត្តិ និងទាំងបុគ្គលិកដែលកើតចេញពីការបោះឆ្នោត។ នៅម៉ាឡេស៊ី វិស័យរដ្ឋាភិបាលមូលដ្ឋាន គឺជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិតាមរយៈនាយកដ្ឋានមុខងារសាធារណៈ មន្ទីរបណ្តុះបណ្តាលរបស់ខ្លួន និងវិទ្យាស្ថានជាតិរដ្ឋបាលសាធារណៈ INTAN ។ ទោះបីវិទ្យាស្ថានINTAN មានការទទួលខុសត្រូវថ្នាក់ជាតិក៏ដោយ ក៏នៅមានវិទ្យាស្ថានបណ្តុះបណ្តាលជំនាញផ្សេងៗទៀត ហើយអាជ្ញាធរមូលដ្ឋាន ធ្វើយ៉ាងណាក៏ដោយ មានការលើកទឹកចិត្ត ដើម្បីបង្កើតក្រុមបណ្តុះបណ្តាលផ្ទាល់របស់ខ្លួន និងបង្កើតកម្មវិធីបណ្តុះបណ្តាលផ្ទាល់របស់ខ្លួនដែលជាផ្នែកមួយ នៃកិច្ចខិតខំប្រឹងប្រែងធ្វើការអភិវឌ្ឍធនធានមនុស្ស។ នៅហ្វីជីមាន ក្រុមប្រឹក្សាបណ្តុះបណ្តាលថ្នាក់ជាតិហ្វីជី សម្រាប់ដំណើរការបណ្តុះ

បណ្ដាលដែលអាជ្ញាធរមូលដ្ឋានទទួលបាន ចំណែកនៃការប្រមូលពន្ធស្មើនឹង១% នៃបៀវត្សសរុបប្រចាំឆ្នាំរបស់ខ្លួន ។ វិទ្យាស្ថានបច្ចេកវិទ្យារបស់ហ្វីជី ផ្ដល់ការអប់រំផ្លូវការលើមុខវិជ្ជា ដែលរដ្ឋាភិបាលមូលដ្ឋានត្រូវការចាំបាច់។

ការទទួលបានស្វ័យភាពមូលដ្ឋានកាន់តែច្រើននឹងទាមទារឱ្យមានការអប់រំ និងការបណ្ដុះបណ្ដាលកាន់តែច្រើនឡើង ដល់បុគ្គលិកដែលជាប់ឆ្នោតរបស់អាជ្ញាធរមូលដ្ឋាន។វិទ្យាស្ថានបណ្ដុះបណ្ដាលមួយចំនួន ដូចជាវិទ្យាស្ថាននៅប្រទេសឥណ្ឌាមានប្រពៃណីយូរលង់ក្នុងការបណ្ដុះបណ្ដាលបុគ្គលិកដែលជាប់ឆ្នោត។រឿងដែលសំខាន់ គឺថាប្រទេសផ្សេងទៀត ផ្ដល់ប្រភពធនធានប្រហាក់ប្រហែលគ្នា។ ការសិក្សាមួយនាពេលថ្មីៗនេះ បានសបញ្ជាក់ឱ្យឃើញថា ស្ទើរមានការខិតខំប្រឹងប្រែងច្រើននៅក្នុងការគ្រប់គ្រងវិស័យសាធារណៈក៏ដោយ ក៏នៅមានការសង្ស័យខ្លះអំពីផលចំណេញដែលបានមកពីការបណ្ដុះបណ្ដាល។ ហេតុផលនយោបាយមួយ ដែលអាចមាន គឺការបណ្ដុះបណ្ដាល ជាការឆ្លើយតបដ៏មានសុវត្ថិភាពចំពោះបញ្ហាធំៗដែលផ្សេងគ្នាទៅតាមសកម្មភាពការងារមិនល្អរបស់ការិយាធិបតេយ្យ និងធម្មានរូបភាពនយោបាយនៃរបបកាន់អំណាច។ ការបណ្ដុះបណ្ដាល គឺជាចម្លើយបច្ចេកទេស ដែលគ្មានការគំរាមកំហែង និងជាចម្លើយពេញនិយមច្រើនសម្រាប់ដោះស្រាយបញ្ហានយោបាយទាំងអស់នេះ។

អ្នកពាក់ព័ន្ធទាំងអស់ នឹងចង់ឱ្យមានការបណ្ដុះបណ្ដាល និងកោតសរសើរគុណតម្លៃនៃការបណ្ដុះបណ្ដាល ចំណែកឯអ្នក

ពាក់ព័ន្ធជាច្រើនអាចជំទាស់ ចំពោះការរៀបចំរចនាសម្ព័ន្ធឡើងវិញ ឬទម្រង់ការគ្រប់គ្រងឱ្យមានការចូលរួមកាន់តែច្រើនឡើង។

លោក Turner និង Hume បានលើកឡើងថា៖ ការអភិវឌ្ឍបុគ្គលិក និងផ្នែកបណ្តុះបណ្តាលរបស់អង្គការរដ្ឋាភិបាល គឺជារឿយៗមានភាពទន់ខ្សោយផ្នែកនយោបាយ ខ្វះបុគ្គលិកដែលមានសមត្ថភាព និងត្រូវគេចាត់ទុកថា ជាការកំណត់របស់អង្គការ ។

លោក Turner និង Hume ធ្វើការចង្អុលបង្ហាញពីអនាគតនៃការបណ្តុះបណ្តាល ដោយពួកគេអះអាងថា៖ "ពេលដែលការបណ្តុះបណ្តាលមិនបានជោគជ័យ យើងនឹងគ្មានជម្រើសដែលអាចធ្វើការបណ្តុះបណ្តាលបានទេ។ ភារកិច្ចពេលអនាគតហាក់ដូចជាមានការគិតគូរកាន់តែច្រើនអំពីការវិភាគថា តើគេត្រូវការបណ្តុះបណ្តាលអ្វី គួរធ្វើការតម្រង់ទិសការបណ្តុះបណ្តាល ឱ្យទៅជាការផ្តល់សេវាដល់អតិថិជនដែរឬទេ ? តើគួរបន្តដកពិសោធន៍ជាមួយប្រព័ន្ធផ្តល់ការបណ្តុះបណ្តាលដែរឬទេ ? តើគួរដើរចេញពីកម្មវិធីមុខវិជ្ជា ដែលនាំពីបស្ចិមប្រទេសនិងកម្មវិធីសិក្សាបរទេសដែរឬទេ ? តើមានការបារម្ភច្រើនអំពីលទ្ធផលចុងក្រោយដែរឬទេ ? តើមានការទទួលស្គាល់ថា ការបណ្តុះបណ្តាលមិនមែនជាសកម្មភាពដាច់ពីគ្នាដែរឬទេ ? តែមានសមាសភាពមួយ ក្នុងចំណោមសមាសភាពប្រទាក់ក្រឡាគ្នាជាច្រើន សម្រាប់ធ្វើឱ្យមានការផ្លាស់ប្តូរអង្គការ និងការធ្វើកំណែទម្រង់រដ្ឋបាល ។

**ឃ-ការបណ្តុះបណ្តាលឡើងវិញ**

ដោយសារតែប្រព័ន្ធសមាហរណកម្មខ្សែបណ្តោយ អនុ-

ញ្ញាតឱ្យមានវិធីសាស្ត្រធ្វើការបណ្ដុះបណ្ដាលថ្នាក់ជាតិដូច្នេះប្រព័ន្ធទាំងអស់ នោះក៏មានយន្តការស្របគ្នាសម្រាប់រក្សាបុគ្គលិក។ ការធានាការងារ ត្រូវបានគិតគូរខ្ពស់នៅប្រទេសជប៉ុន តាមរយៈច្បាប់ស្ដីពីគោលការណ៍ការងារមួយជីវិត និងសមភាពឱកាសការងាររបស់ខ្លួន ទោះបីមានការប្រកាន់យកគោលការណ៍ការងារមួយជីវិត ហាក់បីដូចជាជំទាស់នឹងកាលៈទេសៈសេដ្ឋកិច្ចបច្ចុប្បន្ន។ និយោជិករបស់រដ្ឋាភិបាលមូលដ្ឋាននៅហ្វីលីពីន ស្វែងរកអាជីពនៅក្នុងប្រព័ន្ធ ដែលមានសិទ្ធិធ្វើការរហូតដល់ការគ្រប់គ្រងដោយគណៈកម្មការមន្ត្រីរាជការ និងបទប្បញ្ញត្តិ ដែលអាចអនុវត្តក្រុមរដ្ឋាភិបាលមូលដ្ឋាន។ ប្រព័ន្ធម៉ាឡេស៊ី អាចឱ្យគេកំណត់បានពេលតីជ្រើសរើសបុគ្គលិកល្អ បណ្ដុះបណ្ដាលពួកគេតម្លើងឋានៈពួកគេដោយផ្អែកលើមូលដ្ឋានសមត្ថភាព ដែលកាន់មុខតំណែងថ្នាក់ខ្ពស់ និងរក្សាពួកគេ តាមរយៈការរឹតបន្តឹងការចល័ត តាមខ្សែទទឹងក្នុងចំណោមអាជ្ញាធរនានា។ មានចរន្តធ្វើការផ្លាស់ប្ដូរប្រព័ន្ធដែលគ្មានការនិយមស្ដីពីការមិនឱ្យមានការផ្ទេរ ក្នុងចំណោមអាជ្ញាធរមូលដ្ឋាននានា ដោយគ្មានការបាត់បង់អតីតភាពនោះទេ។

ផលចំណេញដែលបានពីប្រព័ន្ធ"**បិទ**"នេះ រួមមានការធានាការងារ និងកសាងមាគ៌ាអាជីពដែលមានលក្ខណៈដូចគ្នា។ ប្រព័ន្ធនេះក៏អាចជួយក្រុមប្រឹក្សាតូចៗ ឱ្យរក្សាបាននូវបុគ្គលិកល្អៗដែលនៅក្នុងប្រព័ន្ធ"**បើក**"ទំនងជាប្ដូរទៅរកការងារ ដែលមានលក្ខណៈប្រសើរជាង ឬដែលមានចំណូលខ្ពស់ជាង ។ ការខាតបង់នៃការប្រើប្រព័ន្ធ"**បិទ**"នេះ គឺជាគំនិតអភិរក្សនិយមស្របគ្នានឹងភាពនៅ

ដាច់ពីគេ។ ដំណើរបន្ធូរបន្ថយតាមទីផ្សារការងារនៅប្រទេសញូហ្ស៊ីឡែន និងអូស្ត្រាលីបានបន្ថយការធានារយៈពេលការងារ ប៉ុន្តែបានជួយពង្រឹងច្បាប់ស្តីពីឱកាសស្មើគ្នា។ ចំណែកឯមន្ត្រីបានបាត់បង់ការធានាការងារ និងកាន់ការងាររបស់ខ្លួន ប្រសិនបើពួកគេមិនត្រូវបានបណ្តេញចេញពីបទប្រព្រឹត្តពុករលួយ ឬអសមត្ថភាពទាំងស្រុង ពួកគេមានការធានាថា នឹងអាចរកមុខតំណែងថ្មីណាមួយតាមគុណបំណាច់របស់ខ្លួន។ យ៉ាងណាក្តី ស្របតាមវិធីសាស្ត្រយកទីផ្សារជាធំ គឺជាលទ្ធភាពដែលថា អាជ្ញាធរធំៗសំបូរធនធាននឹងទាក់ទាញបានបុគ្គលិកល្អប្រសើរបំផុត។ នៅក្នុងទីផ្សារដែលមានការបន្ធូរបន្ថយសញ្ញាណសេវាសាធារណៈ ឬមន្ត្រីសាធារណៈបានបាត់បង់ ។ កន្លែងណាដែលអាចចល័ត ក្នុងចំណោមវិស័យសាធារណៈ និងឯកជន ត្រូវបានលើកទឹកចិត្តអាជីពការងារ រយៈ-ពេលវែងនៅក្នុងវិស័យសាធារណៈ បើកផ្លូវឱ្យមន្ត្រីអាចស្វែងរកការងារផ្ទាល់ខ្លួនបាន ។ ប្រសិនបើគេយល់ថាជាចំណុចអវិជ្ជមាននោះ ចំណុចវិជ្ជមាន គឺជាការប្រើប្រាស់ចំណេះដឹង ជំនាញថ្មីៗ ហើយជាការសំខាន់ គឺជាទស្សនវិស័យថ្មី ដែលមាននៅក្នុងវិស័យឯកជន។

**ខ-ប្រភពចំណូល**

របាយការណ៍ទាំងអស់ បានបង្ហាញយ៉ាងច្បាស់ណាស់ថា បញ្ហាកុំរ៉ែសម្រាប់អាជ្ញាធរមួយស្ទើរតែទាំងអស់ គឺកង្វះថវិកា។ថ្មីៗនេះ ប្រភពចំណូលចម្បងរបស់មូលដ្ឋានមាន:

-ការផ្ទេរសារពើពន្ធពីរដ្ឋាភិបាលថ្នាក់ខ្ពស់

-កម្ចី និង ការខ្ចី និង

-ពន្ធមូលដ្ឋាន។

ដើម្បីឱ្យមានស្វ័យគ្រប់គ្រងមូលដ្ឋានកាន់តែធំធេងឡើង ប្រកបដោយប្រសិទ្ធភាពខ្ពស់ គេត្រូវតែផ្ដល់ចំណូលបន្ថែមទៅដល់រដ្ឋាភិបាលមូលដ្ឋាន ។ ប្រទេសអូស្ត្រាលី មានប្រវត្តិរឿងខ្លីៗនិយាយពីចំណែកនៃចំណូលថវិកា ដែលធានាដោយថ្នាក់ជាតិចំនួន១% ក៏ប៉ុន្តែតាំងពីពេលនោះមក បែរជាទៅប្រើប្រព័ន្ធចាស់ក្នុងការផ្ដល់ឱ្យរដ្ឋាភិបាលមូលដ្ឋានវិញ។ ចំណែកដែលធានាចំណូលពីថ្នាក់ជាតិ ត្រូវបានគាំទ្រដោយរដ្ឋធំៗ និងរដ្ឋាភិបាលមូលដ្ឋាន ខណៈពេលដែលរដ្ឋនិងរដ្ឋាភិបាលមូលដ្ឋាន ដែលមានប្រជាជនតិចគាំទ្រការបែងចែកតាមសមតុល្យនៃប្រព័ន្ធផ្ដល់ថវិកា។ ដូចគ្នានេះដែរ ជប៉ុន និងម៉ាឡេស៊ី បង្កើតឱ្យមានប្រព័ន្ធឧបត្ថម្ភឆ្លងកាត់ពីរដ្ឋាភិបាលខ្លាំងទៅឱ្យរដ្ឋាភិបាលមូលដ្ឋានទន់ខ្សោយ។

ការសម្រេច ឱ្យមានការបែងចែកសារពើពន្ធប្រកបដោយគុណភាព គឺជាកម្លាំងដ៏ខ្លាំងនៅក្នុងរដ្ឋាភិបាលកណ្ដាល។ នៅហ្វីលីពីនក្រុមរដ្ឋាភិបាលមូលដ្ឋាន ធានាឱ្យមានចំណែកសមធម៌នៃចំណូល ដែលត្រូវផ្ដល់ឱ្យតំបន់របស់ខ្លួន និងចំណែកពីចំណូលជាតិ។ ការចងជាក្រមបែបនេះ មិនត្រឹមតែផ្ដល់ការធានាមូលនិធិមួយចំនួនប៉ុណ្ណោះទេប៉ុន្តែថែមទាំងជាការលើកទឹកចិត្តជួយសម្រួលការអភិវឌ្ឍមូលដ្ឋាន ពីព្រោះការផ្ដល់ចំណូលកាន់តែច្រើនទៅក្នុងតំបន់របស់ពួកគេ គឺធ្វើឱ្យចំណូលប្រចាំគ្រួសារកើនកាន់តែច្រើនផងដែរ។

ខណៈដែលរដ្ឋាភិបាលមូលដ្ឋាន អាចមានអំណាចខ្ចីថវិកាបាន ក៏រដ្ឋាភិបាលនេះ មានអំណាចតិចតួចណាស់។

ឧទាហរណ៍នៅបង់ក្លាដេសរដ្ឋាភិបាលមូលដ្ឋានភាគច្រើនបំផុត មិនមានអំណាចច្រើនគ្រប់គ្រាន់ ដើម្បីធានាកំចី និងសងបំណុលទេ។ គេអាចដោះស្រាយរឿងនេះបាន ដូចជាករណីនៅប្រទេសហ្វីជី គឺរដ្ឋាភិបាលថ្នាក់លើធ្វើការធានាកំចី ចំពោះអ្នកផ្តល់កម្ចីពាណិជ្ជកម្ម ទោះបីមានការធានាគ្រាន់តែជួយបង្កើនការពឹងផ្អែករបស់មូលដ្ឋានទៅលើរដ្ឋាភិបាលថ្នាក់លើក៏ដោយ។

រដ្ឋាភិបាលមូលដ្ឋាននៅគ្រប់ប្រទេសទាំងអស់ មានសមត្ថភាពប្រមូលពន្ធបាន ។ សូម្បីនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចដែលបញ្ជាដោយថ្នាក់កណ្តាលក៏ដោយ ក៏រដ្ឋាភិបាលមូលដ្ឋាន ធ្វើការប្រមូលពន្ធមូលដ្ឋាន ។ ដូចយើងបានពិភាក្សាពីខាងដើមរួចហើយក្នុងជំពូកនេះ ពន្ធមូលដ្ឋានសំខាន់ៗ រួមមានពន្ធលើទ្រព្យសម្បត្តិតាមទម្រង់ជាច្រើន ដូចជាពន្ធប្រថាប់ត្រា និងអាករបន្ថែម(VAT)។

បញ្ហាមួយ ក្នុងចំណោមបញ្ហានានា ពាក់ព័ន្ធនឹងពន្ធលើទ្រព្យសម្បត្តិ គឺមានទ្រព្យសម្បត្តិមួយចំនួនដែលមិនជាប់ពន្ធ។ ភូមិអ្នកស្រុកជនជាតិដើមនៅហ្វីជី ព្រះវិហារនៅអូស្ត្រាលី និងរដ្ឋាភិបាលថ្នាក់លើ ជាទូទៅមិនបង់ពន្ធទ្រព្យសម្បត្តិឱ្យមូលដ្ឋានទេ។ នៅក្នុងឧទាហរណ៍មួយចំនួន ថ្នាក់លើ គឺជាអ្នកកំណត់ពន្ធលើទ្រព្យសម្បត្តិនេះ ។ បញ្ហាមួយទៀត គឺទាក់ទងនឹងសមត្ថភាព ឬអសមត្ថភាពក្នុងការប្រមូលពន្ធជាក់ស្តែង។ ការយកពន្ធ គឺជារឿងមួយ ហើយការប្រមូលពន្ធ គឺជារឿងផ្សេង។ ការមិនសងបំណុល

គឺជាបញ្ហាសំខាន់មួយនៅប្រទេសហ្វីជី។ក្រុមប្រឹក្សាអាចប្រមូលពន្ធដែលត្រូវប្រមូលបានត្រឹមតែចំនួន៦០-៧០%ប៉ុណ្ណោះ និងប្រមូលបំណុលដែលចេះតែកើនឡើង បានត្រឹមតែ១០-២០%ប៉ុណ្ណោះ ក្នុងមួយឆ្នាំៗ។ ការមិនបង់ពន្ធលើទ្រព្យសម្បត្តិ ក៏ជាព្រឹត្តិការណ៍ធម្មតាមួយ ដូចជាគ្រោះរាំងស្ងួតនៅអូស្ត្រាលី ឬការធ្លាក់ចុះថ្លៃទំនិញកសិកម្មនៅលើទីផ្សារពិភពលោក ។ នេះក៏អាចជាឧបសគ្គ ដល់ការប្រមូលពន្ធដែលត្រូវប្រមូលដែរ ។ ដូចគ្នាករណីនៅប្រទេស ហ្វីជី រដ្ឋាភិបាលកណ្តាលអាចជំទាស់មិនព្រមផ្តល់ ថវិកាបន្ថែមពីថ្នាក់កណ្តាល ប្រសិនបើរដ្ឋាភិបាលមូលដ្ឋាន មិនអាចប្រមូលពន្ធមូលដ្ឋានសំខាន់ៗរបស់ខ្លួនបានទេ។ ពន្ធមូលដ្ឋាន មានប្រពៃណីយូរអង្វែងនៅឥណ្ឌា និងប៉ាគីស្ថាន ។ វាគឺជាពន្ធ ដែលត្រូវយកទៅលើការនាំចូលទំនិញដែលចូលមកតំបន់ មូលដ្ឋានក្នុងគោលបំណងដើម្បីប្រើប្រាស់ ឬលក់នៅលើទឹកដីរបស់ខ្លួន។ នេះមិនមែនគ្រប់រដ្ឋទាំងអស់ សុទ្ធតែប្រើពន្ធនេះទេ ប៉ុន្តែនៅកន្លែងណាដែលប្រើពន្ធនោះ កន្លែងនោះមានប្រភពចំណូលសំខាន់ នៃចំណូលសរុបរបស់ខ្លួនប្រហែល៦០-៨០% ដែលអង្គភាពមូលដ្ឋានទីក្រុងត្រូវប្រើប្រាស់។ ការទាក់ទាញប្រមូលពន្ធនេះគឺជាបរិមាណចំណូលដែលមានក្នុងដំណើរការទៅតាមទំហំប្រជាពលរដ្ឋប្រើប្រាស់ និងសកម្មភាពឧស្សាហកម្មនៅតំបន់នោះ។វាក៏ជាការទាក់ទាញផងដែរ ដោយហេតុថា ការប្រមូលចុងក្រោយ គឺអាស្រ័យលើទំនិញដែលនាំចូលមកតំបន់ក្នុងមូលដ្ឋានតែម្តង។ ទោះបីមានការទាក់ទាញទាំងអស់នេះក៏ដោយ ក៏គេរិះគន់យ៉ាងខ្លាំង ហើយរដ្ឋឥណ្ឌា

ចំនួន១៣ បានបោះបង់ការយកពន្ធបែបនេះរួចហើយ ហើយរដ្ឋផ្សេងៗទៀត កំពុងធ្វើការពិចារណារឿងនេះដែរ។

ឥទ្ធិពលរបស់រដ្ឋាភិបាលកណ្ដាល ទៅលើការប្រមូលពន្ធ គឺទំនងជាមានលក្ខណៈធ្ងន់ធ្ងរបំផុតនៅប្រទេសឥណ្ឌូនេស៊ី ដែលបានកើតមានករណីនេះយូរមកហើយ។តួយ៉ាងប្រទេសភាគច្រើនចំណោល ដែលរដ្ឋាភិបាលមូលដ្ឋានត្រូវទទួលបាន ដូចជានៅប៉ាគីស្ថាន គឺមានលក្ខណៈតិចតួច តើវាពាក់ព័ន្ធនឹងបញ្ហាប្រមូលពន្ធឬទេ ? ។ វាប្រាកដណាស់រឿងសំខាន់ គឺត្រង់ថា តើនរណាជាអ្នកចាយលុយនេះ ? ។ ដោយហេតុថា រដ្ឋាភិបាលមូលដ្ឋានមានថវិកាគ្រប់គ្រាន់ ដើម្បីបំពេញភាគព្វកិច្ចរបស់ខ្លួនជូនសហគមន៍ ហើយការធ្វើដូច្នេះអាចមានប្រយោជន៍ក្នុងការទទួលបានចំណែកដែលបានពីការប្រមូលពន្ធរបស់ថ្នាក់កណ្ដាល និងចំណែកវិភាជន៍ចំណុចខ្សោយក្នុងរឿងនេះ គឺពាក់ព័ន្ធកម្រិតគ្រប់គ្រងរបស់រដ្ឋាភិបាលកណ្ដាលទៅលើការងាររបស់មូលដ្ឋាន។នៅក្នុងរបាយការណ៍ទាំងអស់បង្ហាញច្បាស់ណាស់ថា រដ្ឋាភិបាលថ្នាក់លើមានការប្រុងប្រយ័ត្ន ដោយឱ្យរដ្ឋាភិបាលមូលដ្ឋាន ធ្វើការផ្ដល់សេវាបន្ថែមដោយមិនចាំបាច់ផ្ដល់ធនធានសមរម្យ។

**ច-សមត្ថភាពសហគមន៍**

ការផ្ដោតលើពីរផ្នែកចុងក្រោយនេះ គឺជាបឋមផ្នែកលើអាជ្ញាធរ រដ្ឋាភិបាលមូលដ្ឋាន ប្រជាជន និងហិរញ្ញវត្ថុរបស់ខ្លួន។ នៅក្នុងផ្នែកចុងក្រោយ យើងនិយាយផ្ដោតទៅលើសហគមន៍។ ការមិនធ្វើឱ្យប្រសើរឡើងនូវឧបករណ៍របស់រដ្ឋាភិបាល នឹងធានា

វិធីភ្ជាប់គំរូអនុវត្តអភិបាលកិច្ចបែបថ្មីបានទេ ប្រសិនបើសហគមន៍មិនមានសមត្ថភាពក្នុងការចូលរួម ។ ប្រទេសគីហ្ស៊ីស្ថាន នៅក្នុងដំណាក់កាលអន្តរកាលគឺជាករណីដែលគួរលើកយកមកនិយាយ ដោយហេតុថាប្រទេសនេះ ឈានទៅអនុវត្តស្វ័យភាពថ្នាក់មូលដ្ឋានកាន់តែធំធេងឡើង ហើយសាធារណរដ្ឋនេះត្រូវតែគ្រប់គ្រងមរតកនេះ បានប្រាំមួយទសវត្សកន្លងមក ។ នៅដើមទសវត្សឆ្នាំ ១៩៣០ តំបន់មូលដ្ឋាននៅក្នុងអតីតរដ្ឋ សហភាពសហព័ន្ធរុស្ស៊ីមានឯករាជ្យភាពប្រហាក់ប្រហែលគ្នា ប៉ុន្តែស្វ័យភាពនេះ បានត្រឡប់ទៅរកការគ្រប់គ្រងថ្នាក់កណ្តាលដ៏ខ្លាំងក្លាវិញ តាមរយៈការបង្កើតប្រពៃណី វប្បធម៌គ្រប់គ្រងតាមបែបការិយាធិបតេយ្យខ្លាំងក្លា និងគោលការណ៍បែងចែកមុខងារ subsidization ដោយរដ្ឋាភិបាល។ ការឈានចូលសេដ្ឋកិច្ចទីផ្សារ បានសំដៅដល់ "ការអភិវឌ្ឍស្ថាប័នប្រជាធិបតេយ្យយ៉ាងសកម្ម " ទោះបីដំណាក់កាលអន្តរកាលនេះ មិនមានលក្ខណៈងាយស្រួលត្រូវប្រឈមមុខបញ្ហាជាច្រើនដ៏ស្មុគ្រស្មាញនិងគំនិតពីរបបចាស់ក៏ដោយ។ ការផ្លាស់ប្តូរប្រពៃណី និងវប្បធម៌ទាំងអស់នឹងមិនអាចប្រព្រឹត្តទៅបាន ដោយឆាប់រហ័សនោះទេ ។ ការកសាងសមត្ថភាព ត្រូវតែរួមបញ្ចូលសមត្ថភាពទទួលខុសត្រូវនៅមូលដ្ឋាន ។ ក្នុងការអនុវត្តសេដ្ឋកិច្ចដែលដាក់ផែនការពីថ្នាក់មជ្ឈិម ប្រជាពលរដ្ឋគ្មានជម្រើសទេ ហើយរដ្ឋាភិបាលកណ្តាលនៅតែរក្សាការគ្រប់គ្រង។ នៅបណ្តាប្រទេសលោកខាងលិច កម្រិតនៃការចូលរួមរបស់មូលដ្ឋាន ផ្តោតលើផលប្រយោជន៍ផ្ទាល់ខ្លួន និងភាពព្រងើយកន្តើយ។ ទាំងសង

ខាង ទាមទារឱ្យមានសមត្ថភាព ធ្វើការវិនិច្ឆ័យសាធារណៈ។

ដូចដែលបានជម្រាបជូនពីដើមរួចហើយ គេសន្និដ្ឋានថា សហគមន៍នានាចង់ចូលរួម ហើយដូចបង្ហាញជូនករណីប្រទេសហ្វីជី ក្រុមប្រឹក្សាក្រុង និងគណបក្សនយោបាយនៅមូលដ្ឋាន មិនមែនសុទ្ធតែទទួលបានប្រយោជន៍ពីសេរីភាពដ៏សំខាន់ ដែលពួកគេចង់បាន និងសិទ្ធិដែលពួកគេអាចចូលទៅកាន់រដ្ឋាភិបាលកណ្តាលបានទេ។

នៅក្នុងករណីនេះ សមត្ថភាពភ្នាក់ងារនយោបាយនៅមូលដ្ឋាន ដែលធ្វើប្រតិបត្តិការនៅក្នុងសៃរៀនជាតិ ហាក់ដូចជាត្រូវការការពង្រឹងបន្ថែម។

## VII-របៀបវារៈដើម្បីសកម្មភាព

បញ្ហាជាច្រើន ត្រូវបានលើកឡើងនៅក្នុងផ្នែកខាងដើម គឺជាបញ្ហាដែលគេដកចេញពីរបាយការណ៍ប្រចាំប្រទេស ។ យើងចង់និយាយថារបាយការណ៍នានា ជាការលាបពណ៌ការសម្តែងរបស់រដ្ឋនាពេលបច្ចុប្បន្ន។ ការសិក្សានេះបង្ហាញច្បាស់ថា រដ្ឋាភិបាលមូលដ្ឋានជាច្រើននៅអាស៊ី ប៉ាស៊ីហ្វិកកំពុងតស៊ូរៀបចំដំណើរការប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការបំពេញតម្រូវការនិងបំណងប្រាថ្នារបស់អ្នកស្រុក។ សូម្បីពួកគេតស៊ូដោះស្រាយបញ្ហាប្រឈមជាសម្ពាធថ្មីនៅពេលដែលរដ្ឋាភិបាលកណ្តាលដាក់ការទទួលខុសត្រូវ ទៅឱ្យរដ្ឋាភិបាលមូលដ្ឋាននោះក៏ដោយក៏វិស័យឯកជន ទាមទារឱ្យមានភាពបត់បែនកាន់តែច្រើនឡើងដើម្បីប្រតិបត្តិការតាមការរឹតបន្តឹងកាន់តែតិច ក្នុងពេលដែលកើត

មានវណ្ណៈកណ្ដាល ដែលមានការអប់រំល្អ ញ៉ាំងឱ្យមានការចូលរួមកាន់តែច្រើន ហើយបញ្ហាភាពក្រីក្រ នៅតែបន្តកើនឡើង។ គោលបំណងចម្បងនៃការសិក្សានេះ គឺសំដៅរួមចំណែកដល់ការបង្កើតគំរូអនុវត្តថ្មី។ តែយ៉ាងណាក៏ដោយ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។

អំណះអំណាងចម្បង នៅក្នុងការសិក្សានេះ បង្ហាញថា នៅពេលបច្ចុប្បន្ន និងនៅពេលអនាគតនៃសាកលភាវូបនីយកម្មសេដ្ឋកិច្ច ដែលគេអាចព្យាករណ៍បាន មានទំនោរទៅរកសេរីភាពនយោបាយកាន់តែច្រើនឡើង ការមកដល់យុគសម័យព័ត៌មានទាមទារឱ្យមានការធ្វើកំណែទម្រង់ និងការពង្រឹងប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន ដើម្បីឆ្លើយតបបញ្ហាប្រឈមបច្ចុប្បន្ននិងពេលខាងមុខ។ ករណីនេះទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើន និងពុះពារគ្នា ដោយផ្អែកលើសកម្មភាពស្រាវជ្រាវ ដូចជាការដកពិសោធន៍ និងការធ្វើឱ្យប្រព័ន្ធដែលមានស្រាប់ មានលក្ខណៈប្រសើរឡើង ព្រមទាំងការស្វែងយល់ពីការអនុវត្តតាមរបៀបថ្មី នៅក្នុងបណ្ដាប្រទេសផ្សេងៗទៀត និងការសម្របទៅតាមតម្រូវការមូលដ្ឋាន។

## ក-ការងារអនុវត្តនិងការត្រួតពិនិត្យ

របាយការណ៍របស់ប្រទេសចំនួន១៥ បង្ហាញឱ្យឃើញថា ការធ្វើកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាន ចាំបាច់ត្រូវផ្ដោតលើវិស័យជាច្រើន ។ បញ្ហាខាងក្រោមនេះ ត្រូវបានដកចេញពីការវិភាគ ដើម្បីលើកឡើងពីរបៀបវារៈ សម្រាប់ធ្វើសកម្មភាពកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាន។

**ខ-ស្វ័យភាពមូលដ្ឋាន**

បញ្ហាគន្លឹះនៅក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានដើម្បីដោះស្រាយបញ្ហាប្រឈមនៃសាកលភាវូបនីយកម្ម គឺកំណត់អំពីកម្រិតសមស្របនៅក្នុងរដ្ឋាភិបាល ដែលបានទទួលការផ្ទេរមុខងារ និងអំណាចពីថ្នាក់លើ។

ក្នុងការធ្វើកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាន រដ្ឋាភិបាលចាំបាច់ត្រូវពិចារណាអំពីបញ្ហាដូចតទៅនេះ ៖

-គោលការណ៍ស្វ័យភាព គោលការណ៍បែងចែងមុខងារ (subsidiarity) និងភាពនៅជិតបំផុត គួរត្រូវលើកកម្ពស់ដោយគោរពតាមធម្មនុញ្ញពិភពលោកស្ដីពីស្វ័យគ្រប់គ្រងមូលដ្ឋាន

-យុទ្ធសាស្ត្រសម្រាប់សម្រេចឱ្យបានគោលការណ៍ទាំងអស់នេះ នឹងត្រូវបន្តនៅក្នុងបរិបទជាតិ និងការជំរុញទឹកចិត្ត ព្រមទាំង

-បញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗនានា ដែលរដ្ឋាភិបាលមូលដ្ឋានប្រឈមមុខ គឺការបង្កើតតួនាទីថ្មីរបស់ពួកគេស្របតាមនិន្នាការកើនឡើងឯកជនភាវូបនីយកម្មនិងសាជីវកម្មនីយកម្ម

**គ-ការជារលឹកកម្ម**

របាយការណ៍ប្រចាំប្រទេស បង្ហាញឱ្យឃើញថានៅបណ្ដាប្រទេសជាច្រើន រដ្ឋាភិបាលមូលដ្ឋានត្រូវបានបង្កើត ឬរំលាយចោលតាមអំពើចិត្តរបស់រដ្ឋាភិបាលថ្នាក់ខ្ពស់ជាង ។ នេះគឺជាការធ្វើឱ្យខូចប្រយោជន៍ដល់ដំណើរការអភិវឌ្ឍស្ថាប័នមូលដ្ឋាន ។

រដ្ឋាភិបាលមូលដ្ឋាន គឺជាសសរគ្រឹះដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ហើយការធ្វើកំណែទម្រង់អភិបាលកិច្ច គួរតែគិតគូរអំពី

ទិដ្ឋភាពរដ្ឋាភិបាលមូលដ្ឋាន នៅក្នុងដំណើរការកំណែទម្រង់។ កំណែទម្រង់ច្បាប់ ត្រូវតែធានាថា៖

-អនុលោមតាមគោលការណ៍បែងចែកមុខងារ (Subsidiarity) រដ្ឋាភិបាលមូលដ្ឋាន ដោយសារតែខ្លួនជាថ្នាក់រដ្ឋាភិបាលដែលនៅជិតកៀកនឹងប្រជាជនបំផុត គួរតែអាចទទួលខុសត្រូវជាសាធារណៈជាទូទៅ ។ ការវែកការទទួលខុសត្រូវរបស់រដ្ឋាភិបាលឱ្យអាជ្ញាធរ ឬថ្នាក់ណាមួយត្រូវតែផ្អែកលើតម្រូវការភាពស័ក្តិសិទ្ធិផ្នែកបច្ចេកទេស ឬសេដ្ឋកិច្ច ។

-អំណាច និងការទទួលខុសត្រូវជាមូលដ្ឋានរបស់រដ្ឋាភិបាលមូលដ្ឋាន ត្រូវបានចែងដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់។

-តួនាទីរបស់រដ្ឋាភិបាលមូលដ្ឋាន ចាំបាច់ត្រូវតែបញ្ជាក់ច្បាស់លាស់ ពោលគឺថារដ្ឋាភិបាលមូលដ្ឋានជាអ្នកផ្តល់សេវាភាគច្រើនលើសលុប ឬជានិយតករ និងជាការអ្នកជំរុញវិស័យឯកជនឱ្យផ្តល់សេវា ។ ការកំណត់តួនាទីរបស់រដ្ឋាភិបាលមូលដ្ឋាននេះមានភាពស្មុគ្រស្មាញច្រើនពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋាភិបាល នៃរដ្ឋាភិបាលមូលដ្ឋាន។

**ឃ-ទំនាក់ទំនងពីថ្នាក់កណ្តាល ទៅថ្នាក់មូលដ្ឋាន**

របាយការណ៍ប្រចាំប្រទេសបង្ហាញថា ប្រទេសភាគច្រើនបំផុតលើកលែងតែប្រទេសពីរបី ប្រើប្រព័ន្ធមជ្ឈការរដ្ឋាភិបាលខ្លាំងក្លានៅថ្នាក់កណ្តាលក៏បាន នៅរដ្ឋាភិបាលថ្នាក់រដ្ឋ ខេត្តក៏បានដោយអនុវត្តការត្រួតពិនិត្យច្រើនទៅលើរដ្ឋាភិបាលមូលដ្ឋាន។ ករណីនេះបានបង្ក ឱ្យមានភាពទន់ខ្សោយដល់ស្ថាប័នរដ្ឋាភិបាល

មូលដ្ឋាន។ កំណែទម្រង់ គួរតែរាប់បញ្ចូលការយកឈ្នះភាពស្ទាក់ស្ទើររបស់រដ្ឋាភិបាលកណ្តាល ដើម្បីធ្វើការបរិច្ចាកអំណាច។ រដ្ឋាភិបាលគួរតែធានាថា៖

-ការទទួលខុសត្រូវដែលផ្តល់ជូនរដ្ឋាភិបាលមូលដ្ឋាន ត្រូវភ្ជាប់មកជាមួយនូវអំណាចនិងធនធានពេញលេញ ដើម្បីបំពេញការទទួលខុសត្រូវទាំងអស់នោះ ហើយការទទួលខុសត្រូវទាំងនោះទៀតសោត មិនមែនគ្រាន់តែជាមុខងារភ្នាក់ងារខ្សែបណ្តោយប៉ុណ្ណោះទេប៉ុន្តែត្រូវសំដៅទៅរកស្វ័យគ្រប់គ្រងមូលដ្ឋានពិតប្រាកដ

-បើអាជ្ញាធរ ឬថ្នាក់រដ្ឋាភិបាល ក្រៅពីរដ្ឋាភិបាលមូលដ្ឋាន ត្រូវបានគេប្រគល់ភារកិច្ចអនុវត្តមុខងារប្រាកដប្រជា ដោយសារហេតុផលបច្ចេកទេស ឬទំហំសេដ្ឋកិច្ច គេត្រូវតែកំណត់ឱ្យបានច្បាស់លាស់អំពីអំណាច និងការទទួលខុសត្រូវ។ នៅក្នុងឧទាហរណ៍ជាច្រើន ភាពជាដៃគូនៃការចែករំលែកអំណាចក្នុងចំណោមថ្នាក់រដ្ឋាភិបាលនានា មានផលច្រើនជាងការគ្រាន់តែបែងចែកអំណាចនោះ។

-រដ្ឋាភិបាលមូលដ្ឋាន យល់ច្បាស់ថា ការទទួលបានសេរីភាពពីការត្រួតត្រារបស់ថ្នាក់កណ្តាល មិនត្រូវបានកំណត់ថា ជាមធ្យោបាយក្នុងការកាត់បន្ថយគណនេយ្យភាពសាធារណៈទេ។ តាមការពិត គេគួរតែបោះជំហានធ្វើឱ្យរដ្ឋាភិបាលមូលដ្ឋាន មានការឆ្លើយតប និងការទទួលខុសត្រូវកាន់តែច្រើនចំពោះប្រជាពលរដ្ឋនៅមូលដ្ឋាន។

**ខ-វេជ្ជបញ្ញាល**

រដ្ឋបាលរដ្ឋាភិបាលមូលដ្ឋាន គឺជាទិដ្ឋភាពសំខាន់មួយទៀត ក្នុងការធ្វើកំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាន។ ការធ្វើកំណែទម្រង់រដ្ឋបាល ត្រូវតែផ្ដោតលើវិស័យចំនួនបី ជាពិសេសការបែងចែកអំណាចរវាងអង្គបញ្ញត្តិ និងអង្គប្រតិបត្តិមូលដ្ឋាន កំណែទម្រង់រចនាសម្ព័ន្ធរដ្ឋបាលរបស់អង្គនីតិប្រតិបត្តិ និងការសម្របសម្រួលជាមួយអាជ្ញាធរ និងកម្រិតថ្នាក់រដ្ឋាភិបាលផ្សេងៗទៀត។

គោលការណ៍ខាងក្រោមនេះ គួរតែប្រកាន់ខ្ជាប់នៅពេលធ្វើកំណែទម្រង់រដ្ឋបាល៖

-នៅពេលកំណត់អំពីរចនាសម្ព័ន្ធរដ្ឋាភិបាលមូលដ្ឋាន គេត្រូវរក្សាតុល្យភាពឱ្យបានរវាងអង្គបញ្ញត្តិ និងអង្គប្រតិបត្តិរបស់រដ្ឋាភិបាលមូលដ្ឋាន ។ អង្គបញ្ញត្តិ គួរតែមានអំណាចសមស្របដើម្បីជំរុញឱ្យអង្គប្រតិបត្តិមានគណនេយ្យភាព ជាពិសេសនៅពេលអង្គប្រតិបត្តិត្រូវបានតែងតាំង នេះគឺជាករណីទាក់ទងនឹងប្រព័ន្ធអ្នកគ្រប់គ្រងក្រុង។

-កំណែទម្រង់រដ្ឋបាល គួរតែផ្ដោតទៅលើការធ្វើឱ្យរដ្ឋាភិបាលមូលដ្ឋានមានគណនេយ្យភាព និងការឆ្លើយតបកាន់តែច្រើនចំពោះប្រជាពលរដ្ឋមូលដ្ឋាន ជាជាងចំពោះរដ្ឋាភិបាលថ្នាក់លើ។

-រដ្ឋាភិបាលថ្នាក់លើ ធ្វើការត្រួតពិនិត្យនិងជ្រៀតជ្រែកកិច្ចការរបស់រដ្ឋាភិបាលមូលដ្ឋាន តាមរយៈវិធានការរដ្ឋបាលនានា។ នៅបណ្ដាប្រទេសមួយចំនួន ករណីនេះរួមមានទាំងការចាត់តាំងបុគ្គលិកពីថ្នាក់លើ ដើម្បីទៅកាន់មុខតំណែងសំខាន់ៗ នៅរដ្ឋាភិបាលមូលដ្ឋាន តាមពេលកំណត់ជាក់លាក់។ នេះ គឺជាការកំណត់

និរន្តភាព ភាពស័ក្តិសិទ្ធិ និងតម្លាភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងរដ្ឋបាលរបស់រដ្ឋាភិបាលមូលដ្ឋាន។

រដ្ឋាភិបាលមូលដ្ឋាន គួរតែអាចធ្វើការរៀបចំការងាររដ្ឋបាលថ្មីៗ និងការជ្រើសរើសបុគ្គលិក។

**ច-ហិរញ្ញវត្ថុរដ្ឋាភិបាលមូលដ្ឋាន**

សមាសភាពមួយ ក្នុងចំណោមសមាសភាពគន្លឹះនានា ដើម្បីពង្រឹងរដ្ឋាភិបាលមូលដ្ឋាន គឺហិរញ្ញវត្ថុរបស់រដ្ឋាភិបាលមូលដ្ឋាន។ រដ្ឋាភិបាល ត្រូវតែធ្វើការប្តេជ្ញាចិត្តដូចតទៅ៖

-សិក្សាពីរបៀប និងមធ្យោបាយដើម្បីបង្កើនចំណូលរបស់រដ្ឋាភិបាលមូលដ្ឋានគឺដើម្បីឱ្យមានឯកភាពនិងភាពគួរឱ្យជឿជាក់បាន។

-បង្កើតយន្តការដែលធានាឱ្យមានស្វ័យភាពហិរញ្ញវត្ថុមូលដ្ឋានកាន់តែច្រើនឡើងព្រមទាំងការទទួលខុសត្រូវ និងគណនេយ្យភាព ចំពោះសហគមន៍មូលដ្ឋាន។

-ផ្តល់ការយកចិត្តទុកដាក់កាន់តែច្រើន ដើម្បីអភិវឌ្ឍ និងរក្សាហេដ្ឋារចនាសម្ព័ន្ធឱ្យបានគ្រប់គ្រាន់។

**ឆ-ធនធានមនុស្ស**

ឧបសគ្គមួយក្នុងចំណោមឧបសគ្គចម្បងៗរបស់អភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាន គឺជាកង្វះធនធានមនុស្ស ដែលមានសមត្ថភាព ។ សមត្ថភាពធនធានមនុស្សរបស់រដ្ឋាភិបាលមូលដ្ឋានចាំបាច់ត្រូវមានការពង្រឹងឱ្យស្របទៅតាមការកសាងសមត្ថភាពស្ថាប័ន។ ការអភិវឌ្ឍធនធានមនុស្ស គឺពឹងផ្អែកលើកត្តាបី ពោល

គឺការជ្រើសរើសបុគ្គលត្រឹមត្រូវ ការបណ្តុះបណ្តាលសំដៅកសាងសមត្ថភាពរបស់ពួកគេ និងរក្សាការផ្តល់សេវារបស់ពួកគេ។

-ការតែងតាំង ត្រូវតែគិតទៅដល់មុខងារជាក់លាក់របស់រដ្ឋាភិបាលមូលដ្ឋាននិងត្រូវធ្វើឱ្យមានតម្លាភាព និងផ្អែកលើគុណបំណាច់ ។ របាយការណ៍ប្រចាំប្រទេស ផ្តល់គំរូយ៉ាងវិធីសាស្ត្រអនុវត្តនានា ដែលប្រទេសនានាអាចពិនិត្យមើលបាន។

-ការតែងតាំងបុគ្គលិកល្អ ពិតជាមានសារសំខាន់ ដូច្នេះហើយការបណ្តុះបណ្តាល និងការបន្តបំពាក់សម្ភារ ក៏ជារឿងសំខាន់ដែរ។ រដ្ឋាភិបាលមូលដ្ឋានជាពិសេសរដ្ឋាភិបាលមូលដ្ឋានថ្នាក់ក្រោមជារឿយៗ មិនមានសមត្ថភាពក្នុងការបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនទេ។យន្តការបណ្តុះបណ្តាលរួមតាមរយៈស្ថាប័នបណ្តុះបណ្តាលរបស់រដ្ឋាភិបាល មូលដ្ឋានក៏ដោយ ឬសមាគមរបស់រដ្ឋាភិបាលមូលដ្ឋានក៏ដោយ គួរត្រូវពង្រឹងបន្ថែម។

-ការអប់រំនិងការបណ្តុះបណ្តាលកាន់តែច្រើនគឺត្រូវការចាំបាច់សម្រាប់សមាជិករបស់រដ្ឋាភិបាលមូលដ្ឋាន ដែលកើតចេញពីការបោះឆ្នោត

-រដ្ឋាភិបាលមូលដ្ឋាន មិនត្រឹមតែតែងតាំងបុគ្គលិកល្អ និងផ្តល់ការបណ្តុះបណ្តាល និងការអភិវឌ្ឍបន្តប៉ុណ្ណោះទេ តែពួកគេត្រូវតែបង្កើតឱ្យមានយន្តការរក្សាបុគ្គលិកល្អ។ របាយការណ៍នានាបានផ្តល់នូវឧទាហរណ៍មួយចំនួន ស្តីពីរបៀបដែលប្រទេសនានាបានលើកឡើងពីបញ្ហានេះ។ រឿងនេះចាំបាច់ គេត្រូវពិនិត្យពិចារណាឱ្យបានលម្អិតថែមទៀត។

**៥-ការចូលរួមពីសាធារណៈ**

លក្ខខណ្ឌចាំបាច់មួយទៀតសម្រាប់អភិបាលកិច្ចល្អ គឺការចូលរួមពីសាធារណជន ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ហើយសាធារណជនធ្វើការត្រួតពិនិត្យមើលមុខងាររដ្ឋាភិបាល។

របាយការណ៍របស់រដ្ឋាភិបាល បង្ហាញថា នៅថ្នាក់មូលដ្ឋានថ្នាក់រដ្ឋបាល និងវិសាលភាពនៃការចូលរួមរបស់សាធារណជនមានភាពខុសគ្នាច្រើន។ ប្រទេសមួយចំនួន អនុញ្ញាតឱ្យមានការចូលរួមពេញលេញ ក្នុងពេលដែលប្រទេសខ្លះ មិនអនុញ្ញាតឱ្យមានការចូលរួមឡើយ ។ របាយការណ៍ប្រចាំប្រទេសក៏បានបង្ហាញឱ្យឃើញថា ការចូលរួមអាចធ្វើតាមមធ្យោបាយជាច្រើន។

ជាទូទៅប្រព័ន្ធ និងប្រព័ន្ធប្រពៃណី គឺជាក្រុមប្រឹក្សាមូលដ្ឋាន ដែលកើតចេញពីការបោះឆ្នោតទាំងស្រុង ឬដោយផ្នែក។ នៅបណ្ដាប្រទេសមួយចំនួន ក្រុមសង្គមស៊ីវិលដែលមានអង្គការចាត់តាំង មានទំនាក់ទំនង ជាមួយរដ្ឋាភិបាលមូលដ្ឋាន លើបញ្ហាផលប្រយោជន៍របស់ពួកគេ។តែយ៉ាងណាក៏ដោយ អត្ថិភាពសង្គមស៊ីវិល គឺមិនមានការធានាថា ការចូលរួមពីសាធារណៈនឹងប្រព្រឹត្តទៅដោយល្អនោះទេ។ ប្រព័ន្ធនានា ចាំបាច់ត្រូវបង្កើតឡើង ដើម្បីផ្ដល់ឱ្យក្រុមសង្គមទាំងអស់ មានសម្លេង នៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តនានា។

រូបភាពទូទៅមួយពាក់ព័ន្ធនឹងរដ្ឋាភិបាលមូលដ្ឋានទាំងអស់ គឺចំនួនស្ត្រី និងតំណាងក្រុមភាគតិច នៅក្នុងក្រុមប្រឹក្សាមូលដ្ឋានមានចំនួនតិច។

បញ្ហាមួយទៀតហាក់ដូចជាមិនមានតំណាងអ្នកក្រីក្រនៅទីក្រុង និងនៅក្នុងក្រុមប្រឹក្សាមូលដ្ឋាន។ ប្រទេសនានា អាចធ្វើការពិចារណាអនុសាសន៍ខាងក្រោម នៅពេលត្រួតពិនិត្យមើលគោលនយោបាយ ដើម្បីបង្កើនការចូលរួមនៅថ្នាក់មូលដ្ឋាន៖

-ប្រទេសផ្សេងៗទៀតអាចចាប់ផ្តើមនាំមុខគេ ដូចជាប្រទេសឥណ្ឌា និងបង់ក្លាដេសក្នុងការរក្សាកន្លែងពិសេសសម្រាប់ស្ត្រីជនជាតិភាគតិច និងក្រុមដែលបាត់បង់ផលប្រយោជន៍នៅក្នុងការបោះឆ្នោតមូលដ្ឋាន។

-ប្រព័ន្ធពីរ អាចឱ្យគេធ្វើការពិចារណាបាន គឺប្រព័ន្ធក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោត (ខាងផ្នែកនយោបាយ) និងក្រុមប្រឹក្សាដែលចេញពីការតែងតាំង (ផ្នែកបច្ចេកទេស)

-រដ្ឋាភិបាលកណ្តាល ប្រសិនបើអាចអនុវត្តទៅបាន ត្រូវចាត់ទុកការចូលរួមគឺជាធាតុផ្សំមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យ និងការបង្កើតឱ្យមានក្រុមស៊ីវិល គឺមិនមែនជាការធានាឱ្យមានការចូលរួមប្រកបដោយជោគជ័យនោះទេ។ផ្ទុយទៅវិញរដ្ឋាភិបាលគួរតែកសាងបច្ចេកទេសថ្មីឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងបំពាក់សម្ភារពួកគេ ឱ្យអាចចូលរួមបានព្រមទាំង

-ការរាប់បញ្ចូលសង្គម និងសមភាពយេនឌ័រ គឺជាបញ្ហាចម្បង ដែលចាំបាច់ត្រូវតែធ្វើការសិក្សាស្រាវជ្រាវឱ្យបានល្អិតល្អន់ថែមទៀត។

## ឯកសារពិគ្រោះ

Ahmed, S. G., *Local Government System in Bangladesh: Empowerment, Participation and Development*, Keynote Paper at Round Table on Local Government Reform, TSC, Dhaka University and Parliamentary System Council, 30 October 1997

Aulich, C., *Competition in Local Government*, in Dollery, B. and Marshall, N., Australian Local Government: Reform and Renewal, Macmillan, Melbourne, 1997

CITYNET, *Report and proceedings of the Bandung Regional Policy Workshop on Municipal Revenue Enhancing Strategies*, CITYNET publication, Bangkok, May 1996

ESCAP, *Living in Asian Cities: The Impending Crises-causes, consequences and alternatives for the future*, United Nations, New York, 1996

Mahathir, M., *Message for National Seminar on Public Service*, Seminar on the Public Service - New Strategic Dimensions for the 21st Century, Organized by Malaysian Administrative Modernization and Management Planning Unit, Prime Minister's Department, National Institute of Public Administration and Malaysia and Commonwealth Association for Public Administration and Management (CAPAM), 1 September 1995

Mathur , O. P. and von Einsiedel, N. (eds.), *Increasing the Income of Cities: Tapping the Potentials of Non-Land-Based Sources of Municipal Revenues*, UNCHS, 1996

Singh, K., Steinberg, F. and von Einsiedel, N. (eds.), *Integrated Urban Infrastructure Development in Asia*, Oxford and IBH Publishing, New Delhi, 1996

Turner, M. and Hume, D., *Governance, Administration and Development: Making the State Work*, Kumarian, West Hartford, Connecticut, 1997

# ឧបសម្ព័ន្ធ

## A-**ការថ្លែងសាររួមគ្នា** (Joint Message)

ឯកសារពិគ្រោះយោបល់នេះ បង្ហាញពីការចាប់ផ្តើមគម្រោងការភាពជាដៃគូដ៏មានសារសំខាន់ និងគួរឱ្យប្រាថ្នាដ៏លើសលប់រវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន។គោលបំណងរបស់វា គ្មានអ្វីក្រៅពីការបង្កើតក្របខ័ណ្ឌអនុវត្តប្រជាធិបតេយ្យមូលដ្ឋាន ឱ្យមានការឯកភាពជាលក្ខណៈអន្តរជាតិ ដែលជាការរួមវិភាគទានដ៏សំខាន់ ដើម្បីធ្វើឱ្យប្រសើរ ឡើងនូវលក្ខខណ្ឌជីវភាពរបស់ប្រជាជនក្នុងតំបន់ និងគ្រប់ទីបទាំងអស់។

នៅឯសន្និបាតអង្គការសហប្រជាជាតិលើកទី២ ស្តីអំពីការតាំងទីលំនៅមនុស្សជាតិ(HABIAT-II) ដែលលើកឡើងក្នុងទីក្រុងអ៊ីស្តានប៊ុល (Istanbul) ក្នុងខែមិថុនា ឆ្នាំ១៩៩៦ រដ្ឋាភិបាលជាតិបានប្តេជ្ញាចិត្តដោយខ្លួន ឯងថានឹងធ្វើវិមជ្ឈការអំណាច និងធនធាន (របៀបវារៈ Habitat កថាខ័ណ្ឌ ៤៥(ច)។ ពួកគេបានទទួលស្គាល់ផងដែរថា អាជ្ញាធរមូលដ្ឋានជាដៃគូដ៏កៀកនៃរដ្ឋាភិបាលកណ្តាល ហើយវាមានសារៈសំខាន់ក្នុងការអនុវត្តរបៀប វារៈ២១ និងរបៀបវារៈ Habitat (សេចក្តីប្រកាស អ៊ីស្តានប៊ុល កថាខ័ណ្ឌ ១២)។

ចាប់តាំងពី Habitat II , UNCHS (Habitat) បានអភិវឌ្ឍ

បន្ថែមនូវ ទំនាក់ទំនងការងារដ៏ជិតស្និទ្ធជាមួយសមាគមអន្តរជាតិទីក្រុង និងអាជ្ញាធរមូលដ្ឋាននៅក្នុងក្របខ័ណ្ឌនៃអនុស្សារណៈការយោគយល់គ្នាជាមួយ WACLAC បានបង្ហាញការតាំងចិត្តគ្នាទៅវិញទៅមក ដើម្បីសហការក្នុងផ្នែកនយោបាយសំខាន់ៗមួយចំនួន ដែលទាក់ទងដល់ការអនុវត្ត នៃរបៀបវារៈ Habitat (Habitat Agenda)។ ការរៀបចំធម្មនុញ្ញពិភពលោកស្ដីពីស្វ័យគ្រប់គ្រងមូលដ្ឋាន ជាកិច្ចការរួមគ្នាមួយក្នុងចំណោមកិច្ចការទាំងឡាយ។ UNCHS (Habitat) និង WACLAC មានការជឿជាក់រួមគ្នាថា ការបង្កើតគោលការណ៍ជាមូលដ្ឋាន និន្នាការវិមជ្ឈការ និងប្រជាធិបតេយ្យភាវូបនីយកម្មថ្មីៗនេះ បានទទួលស្វាគមន៍យ៉ាងកក់ក្ដៅពីបណ្ដាប្រទេសជាច្រើន ដោយសរសេររដ្ឋធម្មនុញ្ញរបស់ខ្លួនពឹងផ្អែកលើគោលការណ៍មូលដ្ឋាន ដែលទទួលស្គាល់ជាអន្តរជាតិលើស្វ័យគ្រប់គ្រងជាមូលដ្ឋាន ដែលជាការរួមចំណែកមួយយ៉ាងសំខាន់ក្នុងការអនុវត្ត Habitat Agenda ឱ្យមានប្រសិទ្ធភាព និងប្រកបដោយនិរន្តរភាព។

ឯកសារនេះពន្យល់អំពីប្រភពដើម សេចក្ដីប្រាថ្នា និងគោលបំណង នៃការរៀបចំធម្មនុញ្ញពិភពលោក និងការបង្កើតសេចក្ដីព្រាងដំបូងមួយនៃធម្មនុញ្ញតែម្ដង។ឯកសារនេះក៏មានការរៀបចំការពិគ្រោះយោបល់ទូលំទូលាយ ទូទាំង

ពិភពលោក និងដំណើរការស្វែងរកការព្រមព្រៀង ជាកុងសង់ស៊ីសចាប់ផ្តើមពីពេលនេះតទៅ តាមរយៈការខិតខំបង្ហាញអត្ថបទសេចក្តីព្រាង ចុងក្រោយឱ្យបានខ្លាំងក្លាបំផុតសម្រាប់គណៈកម្មការអង្គការសហប្រជា ជាតិស្តីពីការតាំងទីលំនៅមនុស្សជាតិ អនុម័តនៅឆ្នាំ២០០១។

គោលបំណងចុងក្រោយបំផុត គឺការប្រកាសធម្មនុញ្ញដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងឱកាសសម័យប្រជុំពិសេសក្នុងឆ្នាំនោះ ដែលផ្តោតទៅលើការត្រួតពិនិត្យឡើងវិញនៃការអនុវត្ត Habitat Agenda ។

រដ្ឋាភិបាលជាតិ និងអន្តរជាតិ អាជ្ញាធរមូលដ្ឋាន និងសមាគមរបស់ពួកគេ សមាជិកសភា អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលគ្រប់ប្រភេទទាំងអស់ ត្រូវបានអញ្ជើញឱ្យចូលរួមយ៉ាងសកម្មក្នុងការអនុវត្តបន្ថែម នៃធម្មនុញ្ញពិភពលោក ដែលយើងជឿជាក់ថា ជាការចូលរួមចំណែកដ៏សំខាន់បំពេញបន្ថែមគោលបំណងបរិស្ថានធម្មជាតិ នៃលំនៅដ្ឋាន (Habitat ) របស់យើង។

Dr.Klaus Topfer អគ្គនាយក និងជាប្រធាននៃមជ្ឈមណ្ឌលអង្គការសហប្រជាជាតិ សម្រាប់ការតាំងទីលំនៅមនុស្សជាតិ ( Habitat ) ។

Dr.Heinrich Hoffschulte ប្រធានក្រុមអ្នកជំនាញការ

ស្តីពីធម្មនុញ្ញពិភពលោក។

**B-ប្រភពគោលបំណង និងដំណើរការរៀបចំសំណើ**

**ក-សាវតារ**

១-កិច្ចប្រជុំរបស់សមាគមពិភពលោកនៃទីក្រុង និងអាជ្ញាធរមូលដ្ឋាន ដែលបានប្រព្រឹត្តទៅនៅក្នុងទីក្រុងអ៊ីស្តានប៊ុល (Istanbul) នៅថ្ងៃទី៣០ ដល់៣១ ខែឧសភា ឆ្នាំ១៩៩៦ នៅមុនថ្ងៃសន្និបាតអង្គការសហប្រជាជាតិលើកទី២ ស្តីពីការតាំងទីលំនៅមនុស្សជាតិ (Habitat) បានអំពាវនាវឱ្យសមាគមអន្តរជាតិចាប់ផ្តើមធ្វើព្រាងធម្មនុញ្ញពិភពលោកមួយ ស្តីពីស្វ័យភាពគ្រប់គ្រងមូលដ្ឋាន ក្នុងភាពជាដៃគូជាមួយអ្នកតំណាងសមាគមនៃអាជ្ញាធរមូលដ្ឋាន សម្រាប់បង្កើតគោលការណ៍មូលដ្ឋាន ដែលជាមូលដ្ឋាននៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានតាមបែបប្រជាធិបតេយ្យមួយ សម្រាប់ជាមាគ៌ារបស់រដ្ឋាភិបាលជាតិទាំងអស់ និងភ្នាក់ងារអន្តរជាតិទាំងឡាយ។

មានន័យថា មូលដ្ឋាននៃធម្មនុញ្ញនេះ គួរតែមានគោលការណ៍ ស្តីពីមុខការសមត្ថកិច្ចក្នុងពេលគ្មានច្បាប់ចែងច្បាស់ និងភាពនៅជិតបំផុត ដែលសេចក្តីសម្រេច គួរធ្វើឡើងនៅថ្នាក់ជិតបំផុតនឹងប្រជាពលរដ្ឋ (ទីក្រុង ឬជនបទ) ហើយថាភារកិច្ចណា ដែលថ្នាក់មូលដ្ឋានមិនអាចអនុវត្តឱ្យមានប្រសិទ្ធភាពបាន គួរតែផ្ទេរទៅឱ្យថ្នាក់ខ្ពស់ជាង។

២-ការពិភាក្សា វែកញែកនៅឯកិច្ចប្រជុំពិភពលោក បានផ្ដោតការព្រមព្រៀងជាទូទៅ ចំពោះគោលជំហរធម្មនុញ្ញអាជ្ញាធរមូលដ្ឋាន និងទំនាក់ទំនងរបស់អាជ្ញាធរមូលដ្ឋាន ជាមួយរដ្ឋាភិបាលកណ្ដាល ក្នុងការបំពេញតួនាទីរបស់ខ្លួន ។

ក្នុងបរិបទនេះ បទពិសោធន៍ជាវិជ្ជមាននៃធម្មនុញ្ញអឺរ៉ុបស្ដីពីស្វ័យគ្រប់គ្រងមូលដ្ឋាន ដែលអនុម័តដោយក្រុមប្រឹក្សាអឺរ៉ុបឆ្នាំ១៩៨៥ ជាអនុសញ្ញាអឺរ៉ុប ហើយបច្ចុប្បន្នត្រូវបានចុះហត្ថលេខា និងឱ្យសច្ចាប័នដោយភាគច្រើនបំផុតនៅក្នុងចំណោមរដ្ឋជាសមាជិកទាំង៤០ របស់ក្រុមប្រឹក្សាអឺរ៉ុប ត្រូវបានគេលើកយកមកបង្ហាញក្នុងការពិភាក្សាវែកញែក។

៣-ករណីការប្រកាសជាផ្លូវការនៃធម្មនុញ្ញពិភពលោក ដោយអង្គការសហប្រជាជាតិ ត្រូវបានប្រតិភូអាជ្ញាធរមូលដ្ឋាន លើកយកមកធ្វើបទអត្ថាធិប្បាយបង្ហាញ នៅឯកិច្ចសន្និសីទចំពោះមុខគណៈកម្មាធិការទីII នៃមហាសន្និបាត Habitat II នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៩៦ ហើយការព្រួយបារម្ភនេះ ត្រូវបានកត់ត្រាទុកនៅក្នុងរបាយការណ៍ជាផ្លូវការនៃកិច្ចសន្និសីទនោះ (កថាខណ្ឌ II)។ ប្រធានបទ សង្ខេបសន្និសីទនោះ (កថាខណ្ឌទី២៣) បានផ្អែកលើបញ្ហាដូចខាងក្រោម ៖

ការតម្រូវឱ្យមានការអភិវឌ្ឍច្បាប់ និងលិខិតបទដ្ឋាន

ជាតិ ដែលចែងបញ្ជាក់ច្បាស់អំពីតួនាទី និងការទទួលខុសត្រូវនៃអាជ្ញាធរមូលដ្ឋាន ចំពោះរដ្ឋាភិបាលថ្នាក់ជាតិ និងអនុវត្តការងាររិមជ្ឈការ និងប្រជាធិបតេយ្យនៅមូលដ្ឋាន ឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយគិតដល់គោលការណ៍ស្វ័យតភាពមុខងារសមត្ថកិច្ច និងភាពនៅជិតនឹងប្រជាពលរដ្ឋ ត្រូវបានលើកឡើងដែរ។ ក្នុងបរិបទនេះ គេបានស្នើថា បទពិសោធន៍ដែលទទួលបានពីការអនុវត្ត ធម្មនុញ្ញអឺរ៉ុបស្តីពីស្វ័យគ្រប់គ្រងមូលដ្ឋាន អាចជាមូលដ្ឋានសម្រាប់ការ អភិវឌ្ឍធម្មនុញ្ញពិភពលោកមួយ ដែលដាក់ចេញគោលការណ៍សំខាន់ៗ ជាក្របខ័ណ្ឌធម្មនុញ្ញ ឬក្របខ័ណ្ឌច្បាប់ដ៏រឹងមាំសម្រាប់ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានប្រជាធិបតេយ្យមួយ។

៤-ការរៀបចំធម្មនុញ្ញពិភពលោកស្តីពីស្វ័យគ្រប់គ្រងមូលដ្ឋាន បង្ហាញគោលបំណងនានា ដែលបានគូសបញ្ជាក់នៅក្នុងរដ្ឋធម្មនុញ្ញ នៃសមាគមទីក្រុង និងការសម្របសម្រួលអាជ្ញាធរមូលដ្ឋានពិភពលោក (WACLAC) បង្ហាញរចនាសម្ព័ន្ធដែលដាក់ចេញដោយសមាគម រដ្ឋាភិបាលមូលដ្ឋានអន្តរជាតិទាំង១០ ដែលបានបើកសន្និបាតពិភពលោក ដើម្បីឆ្លើយតបការអំពាវ នាវរបស់អង្គសន្និបាតសម្រាប់បន្តការសម្របសម្រួល ដើរតួជាដៃគូសន្ទនា និងជាដៃគូស្ថាប័នរបស់អង្គការសហប្រជាជាតិនិងភ្នាក់ងារជំនាញរបស់ខ្លួន។ WACLAC

ប្រមើលមើលទុកជាមុនថា ធម្មនុញ្ញពិភពលោកនេះនឹងអាចគ្រោងធ្វើឡើង ដើម្បីឱ្យមានប្រសិទ្ធភាពបំផុតនៅក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាលជាតិ តាមរយៈយន្តការរបស់អង្គការសហប្រជាជាតិ ស្របទៅតាមអត្ថបទចុងក្រោយ ដែលនឹងត្រូវប្រកាសឱ្យប្រើជាអនុសញ្ញាផ្លូវការ របស់អង្គការសហប្រជាជាតិ។

**ខ-គម្រោងស្តីពីភាពជាដៃគូ**

៥-ការចរចាជាបន្តបន្ទាប់នៅក្នុងកំឡុងពេលប្រជុំតាមដានយ៉ាង ប្រញាប់ឆ្ពោះទៅកាន់ Habitat II ហើយក្នុងឱកាសនៃសម័យប្រជុំលើកទី១៦ របស់គណៈកម្មការ អង្គការសហប្រជាជាតិ ស្តីអំពីការតាំងទីលំនៅមនុស្សជាតិក្នុងខែមេសា-ឧសភា ឆ្នាំ១៩៩៧ អនុស្សារណៈ ស្តីពីការយោគយល់គ្នារវាង UNCHs និង WACLACR ដែលបានចុះហត្ថលេខានៅ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៧ ក្នុងទីក្រុងញូយ៉កតម្រូវឱ្យភាគីទាំងពីរត្រូវ ទទួលខុសត្រូវរៀបចំធម្មនុញ្ញពិភពលោក ដែលជាសកម្មភាពអាទិភាពចម្បងមួយ ក្នុងចំណោមសកម្មភាពអាទិភាពទាំង៤ ពោលគឺៈ

ដោយសារមានការពង្រឹងតួនាទី និងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍការតាំងទីលំនៅមនុស្សជាតិឱ្យប្រកបដោយចីរភាព និងមានប្រសិទ្ធ

ភាពខ្ពស់ ភាគីទាំងពីរចាប់ពីពេលនេះ បានយល់ព្រមទទួលអនុវត្តគម្រោងការរួមគ្នា ពោលគឺធម្មនុញ្ញពិភពលោកស្តីអំពីស្វ័យគ្រប់គ្រងមូលដ្ឋាន។ ជាងនេះទៅទៀត WACLAC និង UNCHs នឹងបង្កើតក្រុមការងាររួមមួយ ទទួលបន្ទុកគម្រោងការងាររួមមាន ៖

-ការប្រមូលមូលនិធិរួមគ្នា សម្រាប់គម្រោងការនេះ

-ការទទួលស្គាល់និងការប្រមូលចងក្រងចំណេះដឹងដែលមានស្រាប់ (ដូចជាឯកសារការសិក្សាស្រាវជ្រាវរបាយការណ៍ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានាជាដើម) ដែលទាក់ទងនឹងស្វ័យអភិបាលកិច្ចមូលដ្ឋាន នៅថ្នាក់ជាតិ និងអន្តរជាតិ តាមរយៈ ៖

ក-ការរៀបចំកិច្ចប្រជុំសម្រាប់ក្រុមជំនាញការពិសេស

ខ-ការរៀបចំកិច្ចពិគ្រោះយោបល់តាមតំបន់ឬអនុតំបន់

គ-ការរៀបចំឯកសារសេចក្តីព្រាងដើម្បីដាក់ជូនឆ្លងគណៈកម្មការ ស្តីពីការតាំងទីលំនៅមនុស្សជាតិ ដាក់ជូនអង្គភាពពាក់ព័ន្ធសមរម្យ គណៈកម្មការ និងគណៈកម្មាធិការរបស់អង្គការសហប្រជាជាតិ។

៦-របាយការណ៍បច្ចុប្បន្ន គឺផ្អែកទៅលើលទ្ធផលកិច្ចប្រជុំនៃក្រុមអ្នកជំនាញការពិសេសលើកដំបូង ដែលធ្វើឡើងនៅប្រទេស Nairobi ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមេសា

ឆ្នាំ១៩៩៨ ដោយយោងទៅតាមបទប្បញ្ញត្តិស្តីពីអនុស្សារណៈនៃការយោគយល់គ្នាដូចបានជម្រាបជូនខាងលើ។ កិច្ចប្រជុំនេះពិនិត្យមើលបទពិសោធន៍ឡើងវិញ ដែលទទួលបានពីសមាគមអន្តរជាតិមួយចំនួន ដែលធ្វើការក្នុងវិស័យនេះ ដូចជាការរៀបចំ និងការអនុវត្តជាបន្តបន្ទាប់នៃធម្មនុញ្ញអឺរ៉ុបស្តីពីស្វ័យគ្រប់គ្រងមូលដ្ឋាន តែងសេចក្តីព្រាងអត្ថបទដំបូងសម្រាប់ធ្វើជាធម្មនុញ្ញពិភពលោក និងអត្ថបទសំណើនានាដែលរៀបចំសម្រាប់ការពិគ្រោះយោបល់ទូលំទូលាយ និងដំណើរការស្វែងរកការព្រមព្រៀងជាកុងសង់ស៊ីស ដែលត្រូវអនុវត្តក្នុងកំឡុងពេលតាមដានការអនុវត្តរយៈពេល៥ឆ្នាំ នៃលទ្ធផលសន្និសីទ Habitat II របស់មហាសន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ ២០០១ ។

**គ-យុទ្ធសាស្ត្រនៃធម្មនុញ្ញអឺរ៉ុបស្តីពីស្វ័យគ្រប់គ្រងមូលដ្ឋាន**

៧-គំនិតផ្តួចផ្តើមដំបូងស្តីអំពីទម្រង់ សម្រាប់ការទទួលស្គាល់ជាអន្តរជាតិ នូវគោលការណ៍ស្វ័យភាពមូលដ្ឋាន (នា-សម័យទំនើប) ត្រូវបានលើកឡើងដោយអង្គមហាសន្និបាតលើកទី១ របស់ក្រុមប្រឹក្សាទីក្រុងអឺរ៉ុបនៅទីក្រុងវែកសៃ (Versailles) នាឆ្នាំ១៩៥៣។ "**ធម្មនុញ្ញអឺរ៉ុបស្តីពីសេរីភាពទីក្រុង** " បានអនុម័តនៅក្នុងឱកាសនោះ គឺបង្ហាញពីការប្តេជ្ញាចិត្តរបស់អ្នកគាំទ្រ ដើម្បីកសាងទ្វីបអឺរ៉ុបក្រោយសង្គ្រាមឡើង

វិញដោយផ្អែកលើមូលដ្ឋាន របស់ស្ថាប័នមូលដ្ឋានខ្លាំងដែលទទួលបានស្វ័យភាពកម្រិតខ្ពស់តាមបែបប្រជាធិបតេយ្យ ។ ក្នុងឆ្នាំជាបន្តបន្ទាប់ ក្រុមប្រឹក្សាទីក្រុងអឺរ៉ុប (បច្ចុប្បន្នក្រុមប្រឹក្សាទីក្រុងនិងតំបន់អឺរ៉ុប ផ្នែកសហភាពអន្តរជាតិនៃអាជ្ញាធរមូលដ្ឋានរបស់អឺរ៉ុប) បានចាប់ផ្តើមគាំទ្រគំនិតផ្តួចផ្តើមជាបន្តបន្ទាប់ដើម្បីឱ្យស្ថាប័នអឺរ៉ុប អនុម័តធម្មនុញ្ញនេះជាផ្លូវការ។

៨-ទោះបីយ៉ាងណាក៏ដោយវាប្រើពេលរហូតដល់ចុងឆ្នាំ១៩៧០ ដើម្បីទទួលបានចម្លើយនិងការរៀបចំសេចក្តីព្រាងធម្មនុញ្ញអឺរ៉ុប ស្តីពីស្វ័យគ្រប់គ្រងមូលដ្ឋាន ពីសំណាក់សន្និបាតអចិន្ត្រៃយ៍នៃអាជ្ញាធរថ្នាក់តំបន់ និងមូលដ្ឋានរបស់អឺរ៉ុប (Standing Conference of Local and Regional Authorities of Europe ដែលហៅកាត់ថា CLRAE ) តំណាងស្ថាប័នផ្លូវការសម្រាប់ថ្នាក់តំបន់ និងមូលដ្ឋាននៃរដ្ឋាភិបាលរបស់សហគមន៍អឺរ៉ុប ។ អត្ថបទនេះត្រូវបានរៀបចំបង្កើតឡើង ក្រោយពីមានការសិក្សាលំអិតរបស់គណៈកម្មាធិការតំណាង ដោយមានជំនួយពីក្រុមជំនាញការច្បាប់ធម្មនុញ្ញដោយផ្អែកលើមូលដ្ឋានច្បាប់អនុសញ្ញាអឺរ៉ុប និងត្រូវបានអនុម័តដោយ CLRAE នៅឆ្នាំ១៩៨១ ហើយបានផ្ញើទៅគណៈកម្មាធិការរដ្ឋមន្ត្រីក្រុមប្រឹក្សាអឺរ៉ុប ដើម្បីមុខការ។

ការអនុម័តយកគោលការណ៍អនុសញ្ញនេះ ត្រូវបាន

ជានាពីអង្គសន្និបាតលើកទី៥ របស់ក្រុមរដ្ឋមន្ត្រីអឺរ៉ុប ដែលទទួលបន្ទុករដ្ឋាភិបាលមូលដ្ឋាននៅឆ្នាំ១៩៨២ ហើយអត្ថបទដែលបានស្នើឡើងដោយ CLRAE ត្រូវបានបញ្ជូនទៅគណៈកម្មាធិការមន្ត្រីជាន់ខ្ពស់ របស់រដ្ឋជាសមាជិក ដើម្បីពិនិត្យពិច័យលំអិត ដោយមានការចូលរួមពីតំណាងរដ្ឋាភិបាលមូលដ្ឋាន ដែលចាត់តាំងដោយ CLRAE ។

៩-លទ្ធផលចុងក្រោយនៃការពិនិត្យពិច័យនេះ គឺជាអត្ថបទធម្មនុញ្ញអឺរ៉ុបនាពេលបច្ចុប្បន្ន ដែលត្រូវបានរៀបចំជាទម្រង់ចុងក្រោយនៃអនុសញ្ញាអឺរ៉ុប និងបើកឱ្យមានការចុះហត្ថលេខានៅឆ្នាំ១៩៨៥ ។ ធម្មនុញ្ញនេះបានចូលជាធរមានអនុវត្តនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៨៨ នៅពេលប្រទេសចំនួន០៤ បានផ្តល់សច្ចាប័ន។ បន្ទាប់មក មានប្រទេសចំនួន១៦បានចុះហត្ថលេខាអនុសញ្ញានេះ។ ធម្មនុញ្ញនេះ បច្ចុប្បន្នត្រូវបានផ្តល់សច្ចាប័នដោយប្រទេសអឺរ៉ុបចំនួន៣០ ហើយគេប្រើប្រាស់វាធ្វើជាគោលការណ៍ណែនាំដ៏សំខាន់ នៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់មូលដ្ឋានពាក់ព័ន្ធនឹងរដ្ឋាភិបាលមូលដ្ឋានសម្រាប់ប្រទេសជាច្រើននៅអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត ដែលបានចូលជាសមាជិកភាពក្រុមប្រឹក្សាអឺរ៉ុប នាឆ្នាំកន្លងទៅថ្មីៗនេះ។

គោលការណ៍ស្តីអំពីស្វ័យគ្រប់គ្រងមូលដ្ឋាន ត្រូវបាន

ចាត់ទុកជាសមាសធាតុចាំបាច់ សម្រាប់ជាគោលការណ៍គ្រឹះនៃក្រុមប្រឹក្សាអឺរ៉ុប ស្តីពីលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ ដែលទាមទារឱ្យមានការចុះហត្ថលេខាលើធម្មនុញ្ញអឺរ៉ុប ស្តីអំពីស្វ័យភាពគ្រប់គ្រងមូលដ្ឋាន ព្រមជាមួយនឹងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស នៅពេលចូលជាសមាជិកថ្មី។

**ឃ-ខ្លឹមសារធម្មនុញ្ញអឺរ៉ុប**

១០-ធម្មនុញ្ញអឺរ៉ុប តម្រូវឱ្យភាគីនីមួយៗ អនុវត្តវិធានមូលដ្ឋាន ដោយធានាឱ្យបាននូវឯករាជ្យភាពនយោបាយ រដ្ឋបាល និងហិរញ្ញវត្ថុរបស់អាជ្ញាធរមូលដ្ឋាន។ នេះជាការបង្ហាញឆន្ទៈនយោបាយនៅកម្រិតអឺរ៉ុប ដើម្បីផ្តល់សារសំខាន់ដល់ថ្នាក់រដ្ឋបាលដែនដីគ្រប់កម្រិត ទទួលបាននូវគោលការណ៍គ្រឹះលទ្ធិប្រជាធិបតេយ្យ ដែលក្រុមប្រឹក្សាអឺរ៉ុបបានប្រកាន់យកចាប់តាំងពីការបង្កើតក្រុមប្រឹក្សានេះ នៅឆ្នាំ១៩៤៩។ ការពិតធម្មនុញ្ញនេះ បង្ហាញការជឿជាក់ថា កម្រិតស្វ័យគ្រប់គ្រងដែលអាជ្ញាធរមូលដ្ឋានទទួលបាន អាចចាត់ទុកជាគំរូលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

១១-ធម្មនុញ្ញនេះ មានចែងជាមាត្រាច្បាស់លាស់ចំនួន១០មាត្រា ដែលរួមមាន៣០កថាខ័ណ្ឌ មានគោលការណ៍សំខាន់ៗ ស្តីពីស្វ័យគ្រប់គ្រងមូលដ្ឋានស្របតាមបរិបទអឺរ៉ុប។ វាចែងបញ្ជាក់ច្បាស់ ពីតម្រូវការមូលដ្ឋាន រដ្ឋធម្មនុញ្ញ ច្បាប់

សម្រាប់ស្វ័យគ្រប់គ្រងមូលដ្ឋាន កំណត់ពីគោលគំនិត និង បង្កើតគោលការណ៍គ្រប់គ្រងប្រភេទ និងវិសាលភាពអំណាច នៃអាជ្ញាធរមូលដ្ឋាន។ លើសពីនេះទៀត មាត្រាទាំងឡាយ កំណត់នីតិវិធីច្បាស់លាស់ ដើម្បីអនុវត្តស្របតាមការផ្លាស់ប្តូរ ព្រំប្រទល់សម្រាប់ស្វ័យភាព ដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ រដ្ឋបាលរបស់អាជ្ញាធរមូលដ្ឋាន និងការជ្រើសរើសបុគ្គលិក ដែលមានសមត្ថភាព និងកំណត់លក្ខខណ្ឌសមរម្យសម្រាប់ ការចូលកាន់តំណែង ដែលកើតចេញពីការបោះឆ្នោត ។

បទប្បញ្ញត្តិមួយចំនួនទៀត សំដៅធានាឱ្យមានក្រប ខ័ណ្ឌច្បាប់ច្បាស់លាស់ សម្រាប់ត្រួតពិនិត្យសកម្មភាពចាំ បាច់នៃអាជ្ញាធរមូលដ្ឋាន និងសំដៅធានាថា អាជ្ញាធរមូលដ្ឋាន មានប្រភពធនធានគ្រប់គ្រាន់ សមស្របតាមភារកិច្ចរបស់ ខ្លួន ពោលគឺក្នុងន័យថា មិនធ្វើឱ្យប៉ះពាល់ដល់ស្វ័យភាព មូលដ្ឋានរបស់ខ្លួន។ ទីបញ្ចប់ធម្មនុញ្ញនេះ មាននិយាយពីសិទ្ធិ របស់អាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើសហប្រតិបត្តិការ រួមទាំង សហប្រតិបត្តិការអន្តរជាតិ និងដើម្បីបង្កើតសមាគមនានា និងផ្តល់សិទ្ធិ ធ្វើបណ្តឹងឧបាស្រ័យ ដើម្បីដោះស្រាយតាម ផ្លូវតុលាការ សម្រាប់ការការពារស្វ័យភាពមូលដ្ឋាន។

១២-អនុលោមតាមគោលបំណងក្នុងការធានាឱ្យមាន គុណភាព ប្រាកដនិយមរវាងការការពារគោលការណ៍ ជា

សារវន្តសំខាន់ៗ និងភាពដែលអាចបត់បែនបាន ដើម្បីកំណត់លក្ខណៈសម្បត្តិផ្លូវច្បាប់ និងស្ថាប័នមួយចំនួនរបស់រដ្ឋ ជាសមាជិកផ្សេងៗ ធម្មនុញ្ញនេះ តម្រូវឱ្យភាគីជាប់កិច្ចសន្យាត្រូវពិចារណាដោយខ្លួនឯង យ៉ាងហោចណាស់ត្រូវគោរពតាម២០កថាខ័ណ្ឌ ក្នុងចំណោមកថាខ័ណ្ឌសារធាតុចំនួន៣០ និងយ៉ាងហោចណាស់គោរពបទប្បញ្ញត្តិសំខាន់ៗចំនួន១០ ដែលមានបញ្ជីចែងបញ្ជាក់ស្រាប់ ។ ដូច្នេះរដ្ឋទាំងឡាយអាចដកខ្លួនចេញពីបទប្បញ្ញត្តិមួយចំនួន នៅពេលផ្ដល់សច្ចាប័នយល់ព្រមប៉ុន្តែអាចចុះហត្ថលេខាយល់ព្រម លើបញ្ញត្តិទាំងនោះនៅពេលក្រោយបាននៅពេលដែលដោះស្រាយ បាននូវឧបសគ្គពាក់ពន្ធ័ទាំងឡាយ។ រដ្ឋទាំងឡាយក៏អាចកំណត់ការអនុវត្តធម្មនុញ្ញនេះត្រឹមកម្រិត ឬប្រភេទណាមួយនៃអាជ្ញាធរមូលដ្ឋាន ពោលគឺដើម្បីសមស្របនឹងព្រឹត្តិការណ៍របស់ប្រទេសទាំងឡាយ ដែលមានរចនាសម្ព័ន្ធសហព័ន្ធ។

១៣-ធម្មនុញ្ញនេះ មិនបានកំណត់អំពីប្រព័ន្ធស្ថាប័នត្រួតពិនិត្យលើការអនុវត្តរបស់ខ្លួនទេ ក្រៅពីតម្រូវការឱ្យភាគីទាំងឡាយត្រូវផ្ដល់ព័ត៌មានសំខាន់ៗទាំងអស់ ដែលទាក់ទិននឹងការចាត់វិធានការច្បាប់ ឬវិធានការផ្សេងទៀត ដើម្បីគោរពទៅតាមធម្មនុញ្ញនេះ។ តម្រូវការឱ្យមានយន្តការត្រួតពិនិត្យពិសេស ដូចមាននៅក្នុងអនុញ្ញាអឺរ៉ុបមួយចំនួនទៀត ត្រូវយក

មកពិចារណា ប៉ុន្តែអាចសន្និដ្ឋានថា អត្ថិភាពរបស់ CLRAE ដែលជាក្រុមប្រឹក្សាផ្លូវការរបស់ស្ថាប័នអឺរ៉ុប ដែលតំណាងអាជ្ញាធរមូលដ្ឋាន និងតំបន់របស់រដ្ឋជាសមាជិកទាំងអស់ ដែលអាចចូលផ្ទាល់ទៅក្នុងគណៈកម្មាធិការរដ្ឋមន្ត្រី ដើម្បីធានាការត្រួតពិនិត្យអនុលោមភាពនយោបាយសមស្រប។

១៨-ក្នុងឆ្នាំកន្លងទៅថ្មីៗនេះ CLRAE បានចាប់ផ្ដើមដំណើរការត្រួតពិនិត្យស្វ័យភាពមូលដ្ឋានរបស់រដ្ឋ នៅក្នុងរដ្ឋជាសមាជិកណាមួយ ដោយប្រើមធ្យោបាយត្រួតពិនិត្យ អនុ-លោមភាពនៃបទប្បញ្ញត្តិធម្មនុញ្ញនេះ ។ នៅក្នុងដំណើរការនេះ ទទួលបានជំនួយពីសមាគមអ្នកជំនាញ ការសិក្សាស្រាវជ្រាវដែលបានបង្កើតនាពេលថ្មីៗនេះ សមាគមរដ្ឋាភិ-បាលមូលដ្ឋានអឺរ៉ុប សម្រាប់ការសិក្សាស្រាវជ្រាវ(European Local Government Association for Research ដែលហៅកាត់ថា: ELGAE )។ លើសពីនេះ ចាប់ពីពេលនេះតទៅ CLRAE ប្រើប្រាស់ធម្មនុញ្ញនេះជាអចិន្ត្រៃយ៍ ធ្វើជាគំរូក្នុងការពិចារណាទិដ្ឋភាពនយោបាយទូលំទូលាយ និងបញ្ហាអភិ-បាលកិច្ច ដែលមាននៅក្នុងរបៀបវារៈរបស់ខ្លួន។

**ខ-ដំណើរឆ្ពោះទៅកាន់ធម្មនុញ្ញពិភពលោក**

១៥-បទប្បញ្ញត្តិនៃធម្មនុញ្ញអឺរ៉ុបនេះ ប្រហែលជានិមិត្តរូបនៃសាកលភាព និងភាពច្បាស់លាស់មួយ ពោលគឺចាប់

តាំងពីការអនុម័តធម្មនុញ្ញនេះ គ្មានដំណើរការកែប្រែ ដើម្បីផ្លាស់ប្ដូរអត្ថបទទេ ហើយធម្មនុញ្ញនេះត្រូវបានចុះហត្ថលេខា និងផ្ដល់សច្ចាប័នយល់ព្រមជាបន្តបន្ទាប់ ពីសំណាក់ប្រទេសសំខាន់ៗមួយចំនួន រួមមានប្រទេសនៅអឺរ៉ុបខាងកើត នៅពេលធ្វើសេចក្ដីព្រាងធម្មនុញ្ញនេះ ប្រទេសទាំងនោះមិនទាន់ក្លាយជាសមាជិកក្រុមប្រឹក្សាអឺរ៉ុបនៅឡើយ ដូច្នេះហើយគឺគ្មានការពាក់ព័ន្ធនៅក្នុងដំណើរការនោះទេ។

អត្ថិភាពរបស់ធម្មនុញ្ញនេះ ស្ញប្បីតែគ្មានសមត្ថភាពអនុវត្តជាផ្លូវការក៏ដោយ ក៏អាចជាការដាក់សម្ពាធខាងផ្នែកសីលធម៌ទៅលើរដ្ឋាភិបាលអឺរ៉ុបទាំងអស់ ហើយប្រាកដណាស់ថា ការរំលោភបំពានធ្ងន់ធ្ងរណាមួយនឹងទទួលបានការចាប់អារម្មណ៍ពីមតិសាធារណៈយ៉ាងខ្លាំង នៅក្នុងCLRAEនិងនៅក្នុងអង្គសភា និងគណៈកម្មាធិការរដ្ឋមន្ត្រីរបស់ក្រុមប្រឹក្សាអឺរ៉ុប និងនៅក្នុងប្រភពប្រព័ន្ធផ្សព្វផ្សាយ។ នៅពេលសរសេរសេចក្ដីព្រាងដំបូង មានអ្នកខ្លះបានចាត់ទុកធម្មនុញ្ញនេះ ថាជាការអនុវត្តទ្រឹស្ដីប្រតិបត្តិការកម្រិត ការងារប្រចាំថ្ងៃ នៃការទំនាក់ទំនងរវាងរដ្ឋាភិបាលកណ្ដាល និងរដ្ឋាភិបាលមូលដ្ឋាន ដែលប្រវត្តិសាស្ត្រនាពេលថ្មីៗនេះ បានបង្ហាញជំហរផ្សេងទៅវិញ ។ អភិបាលក្រុងអឺរ៉ុប និងរដ្ឋាភិបាលអឺរ៉ុបមួយចំនួនតូច នឹងចោទសួរអំពីតម្លៃ នៃការប្រកាន់យកស្តង់ដារ ដែល

បានកំណត់ជាអន្តរជាតិ នៅក្នុងសៀវភៅលក្ខន្តិកៈថា ជាការការពារដោយរដ្ឋធម្មនុញ្ញអំពីស្វ័យគ្រប់គ្រងមូលដ្ឋាន។

១៦-លក្ខណៈសកលភាពនៃគោលការណ៍ភាគច្រើនបំផុត ដែលមាននៅក្នុងធម្មនុញ្ញអឺរ៉ុប ត្រូវបានទទួលស្គាល់ដោយសហភាពអន្តរជាតិនៃអាជ្ញាធរមូលដ្ឋាន(International Union of Local Authorities ហៅកាត់ថា IULA) នៅឆ្នាំ១៩៨៥ ដោយអនុម័ត យល់ព្រមលើសេចក្ដីប្រកាសពិភពលោក ស្ដីពីគោលការណ៍ស្វ័យគ្រប់គ្រងមូលដ្ឋាន នៅក្នុងសន្និបាតពិភពលោករបស់ខ្លួននៅទីក្រុង Rio de Janeiro ដែលសេចក្ដីព្រាងនៃសេចក្ដីប្រកាសនេះ បានពឹងផ្អែកច្រើនលើយុត្តិសាស្ត្រដែលជាទម្លាប់អនុវត្តរបស់អឺរ៉ុប។សន្និបាតរបស់ IULA នៅទីក្រុង Toroto នាឆ្នាំ១៩៩៣ បានបញ្ជាក់ឡើងវិញ នូវអត្ថបទសេចក្ដីប្រកាសទូទាំងពិភពលោក ដោយមានបុព្វកថា បានធ្វើបច្ចុប្បន្នភាពទៅលើនូវចំណុចសំខាន់ៗ ដែលពាក់ព័ន្ធនឹងនិន្នាការវិមជ្ឈការ និងប្រជាធិបតេយ្យនៅក្នុងផ្នែកជាច្រើនរបស់ពិភពលោក។ នៅឯសន្និបាតពិភពលោករបស់ IULA ក្នុងទីក្រុង Maurities នៅខែមេសា ឆ្នាំ១៩៩៧ បទពិសោធន៍ដែលពាក់ព័ន្ធនឹងធម្មនុញ្ញអឺរ៉ុបរហូតមកដល់ពេលនេះ និងសេចក្ដីប្រកាសពិភពលោក ត្រូវបានបង្ហាញនៅក្នុងសម័យប្រជុំសាមញ្ញ ដែលមានសមាជិកចូលរួមយ៉ាងច្រើនបានផ្ដោត

ការយកចិត្តទុកដាក់ទៅលើជំហានទី១ ឆ្ពោះទៅធម្មនុញ្ញពិភពលោក នៅទីក្រុង Istanbul ។ សេចក្ដីប្រកាសចុងក្រោយរបស់អង្គសន្និបាតរួមមានការអំពាវនាវសុំឱ្យអង្គការ ភ្នាក់ងារអន្តរជាតិ និងរដ្ឋាភិបាលជាតិនានា សហការគ្នាជាមួយរដ្ឋាភិបាលមូលដ្ឋាន សមាគម បណ្ដាញថ្នាក់ជាតិតំបន់ និងអន្តរជាតិរបស់អាជ្ញាធរមូលដ្ឋាន ដើម្បីអភិវឌ្ឍនិងប្រកាសជាផ្លូវការ តាមរយៈអង្គការសហប្រជាជាតិ នូវធម្មនុញ្ញពិភពលោកស្ដីពីស្វយ័គ្រប់គ្រងមូលដ្ឋាន និងបន្តអនុវត្តឱ្យបានលឿនទៅគ្រប់ទីបទាំងអស់ តាមរយៈទិវា "ទសវត្សរ៍ពិភពលោករបស់រដ្ឋាភិបាលមូលដ្ឋាន២០០០-២០០៩" ។ មុនពេលនេះ ផ្នែក IULA អឺរ៉ុប គឺ " ក្រុមប្រឹក្សាតំបន់ និងទីក្រុងនៅអឺរ៉ុប " នៅឯសន្និបាតរបស់ខ្លួន នៅទីក្រុង Thessaloniki នាខែឧសភា ឆ្នាំ១៩៩៦ គឺនៅមុនពេលសន្និបាតពិភពលោកស្ដីពីទីក្រុង និងសន្និបាត Habitat II នៅទីក្រុង Istanbul បានសំណូមពរសហគមន៍អន្តរជាតិ ប្រកាន់យកជំហានដាច់ណាត់ឆ្ពោះទៅកាន់ធម្មនុញ្ញពិភពលោក ស្ដីពីស្វយ័គ្រប់គ្រងមូលដ្ឋានហើយជួយបង្កើតប្រកខ័ណ្ឌដ៏មានប្រសិទ្ធភាពមួយ ដើម្បីអនុវត្តភារកិច្ចទាំងឡាយដែល មានក្នុងផែនការសកម្មភាពអន្តរជាតិដែលពាក់ព័ន្ធនឹងថ្នាក់ក្រោមជាតិ។

១៧-ការរៀបចំបង្កើតធម្មនុញ្ញពិភពលោកមួយ ដែល

សមស្របសម្រាប់គ្រប់កាលៈទេសៈ និងកម្រិតការអភិវឌ្ឍ នៃរដ្ឋជាសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ ចៀស មិនផុតពីភាពស្មុគ្រស្មាញច្រើន ជាងការរៀបចំធម្មនុញ្ញថ្នាក់តំបន់។ ស្វ័យគ្រប់គ្រងមូលដ្ឋាន ត្រូវបានគេមើលឃើញក្នុង បរិបទពិភពលោកថា ជាសមាសភាពដ៏ចម្បងនៃដំណើរការ អភិវឌ្ឍ និងការប្តេជ្ញាប្រកាន់យកនយោបាយវិមជ្ឈការ ដែល រដ្ឋជាសមាជិកបានបង្កើតឡើង នៅក្នុងកិច្ចប្រជុំ Habitat Agenda ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានហានិភ័យមួយ ចំនួន ពោលគឺបុព្វហេតុនេះមិនអាចបន្ថែមនូវការបកស្រាយ គោលការណ៍ដែលមិនអាចអនុវត្តបាន ក្នុងស្ថានភាពដែល មានការខ្វះខាតប្រភពធនធាន និងហេដ្ឋារចនាសម្ព័ន្ធធ្ងន់ធ្ងរ។ ម្យ៉ាងវិញទៀត ការអនុម័តទទួលយកធម្មនុញ្ញអឺរ៉ុប ដោយ ប្រទេសជាច្រើន ក្នុងដំណាក់កាលអន្តរកាល ដែលមិនបាន ចូលរួមក្នុងការសរសេរសេចក្តីព្រាង និងការទទួលយករបស់ IULA និងសមាគមអន្តរជាតិដទៃនូវសេចក្តីប្រកាសពិភពលោក ដែលមានចារិកបទប្បញ្ញត្តិភាគច្រើនដូចគ្នា មានសំណូមពរ ថា គោលការណ៍សកលមួយចំនួន ស្តីពីប្រជាធិបតេយ្យ មូលដ្ឋាន ត្រូវបានកំណត់យ៉ាងច្បាស់ និងប្រកាសឱ្យប្រើជា ផ្លូវការនៅកម្រិតអន្តរជាតិ។

១៨-ក្រុមជំនាញការ ដែលធ្វើការនៅក្រោមអនុស្សាវ

ណៈឃោតយល់គ្នា រវាង UNCHs & WACLAC បានមានយោបល់យល់ឃើញថា មាគ៌ាដ៏ល្អប្រសើរបំផុតឆ្ពោះទៅរៀបចំធម្មនុញ្ញពិភពលោកមួយ គឺតាមការអនុវត្តជាក់ស្ដែងត្រូវពិនិត្យឡើងវិញនូវចំណេះដឹង និងបទពិសោធន៍ដែលមានស្រាប់នៅគ្រប់តំបន់ ដោយគិតទៅដល់ពាក្យបញ្ញត្តិនៅក្នុងធម្មនុញ្ញអឺរ៉ុប ដែលជាលិខិតុបករណ៍ច្បាប់ទី១ ដែលមានលក្ខណៈពហុភាគី ដើម្បីកំណត់ និងការពារគោលការណ៍ស្វ័យភាពមូលដ្ឋាន។ បើផ្អែកលើមូលដ្ឋាននេះ ក្រុមអ្នកជំនាញបានរៀបចំសេចក្ដីព្រាងធម្មនុញ្ញពិភពលោកដំបូង ដូចដែលមានបញ្ចូលនៅក្នុងផ្នែក C នៃឯកសារនេះ។

១៩-អត្ថបទនេះយកលំនាំតាមរចនាសម្ព័ន្ធធម្មនុញ្ញអឺរ៉ុប ដូចដែលបានគូសបញ្ជាក់ក្នុងកថាខ័ណ្ឌទី១១-១២ខាងលើ ដោយមានការធ្វើបច្ចុប្បន្នភាពមួយចំនួន ដើម្បីឱ្យស្របនឹងចរន្តនិន្នាការវិមជ្ឈការនាពេលថ្មីៗ នៅក្នុងបណ្ដាប្រទេសនានា។ មាត្រាថ្មីមួយ(មាត្រា១០) ត្រូវបានបន្ថែមកម្មវត្ថុស្ដីពីការចូលរួមរបស់ប្រជាពលរដ្ឋ និងភាពជាដៃគូ ហើយបទប្បញ្ញត្តិ ស្ដីពីការធ្វើសហប្រតិបត្តិការរវាងអាជ្ញាធរមូលដ្ឋាន និងការបង្កើតសមាគម ត្រូវបានពង្រីកទៅជាពីរមាត្រា ដែលពាក់ព័ន្ធនឹងកម្រិតថ្នាក់ជាតិនិងអន្តរជាតិ (គឺមាត្រា១១ និង១២)។ បុព្វកថា រៀបរាប់ទំនាក់ទំនងធម្មនុញ្ញនេះ ជាមួយ

នឹងអត្ថបទរបស់អង្គការសហប្រជាជាតិ រួមមានរបៀបវារៈទី ២១ សេចក្ដីប្រកាសទីក្រុង Istanbul និង Agenda ហើយមានការប្ដេជ្ញាចិត្តដ៏ជាក់លាក់មួយ (ក្នុងបុព្វកថា និងមាត្រា ៦) ចំពោះសមភាពយេនឌ័រ។

២០-វិធីសាស្ត្រទន់ភ្លន់នៅក្នុងធម្មនុញ្ញអឺរ៉ុប ដែលពាក់ព័ន្ធនឹងតម្រូវការឱ្យមានការចុះហត្ថលេខា លើមូលដ្ឋាននៃការប្ដេជ្ញាចិត្ត គោរពឱ្យបាននូវបទប្បញ្ញត្តិសំខាន់ៗ កម្រិតអប្បបរមា ក៏ត្រូវបានចាត់ទុកជាគំរូមួយ ហើយបទប្បញ្ញត្តិស្ដីពីការចុះហត្ថលេខា ការផ្ដល់សច្ចាប័ន និងនីតិវិធីក្នុងការចូលជាសមាជិកនៅក្នុងផ្នែកទី II និង III គឺផ្អែកទៅលើអនុសញ្ញារបស់អង្គការសហប្រជាជាតិដែលមានស្រាប់។

**ច-ដំណើរការពិគ្រោះយោបល់**

២១-UNCHs និង WACLAC សព្វថ្ងៃនេះ ស្នើឱ្យមានការចាប់ផ្ដើមដំណើរការពិគ្រោះយោបល់ទូលំទូលាយមួយ ដែលពាក់ព័ន្ធនឹងសំណើទាំងអស់ សុំឱ្យមានធម្មនុញ្ញពិភពលោកមួយ ដែលជាបំណងប្រាថ្នាចុងក្រោយរបស់ខ្លួន ដើម្បីស្វែងរកការព្រមព្រៀងកុងសង់ស៊ីសឱ្យបានច្រើនចំពោះសំណៅអត្ថបទមួយដែលអាចកែប្រែបាន បើមានភាពចាំបាច់ស្របទៅតាមការពិគ្រោះយោបល់ ដែលនឹងត្រូវធ្វើទៅសម័យប្រជុំលើកទី១៨របស់ គណៈកម្មការអង្គការសហប្រជាជាតិ

ស្ដីពីការតាំងទីលំនៅមនុស្សជាតិ ក្នុងឆ្នាំ២០០១ ដើម្បីសុំការអនុម័តយល់ព្រមរួច ហើយផ្ញើទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ។ ដើម្បីទទួលបានការអនុម័តនៅកម្រិតទាំងនេះ គេបានប្រមើលឃើញថា ធម្មនុញ្ញពិភពលោកនេះនឹងត្រូវប្រកាសឱ្យប្រើជាផ្លូវការ នៅក្នុងសម័យប្រជុំពិសេស របស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ (ដែលហៅថាIstanbul+5) ឱ្យក្លាយជាលិខិតូបករណ៍មួយដ៏ជាក់លាក់ ក្នុងចំណោមលិខិតុបករណ៍ជាច្រើន ដែលសំដៅជួយសម្របសម្រួល និងរៀបចំ ចងក្រងជាក្រុម ដើម្បីអនុវត្តរបៀបវារៈ Habitat Agenda នេះ។

២២-ដំណើរការពិគ្រោះយោបល់ ត្រូវមានសមាសធាតុមួយចំនួនដូចជា៖

(a)-ការចរាចរចែកផ្សាយរបាយការណ៍នេះជាមុនក្នុងចំណោមសមាគមថ្នាក់តំបន់ អន្តរជាតិនៃទីក្រុង និងអាជ្ញាធរមូលដ្ឋាន ដែលជាសមាជិកភាពរបស់ WACLAC និងការពិចារណានៅក្នុងកិច្ចប្រជុំ ឬសមាជរបស់ខ្លួនតាមលំដាប់

(b)-ការដាក់បញ្ចូលក្នុងសេចក្ដីព្រាងនូវកម្មវិធីការងារសម្រាប់ឆ្នាំ២០០០-២០០១ របស់មជ្ឈមណ្ឌលអង្គការសហប្រជាជាតិទទួលបន្ទុកការតាំងទីលំនៅមនុស្សជាតិ(Habitat) ក្នុងការសហការជាមួយសមាគមអន្តរជាតិនៃទីក្រុង និងអា-

ជ្ញាធរមូលដ្ឋានដើម្បីបន្តស្តាបនាធម្មនុញ្ញនេះថែមទៀត

(c)- ការរៀបចំស្របតាមកថាខ័ណ្ឌទី២នៃសេចក្តីសំរេចចិត្តលេខCHS/16/12 ដែលគណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកការតាំងទីលំនៅមនុស្សជាតិ បានប្តេជ្ញាដោយខ្លួនឯង ផ្តល់ឱកាសឱ្យដៃគូនានា ចូលរួមពិភាក្សាជាមួយគ្នា និងជាមួយរដ្ឋាភិបាលដែលបើអាចធ្វើជាធាតុ ចូលសម្រាប់ការពិភាក្សាលម្អិតរបស់គណៈកម្មការក្នុងការពិភាក្សាជាផ្លូវការ នៅក្នុងសម័យប្រជុំលើកទី១៧របស់គណៈកម្មការនៅខែឧសភា ឆ្នាំ១៩៩៩ ដែលពេលនោះនឹងមានគណៈប្រតិភូ រដ្ឋាភិបាលមូលដ្ឋានអាចបង្ហាញគោលបំណង និងខ្លឹមសារនៃធម្មនុញ្ញពិភពលោក សម្រាប់ការពិភាក្សាបឋមជាមួយរដ្ឋាភិបាលថ្នាក់ជាតិ

(d)-ការរៀបចំក្នុងកំឡុងឆ្នាំ១៩៩៨ និង១៩៩៩ ដោយសហការជាមួយ ទីក្រុងទាំងឡាយដែលត្រូវបានជ្រើសរើសធ្វើជាម្ចាស់ផ្ទះ និងរដ្ឋាភិបាលជាតិ របស់ខ្លួននៅទ្វីបអាហ្វ្រិក អាស៊ី អាមេរិកឡាទីន និងប្រហែលជានៅរដ្ឋអារ៉ាប់ សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់អនុតំបន់ ឬតំបន់ពិសេសពាក់ព័ន្ធនឹងធម្មនុញ្ញពិភពលោក ដែលមានតំណាងនៃរដ្ឋាភិបាលថ្នាក់ជាតិ អាជ្ញាធរមូលដ្ឋាន និងតួអង្គពាក់ព័ន្ធផ្សេងទៀត ។ WACLAC នឹងជួយធ្វើការជ្រើសរើសទីក្រុងម្ចាស់ផ្ទះ និងចាត់

វិធានការតាមគ្រប់លទ្ធភាព ដើម្បីធានាឱ្យមានតំណាងរដ្ឋាភិបាលមូលដ្ឋាន មកពីគ្រប់តំបន់នីមួយៗ

(e)-ការបញ្ចូលសំណើស្តីពីធម្មនុញ្ញពិភពលោកទៅក្នុងរបៀបវារៈ នៃកិច្ចប្រជុំពិគ្រោះយោបល់ទៀងទាត់ថ្នាក់រដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ ដែលបានធ្វើឡើងនៅតាមតំបន់នីមួយៗ មុនសម័យប្រជុំលើកទី១៧ និង១៨ របស់គណៈកម្មការអង្គការសហប្រជាជាតិ ស្តីពីការតាំងទីលំនៅមនុស្សជាតិ

(f)-ការពិគ្រោះយោបល់សមស្របជាមួយសមាជិកសភាទូទាំងពិភពលោក ស្តីអំពីបញ្ហាការតាំងទីលំនៅជាមួយក្រុមថ្នាក់តំបន់របស់ខ្លួនជាមួយមូលនិធិ និង NGOs ពាក់ព័ន្ធនឹងសមាគមជាដៃគូរបស់ខ្លួន ស្របតាមដំណើរការរៀបចំទាំងមូល

(g)-ការប្រជុំវាយតម្លៃតាមពេលកំណត់ទៀងទាត់ពីសំណាក់ក្រុមអ្នកជំនាញការ UNCHS/WACLAC ដើម្បីពិនិត្យមើលលទ្ធផលនៃកិច្ចពិគ្រោះយោបល់ទាំងនេះ ដោយផលិតឱ្យបាន (បើមានការចាំបាច់) នូវសេចក្តីព្រាងកែសំរួលលើកទី១នៃធម្មនុញ្ញ នៅក្នុងខែមេសា ឆ្នាំ១៩៩៩ ឱ្យបានមុនសម័យប្រជុំលើកទី១៧របស់គណៈកម្មការ និងការកែសំរួលលើកទី២ នៅក្នុងខែធ្នូ ឆ្នាំ២០០០ ដោយមានការដាក់បញ្ចូល

ក្នុងឯកសារការងារផ្លូវការ ដើម្បីផ្ញើជូនសម័យប្រជុំលើកទី ១៨ របស់គណៈកម្មការ នៅខែឧសភា ឆ្នាំ២០០១។

២៣-UNCHS និង WACLAC នឹងរៀបចំយុទ្ធសាស្ត្រស្វែងរកមូលនិធិរួមគ្នា ដើម្បីបង្កើតឱ្យមានកញ្ចប់ថវិកាជាក់លាក់មួយ សម្រាប់រ៉ាប់រងលើចំណាយរៀបចំដំណើរការពិគ្រោះយោបល់ និងដំណើរការស្វែងរកការព្រមព្រៀង ជាក្រុងសង់ស៊ីស ដូចបានជម្រាបជូនខាងលើប្រកបដោយភាពស័ក្តិសិទ្ធិ និងតម្លាភាព ដើម្បីធានាឱ្យមានកម្រិតតំណាងសមស្របពីគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ អាចចូលរួមបានក្នុងដំណើរការទាំងមូល ។ ក្នុងន័យនេះ គេអាចប្រមើលមើលឃើញថាសមាគមអន្តរជាតិដែលជាសមាជិកភាពរបស់WACLACនឹងជំរុញដំណើរតាមធម្មនុញ្ញនេះ ឱ្យឆ្ពោះទៅមុខតាមកម្មវិធីរបស់ខ្លួន។ UNCHS នឹងចំណាយធនធានសំខាន់ៗមួយចំនួនសម្រាប់ការងារនេះ សម្រាប់ឆ្នាំ១៩៩៨-១៩៩៩ ដោយគោរពតាមការប្តេជ្ញាចិត្តរបស់ខ្លួន នៅក្នុងអនុស្សារណៈនៃការយោគយល់គ្នាជាមួយ WACLAC ដោយរង់ចាំការបញ្ចូលសេចក្តីធម្មនុញ្ញនេះជាផ្លូវការ ទៅក្នុងកម្មវិធីការងារសម្រាប់ឆ្នាំ ២០០០-២០០១។

**សេចក្តីសន្និដ្ឋាន**

២៤-ការអនុម័តរបស់មហាសន្និបាតអង្គការសហប្រជា

ជាតិលើរបៀបវារៈ Habitat Agenda និងផែនការសកម្មភាពពិភពលោករបស់ខ្លួន កាលពីខែធ្នូ ឆ្នាំ១៩៩៦ បានផ្ដល់អាណត្តិនយោបាយ សម្រាប់ជំរុញដំណើរការ ឆ្ពោះទៅកាន់ធម្មនុញ្ញពិភពលោកស្ដីពីស្វ័យគ្រប់គ្រងមូលដ្ឋាន។ នៅពេលធ្វើការអនុម័ត ក្រោយពីបញ្ចប់ដំណើរការពិគ្រោះយោបល់ដ៏ទូលាយ ធម្មនុញ្ញនេះ ត្រូវបានគ្រោងរៀបចំតំរូសម្រាប់ការព្រមព្រៀងគ្នាជាអន្តរជាតិឱ្យបានប្រសើរឡើង ក៏ប៉ុន្តែការអនុវត្តការប្ដេជ្ញាចិត្តរបស់រដ្ឋជាសមាជិកចំពោះវិមជ្ឈការ ដូចមានចែងនៅក្នុងសេចក្ដីប្រកាសទីក្រុង Istanbul និងក្នុងរបៀបវារៈ Habitat Agenda មានការបត់បែនខ្លះ។ ការគាំទ្រនិន្នាការអនុវត្តវិមជ្ឈការ និងប្រជាធិបតេយ្យនៅពេលថ្មីៗ នៅបណ្ដាលប្រទេសជាច្រើន យកមូលដ្ឋានធម្មនុញ្ញស្ដីពីស្វ័យគ្រប់គ្រងមូលដ្ឋាន ផ្អែកលើគោលការណ៍ដែលទទួលស្គាល់ជាអន្តរជាតិ អាចចូលរួមចំណែកដ៏សំខាន់ ក្នុងការអនុវត្តរបៀបវារៈ Habitat Agenda ។ ការផ្ដល់មូលដ្ឋានធម្មនុញ្ញច្បាប់ច្បាស់លាស់ និងប្រកបដោយចីរភាព ជាគ្រឹះដ៏សំខាន់ដើម្បីធ្វើឱ្យតំណែងអាជ្ញាធរមូលដ្ឋាន ក្លាយជាដៃគូនៅក្នុងប្រព័ន្ធអភិបាលកិច្ច នៅគ្រប់ប្រទេសទាំងអស់។ ហើយមូលដ្ឋាននេះ នឹងជួយឱ្យអាជ្ញាធរមូលដ្ឋាន អាចអនុវត្តតួនាទីពិតប្រាកដរបស់ខ្លួន ក្នុងការដឹកនាំសហគមន៍ និងក្នុងការប្រើ-

ប្រាស់កម្លាំង សុបិន្ត និងគំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានដែល ប្រាថ្នាចង់សម្រេចបានគោលដៅទាំងទ្វេ គឺការមានទីលំនៅសមរម្យ សម្រាប់ប្រជាពលរដ្ឋទាំងអស់គ្នា និងការអភិវឌ្ឍទីលំនៅសម្រាប់មនុស្សជាតិ ប្រកបដោយចីរភាព ក្នុងពិភពនគរូបនីយកម្មនាសម័យទំនើបនេះ ។

# សេចក្ដីព្រាង
# រដ្ឋធម្មនុញ្ញពិភពលោក
# ស្ដីពី
# រដ្ឋាភិបាលស្វ័យគ្រប់គ្រងមូលដ្ឋាន

## បុព្វកថា

**១-រដ្ឋជាភាគីនៃធម្មនុញ្ញនេះ**

-ដោយទទួលស្គាល់ថា បញ្ហាសកលលោកជាច្រើន ដូចមានភស្តុតាងបង្ហាញនៅក្នុងរបៀបវារៈ២១ និងរបៀបវារៈ Habitat Agenda ត្រូវដោះស្រាយនៅកម្រិតថ្នាក់មូលដ្ឋាន ហើយមិនអាចដោះស្រាយបានដោយជោគជ័យ ដោយគ្មានការពិភាក្សា និងសហប្រតិបត្តិការទូលំទូលាយ រវាងអាជ្ញាធរថ្នាក់រដ្ឋ និងអាជ្ញាធរមូលដ្ឋាន

-ដោយមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន ជាដៃគូដ៏ជិតស្និទ្ធបំផុតរបស់រដ្ឋាភិបាលកណ្ដាល មានសារសំខាន់ក្នុងការអនុវត្តរបៀបវារៈ២១ និងរបៀបវារៈ Habitat Agenda

-យោងគោលការណ៍ដែលទទួលស្គាល់នៅក្នុងមាត្រា ២១ នៃសេចក្ដីថ្លែងការណ៍សាកលស្ដីពីសិទ្ធិមនុស្សថា ឆន្ទៈរបស់ប្រជាពលរដ្ឋ គឺជាមូលដ្ឋានអំណាចរបស់រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់

-ដោយមានជំនឿថា គោលការណ៍បែងចែកមុខងារ (Principle of Subsidiarity )* គឺជាមូលដ្ឋាននៃការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ និងការចូលរួម ហើយជឿថា ការបែងចែកភារកិច្ច និងការទទួលខុសត្រូវ គួរគោរពតាមគោលការណ៍នេះ

-ដោយប្តេជ្ញាលើកកម្ពស់ការអនុវត្តវិមជ្ឈការតាមរយៈអាជ្ញាធរមូលដ្ឋានតាមបែបប្រជាធិបតេយ្យ និងពង្រឹងសមត្ថភាពស្ថាប័ន និងហិរញ្ញវត្ថុរបស់អាជ្ញាធរមូលដ្ឋានឱ្យរឹងមាំ

-ដោយមានជំនឿថា សមភាពយេនឌ័រ និងការដាក់បញ្ចូលក្នុងសង្គម ត្រូវដើរទន្ទឹមគ្នាជាមួយលទ្ធិប្រជាធិបតេយ្យ និងការចូលរួមរបស់មូលដ្ឋាន ហើយជឿថា គោលដៅទាំងនេះ នឹងជួយពង្រឹងគ្នាទៅវិញទៅមក

-ដោយបន្តប្តេជ្ញាសម្របសម្រួល និងជំរុញឱ្យមានការចូលរួមទូលំទូលាយពីប្រជាជនទាំងអស់ និងអង្គការ សហគមន៍របស់ប្រជាជន ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងក្នុងការអនុវត្ត និងការឃ្លាំមើលយុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីនានា ស្តីពីការតាំងលំនៅដ្ឋានរបស់មនុស្ស

-ដោយមានជំនឿថា លទ្ធិប្រជាធិបតេយ្យមូលដ្ឋាន

* គោលការណ៍បែងចែកអំណាច តួនាទី ភារកិច្ច គឺរដ្ឋាភិបាលកណ្តាលធ្វើកិច្ចការណាដែលរដ្ឋាភិបាលមូលដ្ឋានធ្វើមិនកើត ឬធ្វើកើត តែមិនមានភាពប្រសើរជាង ។

រឹងមាំ តាមរយៈអាជ្ញាធរមូលដ្ឋាន ដែលកើតចេញពីការបោះឆ្នោត ដោយសេរី ស្របតាមស្តង់ដារ និងការអនុវត្តវិជ្ជាជីវៈនៅថ្នាក់រដ្ឋបាលមូលដ្ឋាន ជាមធ្យោបាយលើកកម្ពស់គណនេយ្យភាពសាធារណៈ និងពង្រឹងក្រុមសង្គមប្រឆាំងអំពើពុករលួយ

-ដោយជឿជាក់ថា អត្ថិភាពអាជ្ញាធរមូលដ្ឋានរឹងមាំ ដែលមានតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ និងប្រកពធនធានគ្រប់គ្រាន់ ជានាឱ្យការផ្តល់សេវាកម្ម ប្រកបដោយប្រសិទ្ធភាព និងនៅកៀកនឹងប្រជាពលរដ្ឋ។

**២-បានព្រមព្រៀងគ្នាដូចតទៅនេះ ៖**

**មាត្រា១** : រដ្ឋជាភាគី គឺស្ម័គ្រចិត្តអនុវត្តតាមមាត្រាខាងក្រោមនេះ តាមរបៀប នឹងតាមវិសាលភាពដូចដែលមានចែងក្នុងមាត្រា១៨នៃធម្មនុញ្ញនេះ។

## ផ្នែកទី១: បញ្ញត្តទូទៅ

**មាត្រា២**: មូលដ្ឋានធម្មនុញ្ញ និងច្បាប់សម្រាប់ស្វ័យាភិបាលមូលដ្ឋានគោលការណ៍ ស្តីពីស្វ័យាភិបាលមូលដ្ឋាន ត្រូវមានការទទួលស្គាល់ក្នុងច្បាប់ ជាតិនិងបើអាចធ្វើបានមានការធានាដោយរដ្ឋធម្មនុញ្ញ។

**មាត្រា៣**: ទស្សនទានស្តីពីស្វ័យាភិបាលមូលដ្ឋាន ៖

១-ស្វ័យាភិបាលមូលដ្ឋាន គឺសំដៅដល់សិទ្ធិ និងលទ្ធ

ភាពរបស់អាជ្ញាធរមូលដ្ឋាន ស្របតាមក្របខ័ណ្ឌច្បាប់ ដើម្បីធ្វើនិយតភាវូបនីយកម្ម និងអនុវត្តឱ្យបានសម្រេចនូវបន្ទុកការងារសាធារណៈ ដែលឋិតក្រោមការទទួលខុសត្រូវផ្ទាល់របស់ខ្លួន និងជាប្រយោជន៍សម្រាប់ប្រជាជននៅមូលដ្ឋាន

២-ក្រុមប្រឹក្សា ត្រូវអនុវត្តសិទ្ធិនេះ ឬធ្វើការប្រជុំ ដែលមានសមាសភាពសមាជិកដែលកើតចេញពីការបោះឆ្នោតដោយសេរី ដោយសន្លឹកឆ្នោតសម្ងាត់ តាមរយៈការបោះឆ្នោតដោយផ្ទាល់ ស្មើភាព និងដោយសកល ហើយដែលមានអង្គប្រតិបត្តិ ដែលទទួលខុសត្រូវចំពោះក្រុមប្រឹក្សា។

**មាត្រា៤:** វិសាលភាពនៃស្វ័យាភិបាលមូលដ្ឋាន

១-អាជ្ញាធរមូលដ្ឋាន ត្រូវតែមានឆន្ទានុសិទ្ធិពេញលេញដើម្បីធ្វើការផ្តួចផ្តើមគំនិតពាក់ព័ន្ធគ្រប់បញ្ហាទាំងអស់ ដែលមិនត្រូវបានដកហូតសមត្ថកិច្ចរបស់ខ្លួនដោយច្បាប់ និងមិនត្រូវប្រគល់ឱ្យអាជ្ញាធរណាមួយផ្សេងទេ

២-អំណាច និងការទទួលខុសត្រូវជាមូលដ្ឋានរបស់អាជ្ញាធរមូលដ្ឋាន ត្រូវតែកំណត់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់។ ក៏ប៉ុន្តែបទប្បញ្ញត្តិនេះ មិនត្រូវហាមឃាត់ការប្រគល់អំណាច និងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន ចំពោះគោលបំណងពិសេសឡើយ

៣-យោងតាមគោលការណ៍បែងចែកតួនាទីភារកិច្ច

អាជ្ញាធរទាំងឡាយណា ដែលនៅកៀកនឹងប្រជាពលរដ្ឋបំផុត ជាទូទៅត្រូវមានការទទួលខុសត្រូវជាសាធារណ:។ នៅក្នុងស្មារតីនេះ ការបែងចែក ការទទួលខុសត្រូវឱ្យអាជ្ញាធរណាមួយទៀត ត្រូវតែឈរលើតម្រូវការភាពស័ក្តិសិទ្ធិ ផ្នែកបច្ចេកទេស ឬសេដ្ឋកិច្ច

៤-អំណាចដែលផ្តល់ឱ្យអាជ្ញាធរមូលដ្ឋាន ជាធម្មតាត្រូវឱ្យមានលក្ខណ:ពេញលេញ និងដាច់មុខ ។ អំណាចនេះមិនត្រូវបាត់បង់ និងមិនអាចកាត់តម្រឹម ដោយអាជ្ញាធរផ្សេងបានទេ លើកលែងតែមានច្បាប់កំណត់

៥-អំណាចដែលទទួលប្រតិភូកម្មពីអាជ្ញាធរកណ្តាល ឬថ្នាក់តំបន់ អាជ្ញាធរមូលដ្ឋាន ត្រូវតែទទួលបានឆន្ទានុសិទ្ធិ នៅក្នុងការសម្របការអនុវត្តរបស់ខ្លួន ឱ្យស្របនឹងស្ថានភាពរបស់មូលដ្ឋាន

៦-អាជ្ញាធរមូលដ្ឋាន ត្រូវតែចូលរួមទៅតាមពេលវេលា និងតាមវិធីមួយ សមស្របក្នុងដំណើរការកសាងផែនការនិងការធ្វើសេចក្តីសម្រេចចិត្ត លើគ្រប់កិច្ចការទាំងអស់ដែលពាក់ព័ន្ធដល់ខ្លួន។

**មាត្រា៥:** ការការពារព្រំប្រទល់ដែនដីរបស់អាជ្ញាធរមូលដ្ឋាន ការផ្លាស់ប្តូរព្រំប្រទល់របស់អាជ្ញាធរមូលដ្ឋាន មិនអាចធ្វើទៅដោយគ្មានការពិគ្រោះយោបល់ជាមុន ពីសហគមន៍មូលដ្ឋាន

ពាក់ព័ន្ធបានទេ ហើយបើអាចធ្វើបាន គឺតាមរយៈការធ្វើប្រជាមតិ ស្របតាមការកំណត់របស់ច្បាប់។

**មាត្រា៦:** រចនាសម្ព័ន្ធរដ្ឋបាល និងធនធានសមស្របសម្រាប់បំពេញភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន

១-អាជ្ញាធរមូលដ្ឋាន ត្រូវមានអំណាចកំណត់រចនាសម្ព័ន្ធរដ្ឋបាលផ្ទៃក្នុងរបស់ខ្លួន ដើម្បីសម្របទៅតាមតម្រូវការរបស់មូលដ្ឋាន និងធានាឱ្យមានការគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាព

២-អាជ្ញាធរមូលដ្ឋាន ត្រូវទទួលបានការឧបត្ថម្ភគាំទ្រពីរដ្ឋាភិបាលថ្នាក់ខ្ពស់ ក្នុងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលបច្ចេកទេស និងគ្រប់គ្រង ហើយក្នុងការរៀបចំរចនាសម្ព័ន្ធដែលមានការទទួលខុសត្រូវមានតម្លាភាព និងគណនេយ្យភាព

៣-លក្ខណៈការងាររបស់បុគ្គលិករដ្ឋាភិបាលមូលដ្ឋាន ត្រូវតែអាចធ្វើការជ្រើសរើស និងរក្សាទុកបុគ្គលិកដែលមានគុណសម្បត្តិខ្ពស់ ដោយផ្អែកលើសមត្ថភាព វិជ្ជាជីវៈ បទពិសោធន៍ និងសមភាពយេនឌ័រ ហើយដើម្បីសម្រេចបានគោលដៅនេះ គេត្រូវផ្ដល់ឱកាសទទួលបានការបណ្ដុះបណ្ដាល តម្លៃតបស្នង និងសេចក្ដីសង្ឃឹមលើការរីកចម្រើនការងារទៅអនាគត។

**មាត្រា៧:** លក្ខខណ្ឌទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន

១-លក្ខខណ្ឌការិយាល័យរបស់តំណាង ដែលជាប់ឆ្នោតនៅថ្នាក់មូលដ្ឋាន ត្រូវមានការធានាការអនុវត្តមុខងាររបស់គេបានដោយសេរី

២-តំណាង ត្រូវទទួលបានថវិកាសម្រាប់ការចំណាយសមស្របក្នុងការបំពេញការងាររបស់ខ្លួន ព្រមទាំងទទួលបានសំណងលើការបាត់បង់ប្រាក់ចំណូល ឬតម្លៃតបស្នងសមស្របសម្រាប់ការបំពេញការងារ និងទទួលបានការការពារផ្នែកសង្គម

៣-ច្បាប់ត្រូវតែចែងបញ្ជាក់ឱ្យច្បាស់អំពីមុខងារ និងសកម្មភាពណាដែលចាត់ទុកថា មានវិសមតិភាពជាមួយនឹងមុខតំណែងដែលកើតចេញពីការបោះឆ្នោតនៅមូលដ្ឋាន។

**មាត្រា៨:** ការត្រួតពិនិត្យមើលសកម្មភាពអាជ្ញាធរមូលដ្ឋាន

១-ការត្រួតពិនិត្យលើអាជ្ញាធរមូលដ្ឋានអាចធ្វើទៅបាន លុះត្រាតែស្របតាមនីតិវិធី ហើយមានករណីជាច្រើនដូចមានចែងដោយរដ្ឋធម្មនុញ្ញ ឬច្បាប់ជាធរមាន

២-ការត្រួតពិនិត្យសកម្មភាពរបស់អាជ្ញាធរមូលដ្ឋានត្រូវអនុលោមទៅតាមច្បាប់ និងគោលការណ៍ធម្មនុញ្ញ។ បើនិយាយពីតួនាទី ភារកិច្ចដែលធ្វើប្រតិភូកម្មដល់អាជ្ញាធរមូលដ្ឋាន ការត្រួតពិនិត្យរដ្ឋបាលរបស់អាជ្ញា ធរថ្នាក់លើទោះជាយ៉ាងណាក៏ដោយ មិនអាចដើរហួសគន្លងច្បាប់

ដើម្បីអនុលោមទៅតាមគោលនយោបាយជាតិទេ

៣-ការត្រួតពិនិត្យអាជ្ញាធរមូលដ្ឋាន ត្រូវធ្វើឡើងនៅពេលណាចាំបាច់ស្របទៅតាមការការពារផលប្រយោជន៍រួម

៤-ប្រសិនបើរដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិ អនុញ្ញាតឱ្យមានការផ្អាក ឬរំលាយក្រុមប្រឹក្សាមូលដ្ឋាន ការផ្អាក ឬការបញ្ឈប់ការងាររបស់អង្គប្រតិបត្តិមូលដ្ឋាន វិធានការណ៍នេះ ត្រូវធ្វើឡើង ស្របទៅតាមនីតិវិធីច្បាប់ត្រឹមត្រូវ ។ ដំណើរការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា និងអង្គប្រតិបត្តិនេះ ត្រូវដំណើរការឡើងវិញក្នុងរយៈពេលដ៏ឆាប់បំផុត តាមដែលធ្វើទៅបានតាមការកំណត់របស់ច្បាប់។

**មាត្រា៩:** ប្រភពធនធានហិរញ្ញវត្ថុរបស់អាជ្ញាធរមូលដ្ឋាន

១-អាជ្ញាធរមូលដ្ឋាន ត្រូវតែមានសិទ្ធិទទួលបានប្រភពធនធានហិរញ្ញវត្ថុគ្រប់គ្រាន់របស់ខ្លួន ដែលអាចប្រើប្រាស់បានដោយសេរី ស្របតាមក្របខ័ណ្ឌសិទ្ធិអំណាចរបស់ខ្លួន។

២-ប្រភពធនធានហិរញ្ញវត្ថុរបស់អាជ្ញាធរមូលដ្ឋាន ត្រូវសមស្របទៅនឹងទំហំតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន។

៣-សមាមាត្រនៃប្រភពធនធានហិរញ្ញវត្ថុសមស្របរបស់អាជ្ញាធរមូលដ្ឋាន ត្រូវទទួលបានពីពន្ធអាករប្រាក់ឈ្នួល និងកំរៃបន្ទុកនៅមូលដ្ឋាន ដែលអាជ្ញាធរទាំងនោះមានសិទ្ធិ

អំណាចកំណត់កម្រិតអត្រាបាន។

៤-ពន្ធអាករ ដែលអាជ្ញាធរមូលដ្ឋានត្រូវមានសិទ្ធិប្រមូលបាន ឬមានសិទ្ធិទទួលបានចំណែកដែលបានធានា ត្រូវតែមានលក្ខណៈទូទៅគ្រប់គ្រាន់ និងមានភាពបត់បែនបំផុត ដើម្បីឱ្យអាជ្ញាធរនោះបំពេញការទទួលខុសត្រូវរបស់ខ្លួនបាន។

៥-ការការពារអាជ្ញាធរដែលមានស្ថានភាពហិរញ្ញវត្ថុទន់ខ្សោយ ទាមទារឱ្យមានប្រព័ន្ធសមតុល្យសមីកាហិរញ្ញវត្ថុ តាមខ្សែបណ្ដោយ និងខ្សែទទឹង។

៦-អាជ្ញាធរមូលដ្ឋាន ត្រូវតែចូលរួមក្នុងការរៀបចំវិធានបទដ្ឋាន សម្រាប់គ្រប់គ្រងការបែងចែកចំណែក ធនធានដែលត្រូវបែងចែកឡើងវិញនោះ។

៧-ការផ្ទេរវិភាជន៍ហិរញ្ញវត្ថុឱ្យបានច្រើនទៅឲ្យអាជ្ញាធរមូលដ្ឋាន អាជ្ញាធរមូលដ្ឋានត្រូវឈរនឹងអាទិភាពនេះ ហើយមិនត្រូវធ្វើសម្រាប់តែគម្រោងពិសេសណាមួយទេ។ ការផ្ដល់ថវិកាឧបត្ថម្ភ មិនត្រូវដកហូតសិទ្ធិសេរីភាពមូលដ្ឋានរបស់អាជ្ញាធរមូលដ្ឋាន តាមការអនុវត្តអំណាចឆន្ទានុសិទ្ធិផ្នែកនយោបាយ ស្របតាមយុត្តាធិការផ្ទាល់របស់ខ្លួនឡើយ។

៨-សម្រាប់គោលបំណងនៃការខ្ចីមូលធនវិនិយោគ អាជ្ញាធរមូលដ្ឋាន ត្រូវមានសិទ្ធិរកទីផ្សារមូលធនជាតិ និង

អន្តរជាតិ។

**មាត្រា១០:** ការចូលរួមរបស់ប្រជាពលរដ្ឋ និងភាពជាដៃគូរ

១-អាជ្ញាធរមូលដ្ឋាន ត្រូវមានសិទ្ធិកំណត់ទម្រង់បែបបទសមស្របសម្រាប់ការចូលរួមរបស់ប្រជាជន និងពលរដ្ឋស៊ីវិល ក្នុងការធ្វើសេចក្តីសម្រេច និងក្នុងការបំពេញតួនាទីដឹកនាំសហគមន៍របស់ខ្លួន

២-អាជ្ញាធរមូលដ្ឋានត្រូវមានអំណាចបង្កើត និងកសាងភាពជាដៃគូរជាមួយគ្រប់តួអង្គសង្គមស៊ីវិលទាំងអស់ ជាពិសេសអង្គការមិនមែនរដ្ឋាភិបាលនានា និងអង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍ និងជាមួយផ្នែកឯកជន ព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀត។

**មាត្រា១១:** សមាគមអាជ្ញាធរមូលដ្ឋាន

១-ក្នុងការប្រើប្រាស់អំណាចរបស់ខ្លួន អាជ្ញាធរមូលដ្ឋាន ត្រូវតែមានសិទ្ធិបង្កើតសមាគម ដើម្បីការពារ និងលើកកម្ពស់ផលប្រយោជន៍រួមរបស់ខ្លួន ព្រមទាំងដើម្បីផ្តល់សេវាជូនសមាជិករបស់ខ្លួន ដើម្បីធ្វើសហការ និងធ្វើជានីតិបុគ្គលជាមួយអាជ្ញាធរមូលដ្ឋានផ្សេងទៀត ក្នុងការអនុវត្តភារកិច្ចដែលជាប្រយោជន៍រួម

២-រដ្ឋាភិបាលកម្រិតផ្សេងទៀតត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន នៅពេលរៀបចំធ្វើច្បាប់ដែលប៉ះពាល់ដល់

រដ្ឋាភិបាលមូលដ្ឋាន។

**មាត្រា១២:** កិច្ចសហប្រតិបត្តិការអន្តរជាតិ

១-សិទ្ធិបង្កើតសមាគមរបស់អាជ្ញាធរមូលដ្ឋាន ត្រូវរួមបញ្ចូលសិទ្ធិ រួមទាំងសមាគមអាជ្ញាធរមូលដ្ឋានអន្តរជាតិ

២-អាជ្ញាធរមូលដ្ឋាន ក៏ត្រូវមានសិទ្ធិតាមច្បាប់ ឬសន្ធិសញ្ញាអន្តរជាតិ ដើម្បីសហការជាមួយសមភាគីរបស់ខ្លួននៅប្រទេសដទៃ រួមទាំងតំបន់ដែលមានព្រំដែនជាប់គ្នា

៣-ក្នុងស្មារតីភាពជាដៃគូរ អាជ្ញាធរមូលដ្ឋានត្រូវចូលរួមក្នុងការចរចា និងការអនុវត្តផែនការសកម្មភាពអន្តរជាតិ ដែលពាក់ព័ន្ធនឹងតួនាទី និងវិស័យទទួលខុសត្រូវរបស់ខ្លួន។

**មាត្រា១៣:** ការការពារស្វ័យាភិបាលមូលដ្ឋានតាមផ្លូវច្បាប់

អាជ្ញាធរមូលដ្ឋាន ត្រូវមានសិទ្ធិប្ដឹងឧបាស្រ័យតាមផ្លូវតុលាការ ដើម្បីការពារស្វ័យភាពរបស់ខ្លួន និងដើម្បីធានាការគោរពច្បាប់ ដែលកំណត់អំពីតួនាទីភារកិច្ចរបស់ខ្លួន និងការពារផលប្រយោជន៍របស់ខ្លួន។

## **ផ្នែកទី២ ៖ បទប្បញ្ញត្តិផ្សេងៗ**

**មាត្រា១៤ :** កាតព្វកិច្ច

១-រដ្ឋភាគីនីមួយៗ មានកាតព្វកិច្ចគោរព យ៉ាងហោចណាស់ ក៏មានកថាខ័ណ្ឌចំនួន២០ នៅក្នុងផ្នែកទី១នៃធម្មនុញ្ញក្នុងនោះក៏មានយ៉ាងហោចណាស់ចំនួន១០កថាខ័ណ្ឌ ដូច

ដែលបានកំណត់គឺ:

-មាត្រា២

-មាត្រា៣ កថាខ័ណ្ឌទី១ និងទី២

-មាត្រា៤ កថាខ័ណ្ឌទី១ ទី២ និងទី៤

-មាត្រា៥

-មាត្រា៧ កថាខ័ណ្ឌទី១

-មាត្រា៨ កថាខ័ណ្ឌទី២

-មាត្រា៩ កថាខ័ណ្ឌទី១ ទី២ និងទី៣

-មាត្រា១១ កថាខ័ណ្ឌទី១

-មាត្រា១៣។

២-រដ្ឋភាគីនីមួយៗនៅពេលដាក់លិខិតុបករណ៍ផ្តល់សច្ចាប័នយល់ព្រម (Ratification) ឬការចូលជាសមាជិក (Acession) ត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ បញ្ជាក់អំពីកថាខ័ណ្ឌដែលបានជ្រើសរើស ស្របតាមបទប្បញ្ញត្តិនៃកថាខ័ណ្ឌ១នៃមាត្រានេះ

៣-រដ្ឋភាគីណាក៏ដោយ នៅពេលចូលក្រោយគេអាចជូនដំណឹងទៅអគ្គលេខាធិការថា ខ្លួននឹងទទួលអនុវត្តកថាខ័ណ្ឌណាខ្លះនៃធម្មនុញ្ញនេះ ដែលខ្លួនមិនទាន់បានទទួលយកអនុវត្តនៅឡើយ ស្របតាមលក្ខខណ្ឌនៃកថាខ័ណ្ឌ១ នៃ

មាត្រានេះ

៤-កាតព្វកិច្ចដែលត្រូវបំពេញជាបន្តបន្ទាប់បែបនេះ នឹងត្រូវចាត់ទុកជាផ្នែកបន្ថែម ក្នុងការផ្តល់សច្ចាប័នយល់ព្រម ឬការចូលជាសមាជិករបស់រដ្ឋភាគី តាមការជូនដំណឹង ហើយត្រូវមានសុពលភាពអនុវត្តដូចគ្នា ចាប់ផ្តើមពី៣០ថ្ងៃក្រោយបន្ទាប់ពីអគ្គលេខាធិការ បានទទួលការជូនដំណឹងនោះ។

**មាត្រា១៥** : អាជ្ញាធរដែលឋិតនៅក្រោមធម្មនុញ្ញគោលការណ៍ស្តីពីស្វ័យភិបាលមូលដ្ឋាន ដែលមានក្នុងធម្មនុញ្ញនេះ ត្រូវអនុវត្តទៅលើអាជ្ញាធរមូលដ្ឋានគ្រប់ប្រភេទ ដែលស្ថិតនៅក្នុងដែនដីរបស់រដ្ឋជាភាគី។ ប៉ុន្តែរដ្ឋជាភាគីនីមួយៗនៅពេលដាក់តម្កល់លិខិតុបករណ៍ ផ្តល់សច្ចាប័ន ឬការចូលជាសមាជិករបស់ខ្លួន អាចកំណត់បញ្ជាក់ច្បាស់ អំពីប្រភេទអាជ្ញាធរមូលដ្ឋាន ឬតំបន់ណាដែលខ្លួនមានបំណងកំណត់វិសាលភាពនៃធម្មនុញ្ញនេះ ឬមានបំណងដកចេញវិសាលភាពមួយចំនួន។ រដ្ឋភាគី ក៏អាចរាប់បញ្ចូលប្រភេទអាជ្ញាធរមូលដ្ឋាន ឬតំបន់ក្នុងដែនវិសាលភាពនៃធម្មនុញ្ញនេះ តាមរយៈការជូនដំណឹងជាបន្តបន្ទាប់ ទៅអគ្គលេខាធិការសហប្រជាជាតិ។

**មាត្រា១៦**: ការផ្តល់ព័ត៌មានរដ្ឋភាគីនីមួយៗ ត្រូវផ្តល់ព័ត៌មាន

ពាក់ព័ន្ធទាំងអស់ តាមកាលកំណត់ ស្តីអំពីបទប្បញ្ញត្តិច្បាប់ និងវិធានការដែលខ្លួនបានអនុវត្ត ដើម្បីគោរពតាមខ្លឹមសារនៃធម្មនុញ្ញនេះ ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

**មាត្រា១៧:** ការតាមឃ្លាំមើល សម្រាប់គោលបំណងវាយតម្លៃការវិវឌ្ឍរីកចម្រើន នៅក្នុងការអនុវត្តធម្មនុញ្ញបច្ចុប្បន្ននេះ រដ្ឋភាគីនានា ត្រូវបង្កើតគណៈកម្មាធិការតាមដានឃ្លាំមើលមួយ ។ គណៈកម្មាធិការនេះត្រូវមានតំណាងពីអាជ្ញាធរមូលដ្ឋាននានា។ អគ្គលេខាធិការដ្ឋានរបស់គណៈកម្មាធិការនេះ នឹងត្រូវផ្តល់ដោយអង្គការសហប្រជាជាតិ។

**ផ្នែកទី៣: ការចុះហត្ថលេខា និងការផ្តល់សច្ចាប័ន**

**មាត្រា១៨:** ការចុះហត្ថលេខា និងការផ្តល់សច្ចាប័ន

១-ធម្មនុញ្ញបច្ចុប្បន្ននេះត្រូវបើកឱ្យរដ្ឋទាំងអស់ចុះហត្ថលេខាបាន

២-ធម្មនុញ្ញបច្ចុប្បន្ននេះតម្រូវឱ្យមានការផ្តល់សច្ចាប័នយល់ព្រម។ លិខិតុបករណ៍ផ្តល់សច្ចាប័នត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ

៣-ធម្មនុញ្ញបច្ចុប្បន្ននេះ ត្រូវបើកចំហរឱ្យរដ្ឋណាក៏ដោយ អាចចូលជាសមាជិកបាន ។ លិខិតុបករណ៍ នៃការចូលជាសមាជិក ត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការ

សហប្រជាជាតិ។

**មាត្រា១៩:** ការចូលជាធរមាន

១-ធម្មនុញ្ញនេះ ត្រូវចូលជាធរមាន និងត្រូវអនុវត្ត៣០ថ្ងៃ ក្រោយពីការតម្កល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬការចូលជាសមាជិកទី២០ នៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ

២-ចំពោះរដ្ឋនីមួយៗ ដែលផ្តល់សច្ចាប័ន ឬអនុម័តយល់ព្រមចំពោះធម្មនុញ្ញនេះ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍ផ្តល់សច្ចាប័ន ឬការចូលជាសមាជិកទី២០ ធម្មនុញ្ញនេះ ត្រូវចូលជាធរមានអនុវត្តក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីការតម្កល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬការចូលជាសមាជិករបស់រដ្ឋទាំងនោះ។

**មាត្រា២០:** បញ្ញត្តិអំពីដែនដី

១-រដ្ឋភាគីណាក៏ដោយ នៅពេលចុះហត្ថលេខា ឬតម្កល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬការចូលជាសមាជិក អាចចែងកំណត់ឱ្យច្បាស់ អំពីដែនដី ឬទឹកដីសម្រាប់អនុវត្តធម្មនុញ្ញនេះ

២-នៅពេលក្រោយមករដ្ឋភាគីណាក៏ដោយ អាចពង្រីកវិសាលភាពអនុវត្តធម្មនុញ្ញនេះ ទៅលើដែនដីដទៃដែលមានបញ្ជាក់នៅក្នុងសេចក្តី ប្រកាសដែលបានផ្ញើជូន

អគ្គលេខាធិការអង្គការសហប្រជាជាតិ។ បើនិយាយពីដែនដីធម្មនុញ្ញនេះត្រូវចូលជាធរមានអនុវត្ត ក្នុងរយៈពេល៣០ថ្ងៃក្រោយពីអគ្គលេខាធិការអង្គការសហប្រជាជាតិ បានទទួលសេចក្តីប្រកាសនោះ

៣-សេចក្តីប្រកាសណា ដែលធ្វើឡើងស្របតាមកថាខ័ណ្ឌពីរខាងដើម បើមាននិយាយពីដែនដីនៅក្នុងសេចក្តីប្រកាស អាចត្រូវបានដកវិញបាន តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរជូនអគ្គលេខាធិការ ។ ការដកចេញនេះ ត្រូវមានប្រសិទ្ធភាពក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីអគ្គលេខាធិការទទួលសេចក្តីជូនដំណឹងនេះ។

**មាត្រា២១**:ការប្រកាសមិនទទួលស្គាល់រដ្ឋភាគី អាចប្រកាសមិនទទួលស្គាល់ធម្មនុញ្ញបច្ចុប្បន្ន តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ការប្រកាសមិនទទួលស្គាល់ មានប្រសិទ្ធភាពក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីអគ្គលេខាធិការបានទទួលសេចក្តីជូនដំណឹងនោះ។

**មាត្រា២២**: ការជូនដំណឹង អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបានកំណត់ជាកន្លែងតម្កល់ទុកឯកសារធម្មនុញ្ញបច្ចុប្បន្ន។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ៖

ក-ការចុះហត្ថលេខាណាមួយ

ខ-ការតម្កល់ទុកលិខិតុបករណ៍ផ្ដល់សច្ចាប័ន ឬការចូលជាសមាជិក

គ-កាលបរិច្ឆេទនៃការចូលជាធរមាននៃធម្មនុញ្ញនេះ ស្របតាមមាត្រា ១៩

ឃ-ការជូនដំណឹងអំពីការអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា១៤ កថាខ័ណ្ឌ២ និង៣

ង-ការជូនដំណឹង អំពីការអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា១៥

ច-សកម្មភាពផ្សេងទៀត ការជូនដំណឹង ឬការប្រាស្រ័យទាក់ទងទាំងឡាយ ដែលពាក់ព័ន្ធនឹងធម្មនុញ្ញនេះ។

**មាត្រា២៣** : ការបញ្ជាក់ពីភាពត្រឹមត្រូវនៃអត្ថបទ អត្ថបទសំណៅដើមនៃធម្មនុញ្ញបច្ចុប្បន្នជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដែលមានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ដើម្បីជាសាក្សី ភាពតំណាងពេញសមត្ថភាពរបស់រដ្ឋទាំងឡាយដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ តាមផ្លូវច្បាប់ពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើធម្មនុញ្ញបច្ចុប្បន្ននេះ៕

**ឯកសារ**

បោះពុម្ពផ្សាយក្នុងឆ្នាំ២០១១ដោយ

**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**


វិមានរដ្ឋចំការមន, មហាវិថីព្រះនរោត្តម,ភ្នំពេញ

ទូរស័ព្ទ ៖ (៨៥៥-២៣) ២១១ ៤៤១,២,៣ ទូរសារ៖ (៨៥៥-២៣) ២១១ ៤៤៦

Email : oum_sarith@camnet.com.kh

Website : www.senate.gov.kh